ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

# របាយការណ៍លទ្ធផលវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា

## សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ

មីនា ២០២៦

# មាតិកា


**១. សេចក្តីផ្តើម** .......... 1
១.១. សាវតាររបស់គ្រឹះស្ថានឧត្តមសិក្សា .......... 1
១.១.១ ចក្ខុវិស័យ បេសកកម្ម និងគោលបំណង .......... 1
១.១.២ ស្ថានភាពបុគ្គលិកគ្រប់គ្រង .......... 2
១.១.៣ ស្ថានភាពគ្រូបង្រៀន .......... 3
១.១.៤ ស្ថានភាពនៃកម្មវិធីអប់រំ .......... 4
១.១.៥ ស្ថានភាពនិស្សិត .......... 5
១.១.៦ ស្ថានភាពធនធានសិក្សា .......... 6
១.១.៧ ស្ថានភាពធនធានរូបវន្ត .......... 8
១.១.៨ ស្ថានភាពហិរញ្ញវត្ថុ .......... 9
១.១.៩ កិច្ចសហប្រតិបត្តិការ .......... 10
១.២ គោលបំណងនៃការវាយតម្លៃ .......... 11
**២. វិធីសាស្ត្រនិងដំណើរការនៃការវាយតម្លៃ** .......... 11
២.១ វិធីសាស្ត្រប្រមូលទិន្នន័យនិងព័ត៌មាន .......... 11
២.១.១ ការប្រមូលទិន្នន័យនិងព័ត៌មានដែលមានស្រាប់ .......... 11
២.១.២ ការប្រមូលទិន្នន័យនិងព័ត៌មានបឋម .......... 11
២.១.៣ ការសង្កេត .......... 11
២.២ ការវិភាគទិន្នន័យនិងព័ត៌មាន .......... 11
**៣. លទ្ធផលវាយតម្លៃ** .......... 12
៣.១. ស្តង់ដា១៖ ចក្ខុវិស័យ បេសកកម្ម និងគោលបំណង .......... 12
៣.២. ស្តង់ដា២៖ អភិបាលកិច្ច និងការគ្រប់គ្រង .......... 16
៣.៣. ស្តង់ដា៣៖ បុគ្គលិកអប់រំ .......... 22
៣.៤. ស្តង់ដា៤៖ កម្មវិធីអប់រំ .......... 28
៣.៥. ស្តង់ដា៥៖ សេវានិស្សិត .......... 40
៣.៦. ស្តង់ដា៦៖ ធនធានសិក្សា .......... 50
៣.៧. ស្តង់ដា៧៖ ធនធានរូបវន្ត .......... 57
៣.៨. ស្តង់ដា៨៖ ធនធានហិរញ្ញវត្ថុ .......... 59
៣.៩. ស្តង់ដា៩៖ ការធានាគុណភាពផ្ទៃក្នុង .......... 63
**៤. សេចក្តីសន្និដ្ឋានរួម** .......... 73
**៥. អនុសាសន៍** .......... 75
**៦. សំណូមពរ** .......... 76
**៧. ឧបសម្ព័ន្ធ** .......... 77

# តារាង ក្រាហ្វិក ដ្យាក្រាម


តារាង ១.១ ៖ ការបន្ស៊ីគ្នារវាងចក្ខុវិស័យ បេសកកម្ម និងគោលបំណង ..... 2
ក្រាហ្វិក ១.១ ៖ ស្ថានភាពបុគ្គលិក ..... 3
ក្រាហ្វិក ១.២ ៖ ស្ថានភាពគ្រូបង្រៀន ..... 4
ក្រាហ្វិក ១.៣ ៖ ស្ថានភាពកម្មវិធីអប់រំដំណើរការ ..... 5
ក្រាហ្វិក ១.៤ ៖ ស្ថានភាពនិស្សិតសិក្សា ..... 6
ក្រាហ្វិក ១.៥ ៖ ស្ថានភាពហិរញ្ញវត្ថុ ..... 10
ក្រាហ្វិក ១.៦ ៖ អង្គភាព/ស្ថាប័នកិច្ចសហប្រតិបត្តិការ ..... 10
ក្រាហ្វិក ៣.១.១ ៖ ភាគរយនិស្សិតមានការងារធ្វើ និងស្របនឹងជំនាញ ..... 13
ក្រាហ្វិក ៣.១.២ ៖ ការបោះពុម្ពស្នាដៃលទ្ធផលស្រាវជ្រាវ ..... 14
ក្រាហ្វិក ៣.១.៣ ៖ ស្ថិតិសកម្មភាពសង្គម/សេវាសគមន៍ និង សមាសភាពចូលរួម ..... 15
ក្រាហ្វិក ៣.២.១ ៖ ស្ថិតិបុគ្គលិកបានតែងតាមរចនាសម្ព័ន្ធគ្រប់គ្រង ..... 16
តារាង ៣.២.១ ៖ សមិទ្ធផលការងារក្រុមប្រឹក្សាភិបាល ..... 17
តារាង ៣.២.២ ៖ សមិទ្ធផលការងារគណៈគ្រប់គ្រង ..... 17
តារាង ៣.២.៣ ៖ សមិទ្ធផលការងារក្រុមប្រឹក្សាអប់រំ ..... 18
ក្រាហ្វិក ៣.២.២ ៖ គុណវុឌ្ឍិរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំ ..... 19
តារាង ៣.២.៤ ៖ លទ្ធផលនៃការវាយតម្លៃប្រសិទ្ធភាពការងារក្រុមប្រឹក្សាភិបាល ..... 21
ក្រាហ្វិក ៣.៣.១ ៖ គុណវុឌ្ឍិនិងបទពិសោធន៍របស់គ្រូបង្រៀនពេញម៉ោង និងវេលាការ ..... 23
ក្រាហ្វិក ៣.៣.២ ៖ ធនធានគ្រូបង្រៀនពេញម៉ោងនិងវេលាការ ..... 24
តារាង ៣.៤.១ ៖ ចំនួនលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធី ..... 29
តារាង ៣.៤.២ ៖ ចំនួនប្លង់មុខវិជ្ជាលម្អិត (រួមទាំងមុខវិជ្ជាជ្រើសរើស Electives) ..... 30
តារាង ៣.៤.៣ ៖ រយៈពេលសិក្សានិងចំនួនក្រេឌីតសរុប ..... 32
តារាង ៣.៤.៤ ៖ ប្រភេទនៃកម្មវិធីសិក្សា ចំនួនក្រេឌីត និងចំនួនម៉ោងសិក្សា ..... 32
តារាង ៣.៤.៥ ៖ ចំនួនលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា ..... 33
តារាង ៣.៤.៦ ៖ ការផ្ទៀងផ្ទាត់រវាងវិធីសាស្ត្រវាយតម្លៃទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា ..... 36
តារាង ៣.៤.៧ ៖ ចំនួនកម្មវិធីអប់រំបានកែលម្អ ..... 38
ក្រាហ្វិក ៣.៥.១ ៖ ស្ថិតិនិស្សិតជ្រើសរើសចូលសិក្សាតាមឆ្នាំនីមួយៗ ..... 41
ក្រាហ្វិក ៣.៥.២ ៖ គុណវុឌ្ឍិនិងបទពិសោធន៍អ្នកគ្រប់គ្រងនិងបុគ្គលិកប្រតិបត្តិសេវានិស្សិត ..... 42
តារាង ៣.៥.១ ៖ លក្ខខណ្ឌនៃការផ្តល់អាហារូបករណ៍ ..... 43
តារាង ៣.៥.២ ៖ ស្ថិតិនិស្សិតថ្មីទទួលបានការណែនាំតម្រង់ទិស ..... 43
ក្រាហ្វិក ៣.៥.៣ ៖ ស្ថិតិនិស្សិតបានចូលរួមក្នុងសកម្មភាពបន្ថែមលើការសិក្សា និងហ្វឹកហាត់ការងារ ..... 44
ក្រាហ្វិក ៣.៥.៤ ៖ អត្រានិស្សិតថ្នាក់បរិញ្ញាបត្របញ្ចប់ការសិក្សា និងបោះបង់ ..... 47
ក្រាហ្វិក ៣.៥.៥ ៖ អត្រានិស្សិតថ្នាក់បរិញ្ញាបត្ររងបញ្ចប់ការសិក្សា និងបោះបង់ ..... 48
តារាង ៣.៦.១ ៖ ការអភិវឌ្ឍបន្ទប់អនុវត្តន៍តាមរយៈគម្រោង HEIP ..... 53
តារាង ៣.៦.២ ៖ ធនធានបច្ចេកវិទ្យា និងល្បឿនអ៊ីនធឺណិតរបស់សាកលវិទ្យាល័យ ..... 54
តារាង ៣.៦.៣ ៖ ស្ថិតិបុគ្គលិកគាំទ្រនិងជួយសម្រួលផ្នែកបច្ចេកទេសទទួលបានការបណ្តុះបណ្តាល ..... 55

# រូបភាព


រូបភាព១ ៖ ស្ថានភាពបណ្ណាល័យ ........ 6
រូបភាព២ ៖ ស្ថានភាពបន្ទប់អនុវត្តកុំព្យូទ័រឯកទេស ........ 7
រូបភាព៣ ៖ ស្ថានភាពបន្ទប់អនុវត្តគណនេយ្យ ........ 7
រូបភាព៤ ៖ ស្ថានភាពបន្ទប់អនុវត្តកុំព្យូទ័រទូទៅ (បន្ទប់ធំ) ........ 7
រូបភាព៥ ៖ ស្ថានភាពបន្ទប់អនុវត្តកុំព្យូទ័រទូទៅ (បន្ទប់តូច) ........ 8
រូបភាព៦ ៖ ស្ថានភាពបន្ទប់តុលាការប្រឌិត ........ 8
រូបភាព៧ ៖ អគារសាកលវិទ្យាល័យ ........ 8
រូបភាព៨ ៖ បន្ទប់សិក្សាឆ្លាតវៃ ........ 9
រូបភាព៩ ៖ បន្ទប់ម៉ាស៊ីនបម្រើ (Server) ........ 9

# ខ្លឹមសារសង្ខេបរួម

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលបានស្នើសុំវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត តាមលិខិតលេខ ១៥៨/២៥ សកពអ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ និង ត្រូវបានចាត់តាំងឱ្យចុះវាយតម្លៃតាមលិខិតឧទ្ទេសនាមលេខ ៥៦/២៥ គ.ទ.ក ឧទន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥។ របាយការណ៍លទ្ធផលនៃការវាយតម្លៃរៀបចំឡើង ដើម្បីផ្តល់ទិន្នន័យនិងព័ត៌មានគ្រប់ជ្រុងជ្រោយនៃវិធីសាស្ត្រវាយតម្លៃ ដំណើរការវាយតម្លៃ និងលទ្ធផលវាយតម្លៃ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាស្ថិតក្នុងកម្រិតណាមួយ។

ការវាយតម្លៃនេះប្រព្រឹត្តទៅតាមវិធីសាស្ត្រ ដូចជា ការពិនិត្យរបាយការណ៍ស្វ័យវាយតម្លៃនិងឯកសារ ការសង្កេត ការសម្ភាស និងការស្ទង់មតិតាមប្រព័ន្ធអនឡាញ និង ធ្វើការវិភាគទិន្នន័យនិងព័ត៌មានបែបបរិមាណវិស័យដោយប្រើប្រាស់កម្មវិធី Google Form និង Ms. Excel សម្រាប់បង្ហាញជាតារាង ក្រាហ្វិក និងដ្យាក្រាម និង ធ្វើការវិភាគបែបគុណភាពដោយប្រើប្រាស់វិធីសាស្ត្រ រួមមាន SWOT Analysis, Stakeholder Analysis, Thematic Analysis និង Content Analysis ។

ជារួមសាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដាទាំង៩។

សាកលវិទ្យាល័យបានអនុវត្តសកម្មភាពសង្គមនិងសេវាសហគមន៍ ព្រមទាំងមានការចូលរួមបុគ្គលិកនិងគ្រូបង្រៀន។ និស្សិតភាគច្រើនបញ្ចប់ការសិក្សាមានការងារធ្វើ និង មានការងារធ្វើស្របនឹងជំនាញ ៥៤%។ សាកលវិទ្យាល័យបានបោះពុម្ពអត្ថបទស្រាវជ្រាវ និងសៀវភៅស្រាវជ្រាវច្រើនកម្រិតគ្រឹះស្ថាន និងជាតិ និងកម្រិតអន្តរជាតិមួយចំនួន។

ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំមានគុណវុឌ្ឍិ និងបទពិសោធន៍ស្របតាមតួនាទីនិងភារកិច្ច ហើយគណៈគ្រប់គ្រងនិងក្រុមប្រឹក្សាអប់រំបានប្រជុំពិភាក្សាគ្នារៀងរាល់ត្រីមាសដើម្បីពិនិត្យមើលនិងកែលម្អកម្មវិធីសិក្សា។ ក្រុមប្រឹក្សាភិបាលបានធ្វើស្វ័យវាយតម្លៃការងាររបស់ខ្លួនជាប្រចាំរៀងរាល់ឆ្នាំ និងបានប្រៀបធៀបសមិទ្ធផលការងារ។ សាកលវិទ្យាល័យបានតែងតាំងមុខតំណែងភាគច្រើននៃរចនាសម្ព័ន្ធគ្រប់គ្រង និង បានអនុវត្តភាគច្រើននៃផែនការយុទ្ធសាស្ត្រ ហើយបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស និងឆ្នាំ។

គុណវឌ្ឍិ បទពិសោធន៍ និង ជំនាញរបស់គ្រូបង្រៀនស្របតាមកម្រិតបណ្តុះបណ្តាល និង មុខវិជ្ជាបង្រៀន។ ការបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗមិនលើស២៤ម៉ោងក្នុងមួយសប្តាហ៍ និង ៣មុខវិជ្ជាក្នុងមួយឆមាស។ សាកលវិទ្យាល័យបានវាយតម្លៃគ្រូបង្រៀនរៀងរាល់ឆមាស ដោយប្រើវិធីសាស្ត្រវាយតម្លៃច្រើនយ៉ាង និង គ្រូបង្រៀនទទួលលទ្ធផលវាយតម្លៃនៅរៀងរាល់ចុងឆមាសនីមួយៗ។ សាកលវិទ្យាល័យបានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកភាគច្រើន ធៀបនឹងផែនការនិងកញ្ចប់ថវិកាដែលបានកំណត់ ព្រមទាំងបានរៀបចំគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន។ គ្រូបង្រៀនភាគច្រើនពុំទាន់ពេញចិត្តប្រាក់បៀវត្សនិងផលប្រយោជន៍នានា។ សាកលវិទ្យាល័យមានកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន។

កម្មវិធីអប់រំស្ទើរតែទាំងអស់ មានលទ្ធផលសិក្សារំពឹងទុកស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ។ ភាគច្រើននៃមុខវិជ្ជាទាំងអស់ មានប្លង់មុខវិជ្ជាលម្អិត និងលទ្ធផលសិក្សារំពឹងទុក។ គ្រឹះស្ថានបានកំណត់ចំនួនក្រេឌីតសរុបបានត្រឹមត្រូវ និងអនុវត្តស្របតាមប្រព័ន្ធក្រេឌីត។ គ្រូបង្រៀនបានប្រើវិធីសាស្ត្រច្រើនយ៉ាងក្នុងការវាយតម្លៃនិស្សិត ហើយបានផ្ទៀងផ្ទាត់រវាងលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា និង វិធីសាស្ត្រវាយតម្លៃ។ មិនតែប៉ុណ្ណោះ សាកលវិទ្យាល័យបានពិនិត្យនិងកែលម្អកម្មវិធីអប់រំស្របតាមយន្តការដែលបានកំណត់ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

សាកលវិទ្យាល័យបានអនុវត្តការជ្រើសរើសនិស្សិត និងការផ្តល់អាហារូបករណ៍ ស្របតាមគោលការណ៍ដែលបានកំណត់ ព្រមទាំងបានធ្វើការស្រាវជ្រាវលើជំនាន់និស្សិតដែលបានបញ្ចប់ការសិក្សាប្រចាំឆ្នាំ និង បានដោះស្រាយរាល់ការតវ៉ារបស់និស្សិត។ បុគ្គលិកគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិភាគច្រើនមានគុណវុឌ្ឍិស្របតាមតួនាទីភារកិច្ច។ និស្សិតភាគច្រើនពេញចិត្តលើសេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និងកម្មវិធីអប់រំសុខភាព។ និស្សិតចូលរៀនថ្មីភាគច្រើនទទួលបានការណែនាំតម្រង់ទិស។ និស្សិតមានឱកាស និងបានចូលរួមហ្វឹកហាត់ការងារបន្ថែមលើការសិក្សា។ សាកលវិទ្យាល័យបានផ្សព្វផ្សាយនិងជួយរកការងារឱ្យនិស្សិត។ និស្សិតបានចូលរួមសកម្មភាពសង្គម និងសេវាសហគមន៍ និង អត្រានិស្សិតភាគច្រើនបានបញ្ចប់ការសិក្សាតាមជំនាន់នីមួយៗ។

បណ្ណាល័យមានទំហំសមស្របតាមចំនួននិស្សិតតាមវេនសិក្សា និងមានបរិយាកាសអំណោយផល ហើយម៉ោងបើកបម្រើសេវាបណ្ណាល័យឆ្លើយតបនឹងតម្រូវការនិស្សិតនិងគ្រូបង្រៀន។ បុគ្គលិកបណ្ណាល័យភាគច្រើនបានទទួលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបណ្ណាល័យពីបណ្ណារក្ស។ និស្សិតស្ទើរតែទាំងអស់ និងគ្រូបង្រៀនភាគច្រើនទទួលបានការណែនាំតម្រង់ទិសពីការប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ។ សៀវភៅសិក្សា ឯកសារយោង និងទស្សនាវដ្តីវិទ្យាសាស្ត្រឆ្លើយតបទៅនឹងកម្មវិធីអប់រំ។ បណ្ណាល័យមានថវិកាមួយចំនួនសម្រាប់គាំទ្រសេវាបណ្ណាល័យ។

សាកលវិទ្យាល័យបានអនុវត្តតាមផែនការអភិវឌ្ឍន៍បន្ទប់អនុវត្ត ហើយបន្ទប់ពិសោធន៍ទូទៅ និងឯកទេសឆ្លើយតបនឹងតម្រូវការនៃកម្មវិធី ព្រមទាំងអនុវត្តបានភាគច្រើនតាមគោលការណ៍សុវត្ថិភាព លើសពីនេះបុគ្គលិកនៃបន្ទប់អនុវត្តន៍បានឆ្លងកាត់ការបណ្តុះបណ្តាល។

សាកលវិទ្យាល័យបានផ្តល់ធនធានបច្ចេកវិទ្យា និងអ៊ីនធឺណិតបម្រើការបង្រៀននិងសិក្សាបានភាគច្រើន ហើយបុគ្គលិកគាំទ្របច្ចេកវិទ្យាជួយសម្រួលបច្ចេកទេសតាមតម្រូវការបានភាគច្រើនផងដែរ។ និស្សិត និង គ្រូបង្រៀនភាគច្រើន ទទួលបានការបណ្តុះបណ្តាលពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា។

សាកលវិទ្យាល័យមានធនធានរូបវន្តសម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ និងសកម្មភាពផ្សេងៗ ព្រមទាំងមានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព រួមទាំងសុវត្ថិភាពចំណត និងសណ្តាប់ធ្នាប់ល្អប្រសើរ។ សាកលវិទ្យាល័យបានធ្វើការណែនាំនិងផ្សព្វផ្សាយពីការអនុវត្តសុខភាព សុវត្ថិភាព សន្តិសុខ និងបានធ្វើការវាយតម្លៃជាប្រចាំ ព្រមទាំងបានធ្វើការកែលម្អឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញ។ សាកលវិទ្យាល័យបានអនុវត្តតាមគោលការណ៍ ស្តីពីការគ្រប់គ្រង ថែរក្សាប្រព័ន្ធអេឡិចត្រូនិក ការការពារអគ្គីភ័យ និងការថតចំលង ព្រមទាំងអនុវត្តសម្រេចបាន១០០%តាមផែនការអភិវឌ្ឍធនធានរូបវន្តដែលបានកំណត់។

សាកលវិទ្យាល័យបានរៀបចំផែនការថវិកាប្រចាំឆ្នាំ ដោយមានការចូលរួមពីតំណាងគ្រប់ភាគីពាក់ព័ន្ធ និងបានអនុវត្តថវិកាប្រចាំឆ្នាំបានភាគច្រើន ព្រមទាំងបានរៀបចំរបាយការណ៍ចំណូល-ចំណាយ តារាងតុល្យការ របាយការណ៍លំហូរសាច់ប្រាក់ និង របាយការណ៍ទ្រព្យម្ចាស់ និងបានបញ្ជូនទៅក្រុមប្រឹក្សាភិបាលទាន់ពេលវេលាដែលបានកំណត់។ សាកលវិទ្យាល័យបានបើកប្រាក់បៀវត្សនិងប្រាក់ឈ្នួលរបស់គ្រូបង្រៀន និងបុគ្គលិកគ្រប់ចំនួននិងទាន់ពេលកំណត់។

សាកលវិទ្យាល័យមានគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ដែលទទួលបានបណ្តុះបណ្តាលស្តីពីស្តង់ដា និងសៀវភៅណែនាំនៃការទទួលស្គាល់គុណភាពអប់រំ ព្រមទាំងមានប្រព័ន្ធ និងយន្តការវាយតម្លៃគុណភាព ហើយបានប្រកាសឱ្យអនុវត្តដោយមានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមប្រឹក្សាភិបាល និង បានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីលើកកម្ពស់គុណភាពអប់រំជានិរន្តរ៍។ ផ្នែកធានាគុណភាពមានការិយាល័យដាច់ដោយឡែក និង បានអនុវត្តតាមផែនការថវិកាសម្រាប់គាំទ្រប្រព័ន្ធធានាគុណភាពប្រចាំឆ្នាំ។ ថ្នាក់ដឹកនាំកំពូល និងគណៈគ្រប់គ្រងបានយកចិត្តទុកដាក់ និងចូលរួមលើកិច្ចការផ្នែកធានាគុណភាពផ្ទៃក្នុង។

**ដើម្បីអនុវត្តស្តង់ដាជាតិទាំង៩ឱ្យកាន់តែល្អប្រសើរ សាកលវិទ្យាល័យត្រូវ៖**

- សិក្សាស្រាវជ្រាវពីតម្រូវការគ្រូបង្រៀន និងកែសម្រួលអត្រាប្រាក់ម៉ោងបង្រៀននិងផលប្រយោជន៍នានាសម្រាប់រក្សាគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ទាំងគ្រូបង្រៀនពេញម៉ោង និងវេលាការ
- រក្សាទុកសំណុំឯកសាររបស់គ្រូបង្រៀនឱ្យស្របតាមការណែនាំរបស់ គ.ទ.ក និង រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀន
- អនុវត្តកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន ឱ្យស្របតាមផែនការដែលបានកំណត់
- វាយតម្លៃប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សាជារៀងរាល់ឆ្នាំ និងប្រើប្រាស់លទ្ធផលវាយតម្លៃដើម្បីប្រៀបធៀបនិងកែលម្អ
- ធ្វើទំនើបកម្មបណ្ណាល័យអេឡិចត្រូនិក ឱ្យបានពេញលេញដើម្បីឱ្យនិស្សិត និងគ្រូបង្រៀនអាចទាញយកឯកសារផ្សេងៗពីចម្ងាយសម្រាប់សិក្សាស្រាវជ្រាវ
- រៀបចំគោលការណ៍ ស្តីពីការធ្វើសវនកម្មផ្ទៃក្នុង និងអនុវត្តតាមគោលការណ៍ដែលបានកំណត់ និង/ឬធ្វើសវនកម្មពីខាងក្រៅ
- ពង្រឹងប្រព័ន្ធវាយតម្លៃគុណផលអ្នកទទួលបន្ទុក IQA ទាំងអស់តាមរយៈការកំណត់សូចនាករវាស់វែងលទ្ធផលសមស្រប និងអនុវត្តការវាយតម្លៃប្រចាំឆ្នាំ។

**ដើម្បីអនុវត្តស្តង់ដាជាតិទាំង៩ឱ្យកាន់តែល្អប្រសើរថែមទៀត សាកលវិទ្យាល័យគប្បី៖**

- សិក្សាស្រាវជ្រាវបន្ថែមអំពីតម្រូវការភាគីពាក់ព័ន្ធ ដោយដេប៉ាតឺម៉ង់ជំនាញនីមួយៗ ដើម្បីកែលម្អកម្មវិធីអប់រំឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ
- រៀបចំទស្សនាវដ្តីស្រាវជ្រាវិទ្យាសាស្ត្រជាទម្រង់ទន់ និងទម្រង់រឹង ដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវរបស់សាកលវិទ្យាល័យ

- តែងតាំងមុខតំណែងព្រឹទ្ធបុរសមហាវិទ្យាល័យពាណិជ្ជសាស្ត្រនិងទេសចរណ៍ មហាវិទ្យាល័យនីតិសាស្ត្រនិងសេដ្ឋកិច្ច សាលាក្រោយបរិញ្ញាបត្រ និង ប្រធានការិយាល័យហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រដែលបង្ហាញពីចំនួនកម្មវិធី ចង្កោមសកម្មភាព និង សូចនាករ ដែលបានអនុវត្ត និងសម្រេចបាន
- ជ្រើសរើសគ្រូបង្រៀនពេញម៉ោងបន្ថែមទៀត
- អនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកឱ្យស្របតាមផែនការ និងកញ្ចប់ថវិកាដែលបានកំណត់
- អនុវត្តគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន
- សរសេរនិងធ្វើបច្ចុប្បន្នកម្ម ប្លង់មុខវិជ្ជាលម្អិត រួមទាំងលទ្ធផលសិក្សារំពឹងទុក ឱ្យបានគ្រប់កម្មវិធីអប់រំ
- ផ្ទផ្ទងវិធីសាស្ត្រវាយតម្លៃនៃមុខវិជ្ជា ទៅនឹងលទ្ធផលសិក្សារំពឹងទុក ឱ្យបានគ្រប់មុខវិជ្ជាទាំងអស់ ក៏ដូចជាផ្ទផ្ទងវិធីសាស្ត្រវាយតម្លៃបញ្ចប់ការសិក្សា ទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃគ្រប់កម្មវិធីអប់រំ
- បង្កើនបុគ្គលិកសេវានិស្សិតពេញម៉ោងបន្ថែមទៀត ដែលមានកម្រិតគុណវុឌ្ឍិនិងបទពិសោធន៍ខ្ពស់ដើម្បីធានាស្ថិរភាពនៃការងារ និងការឆ្លើយតបទៅនឹងតម្រូវការនិស្សិត
- វាយតម្លៃពីប្រសិទ្ធភាពលើការផ្តល់សេវាសុខភាពផ្លូវចិត្ត សេវាសុខភាព និង កម្មវិធីអប់រំសុខភាពដើម្បីកែលម្អគុណភាពនៃសេវាកម្ម
- ណែនាំតម្រង់ទិសនិស្សិតថ្មីឱ្យបានទូលំទូលាយ
- រៀបចំគោលការណ៍ ស្តីពីការហ្វឹកហាត់ការងារឱ្យបានច្បាស់លាស់ឆ្លើយតបទៅនឹងតម្រូវការនៃកម្មវិធីអប់រំ
- តាមដានអំពីលទ្ធផលការងាររបស់និស្សិត ដើម្បីបន្តកែលម្អវិធានការផ្សេងៗ និងការរៀបចំផែនការអភិវឌ្ឍអាជីពនិស្សិតឱ្យបានច្បាស់លាស់
- រៀបចំផែនការក្នុងការផ្តល់សេវាសហគមន៍ និងសកម្មភាពជួយសង្គមប្រចាំឆ្នាំឱ្យបានច្បាស់លាស់
- សិក្សាអំពីមូលហេតុនៃការបោះបង់ចោលការសិក្សា ផ្ទេរចូល និងផ្ទេរចេញ ដើម្បីរៀបចំកែលម្អគោលការណ៍ ស្តីពីភាពជោគជ័យក្នុងការសិក្សា ការថែរក្សានិស្សិត និង អត្រាបញ្ចប់ការសិក្សា
- ធ្វើបច្ចុប្បន្នកម្ម និងបន្ថែមសៀវភៅសិក្សា ឯកសារយោង ជាពិសេសទស្សនាវដ្តីវិទ្យាសាស្ត្រថ្មីៗទាំងឯកសាររឹង និងទន់ ( Hard and Soft Copy )
- បំប៉នសមត្ថភាពបុគ្គលិកក្នុងការគ្រប់គ្រងបណ្ណាល័យ និង ណែនាំតម្រង់ទិសគ្រូបង្រៀនអំពីការប្រើប្រាស់បណ្ណាល័យ និងធនធានធានសិក្សាផ្សេងៗ
- បំប៉នសមត្ថភាពបុគ្គលិកទទួលបន្ទុកបន្ទប់អនុវត្តន៍ឱ្យឆ្លើយតបទៅនឹងតម្រូវការនិស្សិត និងការអនុវត្តគោលការណ៍សុវត្ថិភាពនៃបន្ទប់អនុវត្តន៍នីមួយៗ
- បង្កើនការគាំទ្រធនធានបច្ចេកវិទ្យានិងអ៊ីនធឺណិតឱ្យឆ្លើយតបទៅនឹងតម្រូវការបង្រៀននិងរៀន

- បំប៉នសមត្ថភាពនិស្សិតនិងគ្រូបង្រៀនអំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា និងជំរុញបុគ្គលិកគាំទ្របច្ចេកទេសជួយសម្រួលបច្ចេកទេសឱ្យឆ្លើយតបតាមតម្រូវការ
- ពិនិត្យនិងកែលម្អគម្រោងថវិកាប្រចាំឆ្នាំដែលអាចអនុវត្តបាន
- បង្កើតប្រព័ន្ធតាមដានលទ្ធផល ដើម្បីវាស់វែងផលប៉ះពាល់នៃសកម្មភាពកែលម្អ និងផ្តល់ទិន្នន័យសម្រាប់ការសម្រេចចិត្ត
- បញ្ជ្រាបការយល់ដឹងដល់គ្រូបង្រៀននិងនិស្សិត អំពីការធានាគុណភាពអប់រំផ្ទៃក្នុង និង ជំរុញឱ្យមានការចូលរួម។

# ១. សេចក្តីផ្តើម

## ១.១. សាវតារបស់គ្រឹះស្ថានឧត្តមសិក្សា

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (Phnom Penh International University) ជាគ្រឹះស្ថានឧត្តមសិក្សាឯកជនបានការទទួលស្គាល់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាយោងតាមអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦។ សាកលវិទ្យាល័យមានទីតាំងស្ថិតនៅអាគារលេខ៣៦ ផ្លូវ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា ភ្នំពេញ កម្ពុជា និង មានអាស័យដ្ឋានទំនាក់ទំនង និងពិនិត្យមើលព័ត៌មានផ្សេងៗ តាមរយៈ លេខទូរស័ព្ទ (៨៥៥) ២៣ ៩៩៩ ៩០៧ និង (៨៥៥) ១១ ៩៨៦ ៥៦៧ អ៊ីម៉ែល: info@ppiu.edu.kh គេហទំព័រ: www.ppiu.edu.kh ។

### ១.១.១ ចក្ខុវិស័យ បេសកកម្ម និងគោលបំណង

សាកលវិទ្យាល័យបានកំណត់ចក្ខុវិស័យ បេសកកម្ម និង គោលបំណង ដូចខាងក្រោម។

**ចក្ខុវិស័យ**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (ស.ភ.ព.អ) អនុលោមតាមគុណភាពអប់រំស្តង់ដាជាតិ និងអន្តរជាតិ ដោយឈរលើការអប់រំឌីជីថល និងការស្រាវជ្រាវជាគោល។

**បេសកកម្ម**

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ សម្រេចបានការផ្តល់នូវចំណេះដឹង និងជំនាញ ដោយបញ្ច្រាបនូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការស្រាវជ្រាវដើម្បីចូលរួមចំណែកការអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ និងសីលធម៌ខ្ពស់ឆ្លើយតបទីផ្សារការងារ។

**គោលបំណង**

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មខាងលើ ស.ភ.ព.អ នឹង៖

១. ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាដោយបញ្ច្រាបបច្ចេកវិទ្យាឌីជីថល និងការស្រាវជ្រាវ
២. បង្កើនទំនាក់ទំនងជាមួយស្ថាប័ន សហគ្រាស អង្គការជាតិ អន្តរជាតិនិងគ្រឹះស្ថានសិក្សាទាំងក្នុង និងក្រៅប្រទេស
៣. ពង្រឹងសមត្ថភាពបុគ្គលិកអប់រំ និងនិស្សិតរួមទាំងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល
៤. ថែរក្សា និងបន្តវប្បធម៌ការងារជាក្រុម
៥. បន្តថែរក្សាវប្បធម៌ស្រាវជ្រាវ និងធានាគុណភាព
៦. ធ្វើឱ្យប្រសើរឡើងសេវាបច្ចេកវិទ្យាព័ត៌មានវិទ្យា
៧. កែលម្អជាប្រចាំសេវាកម្មគាំទ្រការសិក្សា និងកិច្ចការរដ្ឋបាល
៨. ពង្រឹងអភិបាលកិច្ចល្អ និងហេដ្ឋារចនាសម្ព័ន្ធ
៩. បន្តរក្សាកិត្តិនាមសាកលវិទ្យាល័យ។

*តារាង ១.១ ៖ ការបន្សើគ្នារវាងចក្ខុវិស័យ បេសកកម្ម និងគោលបំណង*

| ចក្ខុវិស័យ | បេសកកម្ម | គោលបំណង |
|---|---|---|
| - សកពអ អនុលោមតាមស្តង់ដាជាតិ និងអន្តរជាតិ ដោយឈរលើការអប់រំឌីជីថល និងការស្រាវជ្រាវជាគោល។ | - សកពអ សម្រេចបានការផ្តល់នូវចំណេះដឹង និងបញ្ញាបនូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល | - ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាដោយបញ្ជ្រាបបច្ចេកវិទ្យាឌីជីថល<br>- ពង្រឹងសមត្ថភាពបុគ្គលិកអប់រំ និងនិស្សិតរួមទាំងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល<br>- ធ្វើឱ្យប្រសើរឡើងសេវាបច្ចេកវិទ្យាព័ត៌មានវិទ្យា<br>- កែលម្អជាជាប្រចាំសេវាកម្មគាំទ្រការសិក្សានិងកិច្ចការរដ្ឋបាល<br>- ពង្រឹងអភិបាលកិច្ចល្អ និងហេដ្ឋារចនាសម្ព័ន្ធ<br>- បន្តរក្សាកិត្តិនាមសាកលវិទ្យាល័យ |
| | - ការស្រាវជ្រាវដើម្បីចូលរួមចំណែកការអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ និងសីលធម៌ខ្ពស់ឆ្លើយតបទីផ្សារការងារ។ | - ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាដោយជម្រុញការស្រាវជ្រាវ<br>- បង្កើនទំនាក់ទំនងជាមួយស្ថាប័នសហគ្រាស អង្គការជាតិ អន្តរជាតិ និងគ្រឹះស្ថានសិក្សាទាំងក្នុង និងក្រៅប្រទេស<br>- បន្តថែរក្សាវប្បធម៌ស្រាវជ្រាវ និងជានាគុណភាព។ |

យោងតាមតារាង១បង្ហាញថា ការកំណត់ចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់សាកលវិទ្យាល័យមានសង្គតិភាពនឹងគ្នា។

### ១.១.២ ស្ថានភាពបុគ្គលិកគ្រប់គ្រង

សាកលវិទ្យាល័យមានស្ថានភាពបុគ្គលិកតាមឆ្នាំនីមួយៗដូចខាងក្រោម៖

- **ឆ្នាំ២០២០** ៖ មានបុគ្គលិកសរុបចំនួន ៨៥នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន១នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១២នាក់ បរិញ្ញាបត្រចំនួន ៧១នាក់ និងទាបជាងបរិញ្ញាបត្រចំនួន ១នាក់។
- **ឆ្នាំ២០២១** ៖ មានបុគ្គលិកសរុបចំនួន ៦៩នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន៣នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១២នាក់ បរិញ្ញាបត្រចំនួន ៤៨នាក់ និងទាបជាងបរិញ្ញាបត្រចំនួន ៦នាក់។
- **ឆ្នាំ២០២២** ៖ មានបុគ្គលិកសរុបចំនួន ៦៧នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន១នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១០នាក់ និង បរិញ្ញាបត្រចំនួន ៥៦នាក់។
- **ឆ្នាំ២០២៣** ៖ មានបុគ្គលិកសរុបចំនួន ៦៦នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន១នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ៩នាក់ បរិញ្ញាបត្រចំនួន ៥៤នាក់ និងទាបជាងបរិញ្ញាបត្រចំនួន ២នាក់។

- **ឆ្នាំ២០២៤** ៖ មានបុគ្គលិកសរុបចំនួន ៧៩នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន១នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ៨នាក់ បរិញ្ញាបត្រចំនួន ៦៨នាក់ និងទាបជាងបរិញ្ញាបត្រចំនួន ២នាក់។

*ក្រាហ្វិក ១.១ ៖ ស្ថានភាពបុគ្គលិក*




ក្រាហ្វិក ១.១ បង្ហាញថា ស្ថានភាពបុគ្គលិកមានការធ្លាក់ចុះចាប់ពីឆ្នាំ២០២១ រហូតដល់ឆ្នាំ២០២៤ បើធៀបទៅនឹងឆ្នាំ២០២០។ ការធ្លាក់ចុះដូចនេះ ដោយសាកលវិទ្យាល័យបានធ្វើការវិភាគមុខងារ និងចាប់ផ្ដើមកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងមួយចំនួន។

### ១.១.៣ ស្ថានភាពគ្រូបង្រៀន

សាកលវិទ្យាល័យមានស្ថានភាពគ្រូបង្រៀនតាមឆ្នាំនីមួយៗដូចខាងក្រោម៖

- **ឆ្នាំ២០២០** ៖ មានគ្រូបង្រៀនសរុបចំនួន ១៥៧នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន ៧នាក់ (ពេញម៉ោង ៣នាក់ និង វេលាការ ៤នាក់) និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១៥០នាក់ (ពេញម៉ោង ៥១នាក់ និង វេលាការ ៩៩នាក់)។
- **ឆ្នាំ២០២១** ៖ មានគ្រូបង្រៀនសរុបចំនួន ១២៩នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន ១១នាក់ (ពេញម៉ោង ៣នាក់ និង វេលាការ ៨នាក់) និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១១៨នាក់ (ពេញម៉ោង ៣៤នាក់ និង វេលាការ ៨៤នាក់)។
- **ឆ្នាំ២០២២** ៖ មានគ្រូបង្រៀនសរុបចំនួន ១២៧នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន ៦នាក់ (ពេញម៉ោង ៥នាក់ និង វេលាការ ១នាក់) និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១២១នាក់ (ពេញម៉ោង ៣០នាក់ និង វេលាការ ៩១នាក់)។
- **ឆ្នាំ២០២៣** ៖ មានគ្រូបង្រៀនសរុបចំនួន ១១៨នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន ១៥នាក់ (ពេញម៉ោង ២នាក់ និង វេលាការ ១៣នាក់) និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១០៣នាក់ (ពេញម៉ោង ៣០នាក់ និង វេលាការ ៧៣នាក់)។

- **ឆ្នាំ២០២៤ ៖** មានគ្រូបង្រៀនសរុបចំនួន ១១៨នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន ១៥នាក់ (ពេញម៉ោង ២នាក់ និង វេលាការ ១៣នាក់) និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១០៣នាក់ (ពេញម៉ោង ៣០នាក់ និង វេលាការ ៧៣នាក់)។
- **ឆ្នាំ២០២៥ ៖** មានគ្រូបង្រៀនសរុបចំនួន ១៣០នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិតចំនួន ១៩នាក់ (ពេញម៉ោង ៤នាក់ និង វេលាការ ១៥នាក់) និង បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១០៩នាក់ (ពេញម៉ោង ១៧នាក់ និង វេលាការ ៩៤នាក់)។

*ក្រាហ្វិក ១.២ ៖ ស្ថានភាពគ្រូបង្រៀន*




ក្រាហ្វិក ១.២ បង្ហាញថា ស្ថានភាពគ្រូបង្រៀនសរុបរួមមានការធ្លាក់ចុះចាប់ពីឆ្នាំ២០២១-២០២៥ បើធៀបទៅនឹងឆ្នាំ២០២០។ ប្រសិនបើពិនិត្យមើលស្ថានភាពគ្រូបង្រៀនពេញម៉ោងវិញឃើញថា មានតិចជាងគ្រូបង្រៀនវេលាការជារៀងរាល់ឆ្នាំ នេះមានន័យថាសាកលវិទ្យាល័យពឹងផ្អែកលើគ្រូបង្រៀនវេលាការខ្លាំងជាងគ្រូបង្រៀនពេញម៉ោង ដែលការណ៍នេះគប្បីសាកលវិទ្យាល័យដាក់ចេញនូវយុទ្ធសាស្ត្របង្កើនគ្រូបង្រៀនពេញម៉ោងតាមរយៈការបំលែងគ្រូបង្រៀនវេលាការដែលមានសមត្ថភាពខ្ពស់ទៅជាគ្រូបង្រៀនពេញម៉ោង ឬការជ្រើសរើសគ្រូបង្រៀនពេញម៉ោងបន្ថែមទៀត។

### ១.១.៤ ស្ថានភាពនៃកម្មវិធីអប់រំ

សាកលវិទ្យាល័យមានស្ថានភាពកម្មវិធីអប់រំដំណើរការតាមកម្រិតបណ្តុះបណ្តាល និងឆ្នាំនីមួយៗដូចខាងក្រោម៖

- **ឆ្នាំ២០២០ ៖** មានកម្មវិធីអប់រំដំណើរការតាមកម្រិតបណ្តុះបណ្តាលសរុបចំនួន ២៣ ក្នុងនោះកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣ បរិញ្ញាបត្រចំនួន ១១ និង បរិញ្ញាបត្ររងចំនួន ៩។
- **ឆ្នាំ២០២១ ៖** មានកម្មវិធីអប់រំដំណើរការតាមកម្រិតបណ្តុះបណ្តាលសរុបចំនួន ២៣ ក្នុងនោះកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣ បរិញ្ញាបត្រចំនួន ១១ និង បរិញ្ញាបត្ររងចំនួន ៩។

- **ឆ្នាំ២០២២ ៖** មានកម្មវិធីអប់រំដំណើរការតាមកម្រិតបណ្ដុះបណ្ដាលសរុបចំនួន ២៥ ក្នុងនោះកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៥ បរិញ្ញាបត្រចំនួន ១១ និង បរិញ្ញាបត្ររងចំនួន ៩។
- **ឆ្នាំ២០២៣ ៖** មានកម្មវិធីអប់រំដំណើរការតាមកម្រិតបណ្ដុះបណ្ដាលសរុបចំនួន ២៨ ក្នុងនោះកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៥ បរិញ្ញាបត្រចំនួន ១៤ និង បរិញ្ញាបត្ររងចំនួន ៩។
- **ឆ្នាំ២០២៤ ៖** មានកម្មវិធីអប់រំដំណើរការតាមកម្រិតបណ្ដុះបណ្ដាលសរុបចំនួន ២៩ ក្នុងនោះកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៦ បរិញ្ញាបត្រចំនួន ១៤ និង បរិញ្ញាបត្ររងចំនួន ៩។

*ក្រាហ្វិក ១.៣ ៖ ស្ថានភាពកម្មវិធីអប់រំដំណើរការ*




ក្រាហ្វិក ១.៣ បង្ហាញថា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានកម្មវិធីអប់រំដំណើរការកើនឡើងពី ៣កម្មវិធី ទៅដល់៦កម្មវិធី ថ្នាក់បរិញ្ញាបត្រមានកម្មវិធីអប់រំដំណើរការកើនឡើងពី ១១កម្មវិធី ទៅដល់ ១៤កម្មវិធី និង ថ្នាក់បរិញ្ញាបត្ររងមានកម្មវិធីអប់រំរក្សាបាននូវ៩កម្មវិធីគ្រប់ៗឆ្នាំ បើពិនិត្យមើលតាំងពីឆ្នាំ២០២០ មកដល់ ឆ្នាំ ២០២៤។

### ១.១.៥ ស្ថានភាពនិស្សិត

សាកលវិទ្យាល័យមានស្ថានភាពនិស្សិតសិក្សាតាមឆ្នាំនីមួយៗដូចខាងក្រោម៖

- **ឆ្នាំ២០២០ ៖** មាននិស្សិតសិក្សាសរុបចំនួន ៥៩៤នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣៣នាក់ និង បរិញ្ញាបត្រចំនួន ៥៦១នាក់។
- **ឆ្នាំ២០២១ ៖** មាននិស្សិតសិក្សាសរុបចំនួន ១ ៣៧៥នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៥៨នាក់ បរិញ្ញាបត្រចំនួន ១ ០២៣នាក់ និង បរិញ្ញាបត្ររងចំនួន ២៩៤នាក់។
- **ឆ្នាំ២០២២ ៖** មាននិស្សិតសិក្សាសរុបចំនួន ២ ២១៩នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៩២នាក់ បរិញ្ញាបត្រចំនួន ១ ៤៨១នាក់ និង បរិញ្ញាបត្ររងចំនួន ៦៤៦នាក់។
- **ឆ្នាំ២០២៣ ៖** មាននិស្សិតសិក្សាសរុបចំនួន ៣ ១០៣នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១២១នាក់ បរិញ្ញាបត្រចំនួន ១ ៩៧៣នាក់ និង បរិញ្ញាបត្ររងចំនួន ១ ០០៩នាក់។
- **ឆ្នាំ២០២៤ ៖** មាននិស្សិតសិក្សាសរុបចំនួន ៤ ១៤៨នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១៥៨នាក់ បរិញ្ញាបត្រចំនួន ២ ៦៩៣នាក់ និង បរិញ្ញាបត្ររងចំនួន ១ ២៩៧នាក់។

*ក្រាហ្វិក ១.៤ ៖ ស្ថានភាពនិស្សិតសិក្សា*




ក្រាហ្វិក ១.៤ បង្ហាញថា ស្ថានភាពនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានការកើនឡើងពី ៣៣នាក់ ទៅដល់១៥៨នាក់ និស្សិតថ្នាក់បរិញ្ញាបត្រមានការកើនឡើងពី ៥៦១នាក់ ទៅដល់ ២ ៦៩៣នាក់ និង ថ្នាក់បរិញ្ញាបត្ររងមានការកើនឡើងពី ០នាក់ ទៅដល់ ១ ២៩៧នាក់ បើពិនិត្យមើលចាប់តាំងពីឆ្នាំ២០២០ មកដល់ ឆ្នាំ២០២៤។

### ១.១.៦ ស្ថានភាពធនធានសិក្សា

សាកលវិទ្យាល័យមានធនធានសិក្សា រួមមាន បណ្ណាល័យ បន្ទប់អនុវត្តកុំព្យូទ័រ បន្ទប់អនុវត្តគណនេយ្យ បន្ទប់តុលាការប្រឌិត និង ធនធានផ្សេងៗទៀត ។

*រូបភាព១ ៖ ស្ថានភាពបណ្ណាល័យ*



រូបភាព២ ៖ ស្ថានភាពបន្ទប់អនុវត្តកុំព្យូទ័រឯកទេស



រូបភាព៣ ៖ ស្ថានភាពបន្ទប់អនុវត្តគណនេយ្យ



រូបភាព៤ ៖ ស្ថានភាពបន្ទប់អនុវត្តកុំព្យូទ័រទូទៅ (បន្ទប់ធំ)



*រូបភាព៥ ៖ ស្ថានភាពបន្ទប់អនុវត្តកុំព្យូទ័រទូទៅ (បន្ទប់តូច)*



*រូបភាព៦ ៖ ស្ថានភាពបន្ទប់តុលាការប្រឌិត*



### ១.១.៧ ស្ថានភាពធនធានរូបវន្ត

សាកលវិទ្យាល័យមានទីតាំងស្ថិតនៅ អគារលេខ៣៦ ផ្លូវ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

*រូបភាព៧ ៖ អគារសាកលវិទ្យាល័យ*



*រូបភាព៨ ៖ បន្ទប់សិក្សាឆ្លាតវៃ*



*រូបភាព៩ ៖ បន្ទប់ម៉ាស៊ីនបម្រើ (Server)*



### ១.១.៨ ស្ថានភាពហិរញ្ញវត្ថុ

សាកលវិទ្យាល័យមានស្ថានភាពហិរញ្ញវត្ថុតាមឆ្នាំនីមួយៗដូចខាងក្រោម៖

- **ឆ្នាំ២០២០ ៖** មានចំណូលសរុបចំនួន ១ ០៣៥ ៧១៦.១៤ ដុល្លារ ចំណាយសរុបចំនួន ១ ១១៧ ៦១៤.៣៦ ដុល្លារ និង ខាតចំនួន ៨១ ៧៩៨.២២ ដុល្លារ។
- **ឆ្នាំ២០២១ ៖** មានចំណូលសរុបចំនួន ១ ០៤៨ ៦៤២.៤៨ ដុល្លារ ចំណាយសរុបចំនួន ១ ០៨៨ ៦៤៤.៨៦ ដុល្លារ និង ខាតចំនួន ៤០ ០០២.៣៨ ដុល្លារ។
- **ឆ្នាំ២០២២ ៖** មានចំណូលសរុបចំនួន ១ ២០១ ៣៤០.៣៧ ដុល្លារ ចំណាយសរុបចំនួន ១ ២២៩ ៤៧៦.៥៤ ដុល្លារ និង ខាតចំនួន ២៨ ១៣៦.១៧ ដុល្លារ។
- **ឆ្នាំ២០២៣ ៖** មានចំណូលសរុបចំនួន ១ ៩១៦ ២២៩.១៩ ដុល្លារ ចំណាយសរុបចំនួន ១ ២៤៩ ២៨៧.២៥ ដុល្លារ និង ចំណេញបានចំនួន ៦៦៦ ៩៤១.៩៤ ដុល្លារ។
- **ឆ្នាំ២០២៤ ៖** មានចំណូលសរុបចំនួន ១ ៤២៩ ៦៦៤.៥៧ ដុល្លារ ចំណាយសរុបចំនួន ១ ១៩៣ ៦៥៨.១៧ ដុល្លារ និង ចំណេញបានចំនួន ២៣៦ ០០៦.៤០ ដុល្លារ។

*ក្រាហ្វិក ១.៥ ៖ ស្ថានភាពហិរញ្ញវត្ថុ*




| | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|
| ចំណូល | 1,035,716.14 | 1,048,642.48 | 1,201,340.37 | 1,916,229.19 | 1,429,664.57 |
| ចំណាយ | 1,117,514.36 | 1,088,644.86 | 1,229,476.54 | 1,249,287.25 | 1,193,658.17 |
| ចំណេញ/ខាត | -81,798.22 | -40,002.38 | -28,136.17 | 666,941.94 | 236,006.40 |

ក្រាហ្វិក ១.៥ បង្ហាញថា ស្ថានភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យពុំសូវមានស្ថានភាពល្អនោះទេ ចាប់តាំងពីឆ្នាំ២០២០ មកដល់ឆ្នាំ២០២២ ប៉ុន្តែស្ថានភាពហិរញ្ញវត្ថុចាប់ផ្តើមមានភាពប្រសើរឡើងវិញនៅឆ្នាំ ២០២៣ និងឆ្នាំ២០២៤។

### ១.១.៩ កិច្ចសហប្រតិបត្តិការ

សាកលវិទ្យាល័យមានកិច្ចសហប្រតិបត្តិការជាមួយអង្គភាព/ស្ថាប័នជាតិ តំបន់ និងអន្តរជាតិសរុបចំនួន ៤៤ ក្នុងនោះកម្រិតជាតិសរុបចំនួន ៨ កម្រិតតំបន់ចំនួន ២១ និង កម្រិតអន្តរជាតិចំនួន ១៥។ កិច្ចសហប្រតិបត្តិការនេះធ្វើឡើងក្នុងគោលបំណង ១.ការផ្លាស់ប្តូរវប្បធម៌ ២.ការផ្លាស់ប្តូរការសិក្សា ៣.ការហាត់ការ ៤.ការកែលម្អនិងអភិវឌ្ឍកម្មវិធីសិក្សា ៥.ការស្រាវជ្រាវ និង ៦.ការបង្កើនមូលនិធិ។

*ក្រាហ្វិក ១.៦ ៖ អង្គភាព/ស្ថាប័នកិច្ចសហប្រតិបត្តិការ*



### ១.២ គោលបំណងនៃការវាយតម្លៃ

ការវាយតម្លៃនេះធ្វើឡើងក្នុងគោលបំណង ដើម្បីផ្តល់កម្រិតនៃការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា នៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ដោយប្រើស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និង សៀវភៅណែនាំ ស្តីពីការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។ លទ្ធផលវាយតម្លៃត្រូវបានប្រើប្រាស់សម្រាប់ការលើកកម្ពស់គុណភាពអប់រំ និងផ្តល់កម្រិតនៃការទទួលស្គាល់គុណភាពអប់រំ នៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ។

## ២. វិធីសាស្ត្រនិងដំណើរការនៃការវាយតម្លៃ

### ២.១ វិធីសាស្ត្រប្រមូលទិន្នន័យនិងព័ត៌មាន

#### ២.១.១ ការប្រមូលទិន្នន័យនិងព័ត៌មានដែលមានស្រាប់

ក្រុមមន្ត្រីវាយតម្លៃបានពិនិត្យឯកសារ រួមមានៈ

- របាយការណ៍ស្វ័យវាយតម្លៃរបស់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ
- គោលនយោបាយ/គោលការណ៍
- ស្ថិតិនិស្សិត គ្រូបង្រៀន សម្ភារៈ និងឧបករណ៍ផ្សេងៗ
- របាយការណ៍/កំណត់ហេតុកិច្ចប្រជុំ និង
- ឯកសារផ្សេងៗ ដូចជា ប្រវត្តិរូប សញ្ញាបត្រ បទពិសោធន៍ កាលវិភាគបង្រៀននិងរៀន និងផលធៀបគ្រូនិងនិស្សិត។ល។

#### ២.១.២ ការប្រមូលទិន្នន័យនិងព័ត៌មានបឋម

ក្រុមមន្ត្រីវាយតម្លៃបានធ្វើការប្រមូលទិន្នន័យនិងព័ត៌មានបឋម ដូចខាងក្រោមៈ

- **ការសម្ភាសៈ**
    - ✓ **ការសម្ភាសផ្ទាល់ ៖** គណៈគ្រប់គ្រងនិងបុគ្គលិកចំនួន ១៨នាក់ ស្រី ៦នាក់ និស្សិតចំនួន ៥៨នាក់ ស្រី ៣៧នាក់ និង គ្រូបង្រៀនចំនួន ៣៩នាក់ ស្រី ៣នាក់។
    - ✓ **ការសម្ភាសតាមអនឡាញ ៖** អតីតនិស្សិតចំនួន ៣៤នាក់ ស្រី ៩នាក់ និង និយោជកចំនួន ២២នាក់ ស្រី ២នាក់។
- **ការស្ទង់មតិតាមអនឡាញ ៖** បុគ្គលិកចំនួន ៦១នាក់ ស្រី ៣៦នាក់ និស្សិតចំនួន ៦៦១នាក់ ស្រី ៤០៤នាក់ អតីតនិស្សិតចំនួន ១៦៨នាក់ ស្រី ១០០នាក់ គ្រូបង្រៀនចំនួន ១០៤នាក់ ស្រី ៩នាក់ និង និយោជកចំនួន ២១នាក់ ស្រី ៣នាក់។

#### ២.១.៣ ការសង្កេត

ក្រុមមន្ត្រីវាយតម្លៃបានសង្កេតលើសកម្មភាពអនុវត្តជាក់ស្តែងតាមផ្នែកនីមួយៗ រួមមាន គុណផលជាក់ស្តែងរបស់បុគ្គលិកពាក់ព័ន្ធ ធនធានសិក្សា ធនធានរូបវន្ត សកម្មភាពគ្រូបង្រៀន សកម្មភាពនិស្សិតសិក្សា ចំណតរថយន្តនិងម៉ូតូ និង បរិវេណទាំងមូលរបស់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ។

### ២.២ ការវិភាគទិន្នន័យនិងព័ត៌មាន

ការវិភាគទិន្នន័យនិងព័ត៌មានអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោមៈ

- ការវិភាគទិន្នន័យនិងព័ត៌មានបែបបរិមាណវិស័យ ដោយប្រើប្រាស់កម្មវិធី Google Form និង Ms. Excel ហើយបង្ហាញលទ្ធផលជាតារាង ក្រាហ្វិក និងដ្យាក្រាម
- ការវិភាគទិន្ន័យនិងព័ត៌មានបែបគុណភាព ដោយប្រើប្រាស់វិធិសាស្រ្ត រួមមាន **SWOT Analysis, Stakeholder Analysis, Thematic Analysis** និង **Content Analysis**។

## ៣. លទ្ធផលវាយតម្លៃ

### ៣.១. ស្តង់ដា១៖ ចក្ខុវិស័យ បេសកកម្ម និងគោលបំណង

**របកគំហើញ**

**១. និស្សិតមានការងារធ្វើឆ្លើយតបទៅនឹងតម្រូវការការទីផ្សារការងារថ្នាក់ជាតិ តំបន់ ឬអន្តរជាតិ**

ការសិក្សាស្រាវជ្រាវនិស្សិតក្រោយបញ្ចប់ការសិក្សាធ្វើឡើងដើម្បីពិនិត្យគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងបញ្ហាប្រឈមនៅក្នុងកម្មវិធីសិក្សា ការប្រកបការងារឬអាជីវកម្មរបស់អតីតនិស្សិត កម្រិតប្រាក់ចំណូល ចំណេះដឹង ជំនាញដែលទទួលបានពីការបណ្តុះបណ្តាល និងតម្រូវការទីផ្សារការងារ។

សាកលវិទ្យាល័យបានសិក្សាស្រាវជ្រាវនិស្សិតក្រោយបញ្ចប់ការសិក្សា កម្រិតបរិញ្ញាបត្រ ចាប់ពីឆ្នាំចាប់ពីឆ្នាំ២០២២ រហូតដល់ឆ្នាំ២០២៤ លើជំនាន់ទី១៧ ជំនាន់ទី១៨ និងជំនាន់ទី១៩ និង កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ លើជំនាន់ទី១៥ ជំនាន់ទី១៦ និងជំនាន់ទី១៧ ជាលក្ខណៈវិទ្យាសាស្រ្ត។ ជាលទ្ធផលនិស្សិតបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រទទួលបានការងារនៅជំនាន់ទី១៧មានចំនួន៨៤% ជំនាន់ទី១៨មានចំនួន៨៤% និងជំនាន់ទី១៩មានចំនួន៨២% ជារួមមានការងារធ្វើជាមធ្យមប្រហែល ៨៣% ព្រមទាំងមានការងារធ្វើស្របនឹងជំនាញសម្រាប់ជំនាន់ទី១៧មានចំនួន៦៧% ជំនាន់ទី១៨មានចំនួន៣៨% និង ជំនាន់ទី១៩មានចំនួន៥៤% ជារួមមានការងារធ្វើស្របទៅនឹងជំនាញជាមធ្យមប្រហែល ៥៣%។ ចំណែកឯនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានការងារធ្វើ ១០០% ក្នុងនោះមានការងារធ្វើកម្រិតជាតិ ៩៦.៦% និងធ្វើការងារកម្រិតអន្តរជាតិ ៣.៤% (ស្ថិតិសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យ)។

តាមការរយៈការសិក្សាស្រាវជ្រាវពិនិត្យនិងផ្ទៀងផ្ទាត់បន្ថែម ដោយមានការចូលរួមពីអតីតនិស្សិត ១៦៨នាក់ ស្រី ១០០នាក់ ក្នុងនោះនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រចំនួន១៤២នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៦នាក់ ជាលទ្ធផលពិនិត្យឃើញថា និស្សិតកម្រិតបរិញ្ញាបត្រក្នុងទំហំសំណាក ១៤២នាក់ មានចំនួន ៨៦% ស្មើនឹង ១២២នាក់ ទទួលបានការងារធ្វើ និង ១៤% ពុំទាន់ទទួលបានការងារធ្វើ។ ក្នុងចំណោម ១២២នាក់ អ្នកដែលមានការងារធ្វើស្របនឹងជំនាញមានចំនួន ៥៤% និងពុំស្របនឹងជំនាញមានចំនួន ៤៦%។ ចំណែកឯនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្នុងទំហំសំណាក ២៦នាក់ មាន ១០០% ទទួលបានការងារធ្វើ ក្នុងនោះមានការងារកម្រិតជាតិ ៨២.៣% និង មានការងារធ្វើកម្រិតអន្តរជាតិ ១៧.៧% (ស្ថិតិសិក្សាស្រាវជ្រាវដើម្បីផ្ទៀងផ្ទាត់)។

ជារួមនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើចំនួន ៨៥% និង មានការងារធ្វើស្របនឹងជំនាញ ៥៤% ដូចមានបញ្ជាក់លម្អិតនៅក្នុងក្រាហ្វិក ៣.១.១។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួរសិក្សាស្រាវជ្រាវបន្ថែមអំពីតម្រូវការភាគីពាក់ព័ន្ធ ដោយដេប៉ាតឺម៉ង់ជំនាញនីមួយៗ ដើម្បីកែលម្អកម្មវិធីអប់រំឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។

*ក្រាហ្វិក ៣.១.១ ៖ ភាគរយនិស្សិតមានការងារធ្វើ និងស្របនឹងជំនាញ*




## ២. លទ្ធផលស្រាវជ្រាវឆ្លើយតបទៅនឹងបេសកម្ម និងគោលបំណង

សាកលវិទ្យាល័យបានរៀបចំគោលនយោបាយនៃការស្រាវជ្រាវវិទ្យាសាស្ត្រ សង្គម សម្រាប់ជាមគ្គុទេសក៍នៃអ្នកស្រាវជ្រាវ និងបានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ ដូចជា សាស្ត្រាចារ្យ គ្រូបង្រៀន បុគ្គលិក និស្សិត នៅតាមមហាវិទ្យាល័យ ទាំងកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។ ជាក់ស្តែងកន្លងមកសាស្ត្រាចារ្យបានស្រាវជ្រាវនិងចងក្រងសៀវភៅគោលសម្រាប់ការបង្រៀនជាភាសាជាតិចំនួន ៩៥ ចំណងជើង ក្នុងនោះវិស័យបច្ចេកវិទ្យានិងព័ត៌មានវិទ្យាចំនួន ១៣ក្បាល វិស័យធុរកិច្ចចំនួន ៤២ក្បាល និង វិស័យសង្គមសាស្ត្រ (ច្បាប់និងសេដ្ឋកិច្ច) ចំនួន ៤០ក្បាល ដែលបានការទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ សាកលវិទ្យាល័យបានចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងនានាផងដែរ ដែលក្នុងនោះបានបោះពុម្ពស្នាដៃស្រាវជ្រាវកម្រិតអន្តរជាតិក្រោមកិច្ចសហការជាមួយដៃគូបានចំនួន ១៣ក្បាលបន្ថែមទៀត។

ជារួមសាកលវិទ្យាលបានបោះពុម្ពអត្ថបទស្រាវជ្រាវ និងសៀវភៅស្រាវជ្រាវច្រើនកម្រិតគ្រឹះស្ថាន និងជាតិ និងកម្រិតអន្តរជាតិមួយចំនួន ប៉ុន្តែពុំទាន់បានរៀបចំទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រជាទម្រង់ទន់ ឬ/និងទម្រង់រឹង។ ការណ៍គប្បីសាកលវិទ្យាល័យគួររៀបចំទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រជាទម្រង់ទន់ និងទម្រង់រឹងដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវរបស់សាកលវិទ្យាល័យ។

*ក្រាហ្វិក ៣.១.២ ៖ ការបោះពុម្ពស្នាដៃលទ្ធផលស្រាវជ្រាវ*




## ៣. សកម្មភាពសង្គមឬសេវាសហគមន៍របស់សាកលវិទ្យាល័យ

សាកលវិទ្យាល័យបានចលនាយុវនិស្សិតឱ្យចូលរួមបរិច្ចាគឈាម ដើម្បីជួយជនរងគ្រោះដែលមានតម្រូវការឈាមសង្គ្រោះជីវិត និង ចូលរួមជាមួយយុវជនកាកបាទក្រហមសហភាពសហព័ន្ធយុវជនកម្ពុជា ដើម្បីផ្តល់ឱកាសដល់និស្សិតចូលរួមចំណែកនិងបរិច្ចាគតាមគ្រប់រូបភាពក្នុងសហគមន៍ និងសង្គមជាតិ។ ក្រុមការងារបានចលនាយុវជននៅមធ្យមសិក្សា ពិសេសសិស្សថ្នាក់ទី១២ ឱ្យយកចិត្តទុកដាក់និងបន្តការសិក្សានៅឧត្តមសិក្សាដើម្បីចាប់យកជំនាញវិជ្ជាជីវៈសម្រាប់អាជីពក្នុងសហគមន៍។ លើសពីនេះសាកលវិទ្យាល័យបានចូលរួមអបអរសាទរវេទិកាកីឡាអាស៊ានក្នុងកម្មវិធីបើកនិងបិទដែលមានកម្ពុជាជាម្ចាស់ផ្ទះ និង ព្រឹត្តិការណ៍កីឡាជាតិក្នុងកម្មវិធីបើកនិងបិទ តាមរយៈក្រសួងអប់រំ យុវជន និងកីឡា សហភាពសហព័ន្ធយុវជនកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សាកលវិទ្យាល័យបានត្រៀមលក្ខណសម្បត្តិ និងដាក់នៅក្នុងផែនការសកម្មភាពការចូលរួមសកម្មភាពសង្គម ដូចជា ការពារបរិស្ថានដោយចុះអនុស្សរណៈយោគយល់ជាមួយអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) និង អង្គការម្លប់បៃតង ដោយបានរៀបចំសិក្ខាសាលាស្តីពី "Basic concepts of Climate and Biodiversity"។ សកម្មភាពសង្គមនិងសេវាសហគមន៍របស់សាកលវិទ្យាល័យ រួមមាន ការចូលរួមមូលនិធិមន្ទីរពេទ្យ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការបរិច្ចាគថវិកាចុះមូលដ្ឋាន ការចែករំលែកបទពិសោធន៍ទៅកាន់សហគមន៍ ការចែកសម្ភារៈសិក្សាដល់កុមារក្នុងសហគមន៍ ការចែករំលែកពីការគ្រប់គ្រងសំរាមនិងអនាម័យបរិស្ថាន ការងារស្ម័គ្រចិត្ត ការដាំកូនឈើ សកម្មភាពទីក្រុងស្អាត ការរេចនំអន្សម កីឡាជាតិ ការចូលរួមការលើកកម្ពស់ការយល់ដឹងច្បាប់ជាតិនិងអន្តរជាតិ ការរៃអង្គាសថវិកាកសាងសាលាបណ្តែតទឹក (ខេត្តកំពង់ឆ្នាំង) ការចូលរួមថវិកាកសាងហេដ្ឋារចនាសម្ព័ន្ធព្រំដែន ការដាក់ស្លាកលេខផ្លូវ ការបរិច្ចាគថវិកាជួយកងទ័ពនិងជនភាសសឹក ការចូលរួមសម្អាតបរិស្ថាន កម្មវិធីជួយជីវិតអ្នកជំងឺ ការជួយសហគមន៍ពេលមានគ្រោះធម្មជាតិ ការបរិច្ចាគឈាម ។ល។

ទោះបីជាសាកលវិទ្យាល័យពុំមានផែនការច្បាស់លាស់ប្រចាំឆ្នាំក៏ដោយ ប៉ុន្តែនៅឆ្នាំ២០២១ អនុវត្តបាន ១៤សកម្មភាព ដែលមានសមាសភាពបុគ្គលិកគ្រប់គ្រងចូលរួមសរុបចំនួន ៣៤នាក់ និង គ្រូបង្រៀនចំនួន ៨៩នាក់។ ឆ្នាំ២០២២ អនុវត្តបាន ២២សកម្មភាព ដែលមានសមាសភាពបុគ្គលិកគ្រប់គ្រងចូលរួមសរុបចំនួន

៤៦នាក់ និង គ្រូបង្រៀនចំនួន ១៣៨នាក់។ ឆ្នាំ២០២៣ អនុវត្តបាន ១២សកម្មភាព ដែលមានសមាសភាពបុគ្គលិកគ្រប់គ្រងចូលរួមសរុបចំនួន ១៧នាក់ និង គ្រូបង្រៀនចំនួន ៥១នាក់។ ឆ្នាំ២០២៤ អនុវត្តបាន ៤០ សកម្មភាព ដែលមានសមាសភាពបុគ្គលិកគ្រប់គ្រងចូលរួមសរុបចំនួន ៥៣នាក់ និង គ្រូបង្រៀនចំនួន ១៥៣ នាក់។ ជារួមចាប់ពីឆ្នាំ២០២១ រហូតដល់ឆ្នាំ២០២៤ ជាមធ្យមសាកលវិទ្យាល័យអនុវត្តបានប្រហែលជា ២២ សកម្មភាពជាប្រចាំឆ្នាំ ដែលមានបុគ្គលិកគ្រប់គ្រងចូលរួមជាធម្យមប្រហែល៣៨នាក់ និងគ្រូបង្រៀនចូលរួមជាមធ្យមប្រហែល ១០៨នាក់។

*ក្រាហ្វិក ៣.១.៣ ៖ ស្ថិតិសកម្មភាពសង្គម/សេវាសគមន៍ និង សមាសភាពចូលរួម*




**ចំណុចខ្លាំង**

- បុគ្គលិកនិងគ្រូបង្រៀនបានចូលរួមសកម្មភាពសង្គមនិងសេវាសហគមន៍។

**ចំណុចអនុវត្តបានល្អ**

- និស្សិតភាគច្រើនបញ្ចប់ការសិក្សាមានការងារធ្វើ និង មានការងារធ្វើស្របនឹងជំនាញភាគច្រើន។
- បានបោះពុម្ពអត្ថបទស្រាវជ្រាវ និងសៀវភៅស្រាវជ្រាវច្រើនកម្រិតគ្រឹះស្ថាន និងជាតិ និងកម្រិតអន្តរជាតិមួយចំនួន ប៉ុន្តែពុំទាន់រៀបចំទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រជាទម្រង់ទន់ និង ទម្រង់រឹង។

**សេចក្ដីសន្និដ្ឋាន**

ជារួមសាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា១។ សាកលវិទ្យាល័យបានអនុវត្តសកម្មភាពសង្គមនិងសេវាសហគមន៍ស្របតាមការកំណត់ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ព្រមទាំងមានការចូលរួមបុគ្គលិកនិងគ្រូបង្រៀន។ និស្សិតភាគច្រើនបញ្ចប់ការសិក្សាមានការងារធ្វើ និង មានការងារធ្វើស្របនឹងជំនាញ ៥៤%។ សាកលវិទ្យាល័យបានបោះពុម្ពអត្ថបទស្រាវជ្រាវ និងសៀវភៅស្រាវជ្រាវច្រើនកម្រិតគ្រឹះស្ថាន និងជាតិ និងកម្រិតអន្តរជាតិមួយចំនួន ប៉ុន្តែពុំទាន់រៀបចំទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រជាទម្រង់ទន់ ឬ/និង ទម្រង់រឹង។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា១ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវ៖

- ពុំមាន។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា១ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរះ

- សិក្សាស្រាវជ្រាវបន្ថែមអំពីតម្រូវការភាគីពាក់ព័ន្ធ ដោយដេប៉ាតឺម៉ង់ជំនាញនីមួយៗ ដើម្បីកែលម្អកម្មវិធីអប់រំឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ
- រៀបចំទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រជាទម្រង់ទន់ និងទម្រង់រឹង ដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវរបស់សាកលវិទ្យាល័យ។

## ៣.២. ស្តង់ដា២៖ អភិបាលកិច្ច និងការគ្រប់គ្រង

### របកគំហើញ

### ១. រចនាសម្ព័ន្ធនៃអភិបាលកិច្ចនិងការគ្រប់គ្រង

សាកលវិទ្យាល័យបានរៀបចំតែងតាំងទៅតាមមុខតំណែងនៃរចនាសម្ព័ន្ធគ្រប់គ្រង រួមមាន សាកលវិទ្យាធិការ១រូប សាកលវិទ្យាធិការរង៣រូប ព្រឹទ្ធបុរស២រូប អ្នកសម្របសម្រួលកម្មវិធីក្រោយកម្រិតបរិញ្ញាបត្រ១រូប ព្រឹទ្ធបុរសរង៣រូប ប្រធានការិយាល័យ៥រូប ប្រធានដេប៉ាតឺម៉ង់៣រូប និង ប្រធានការិយាល័យ១រូប។ សាកលវិទ្យាល័យបានតែងតាំងមុខតំណែងភាគច្រើននៃរចនាសម្ព័ន្ធគ្រប់គ្រង និងស្របតាមអនុក្រឹត្យ ស្តីពីការបង្កើតសាកលវិទ្យាល័យ និងអនុវត្តស្របតាមអនុក្រឹត្យនៃការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ ប៉ុន្តែពុំទាន់បានតែងតាំងមុខតំណែងអ្នកទទួលបន្ទុករួម មហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងទេសចរណ៍មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច សាលាក្រោយបរិញ្ញាបត្រ និង ការិយាល័យហិរញ្ញវត្ថុ។ ភាពខ្វះខាតនេះអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងការសម្របសម្រួលសកម្មភាពរវាងមហាវិទ្យាល័យ។ ការមានរចនាសម្ព័ន្ធច្បាស់លាស់ជួយបង្កើនភាពទទួលខុសត្រូវ និងប្រសិទ្ធភាពក្នុងការអនុវត្តបេសកកម្ម។ ទោះជាយ៉ាងណា ការអវត្តមានមុខតំណែងសំខាន់ៗមួយចំនួន បង្ហាញថា សាកលវិទ្យាល័យត្រូវការការពង្រឹងលទ្ធភាពអនុវត្តផែនការក្នុងការគ្រប់គ្រងធនធានមនុស្ស និងភាពជាប់ទាក់ទងគ្នាជាអន្តរមហាវិទ្យាល័យ។ ភាពខ្វះខាតនៃមុខតំណែងដូចបានរៀបរាប់ខាងលើ គប្បីសាកលវិទ្យាល័យគួរតែងតាំងមុខតំណែងព្រឹទ្ធបុរសមហាវិទ្យាល័យពាណិជ្ជសាស្ត្រនិងទេសចរណ៍ មហាវិទ្យាល័យនីតិសាស្ត្រនិងសេដ្ឋកិច្ច សាលាក្រោយបរិញ្ញាបត្រ និង ប្រធានការិយាល័យហិរញ្ញវត្ថុ។

*ក្រាហ្វិក ៣.២.១ ៖ ស្ថិតិបុគ្គលិកបានតែងតាមរចនាសម្ព័ន្ធគ្រប់គ្រង*



## ២. សមិទ្ធិផលការងាររបស់ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាប្រតិបត្តិ និងក្រុមប្រឹក្សាអប់រំឆ្លើយតបទៅនឹងតួនាទីភារកិច្ច

### ក. ក្រុមប្រឹក្សាភិបាល

សាកលវិទ្យាល័យ បានបង្កើតក្រុមប្រឹក្សាភិបាល ដោយមានសមាជិក៥នាក់ និង មានអណត្តិបីឆ្នាំ ដែលជាថ្នាក់ដឹកនាំខ្ពស់បំផុត ដើម្បីតម្រង់ទិសការអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងារ ស.ភ.ព.អ ស្របតាមលក្ខខន្តិកៈក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០១៧។ ក្រុមប្រឹក្សាភិបាលមានភារៈពិនិត្យ និងអនុម័តគម្រោងផែនការ ឬ ថវិការយៈពេលវែង ខ្លី មធ្យម ដែលដាក់ជូនដោយគណៈគ្រប់គ្រង ហើយបានប្រជុំពិនិត្យលទ្ធផលប្រតិបត្តិរបស់គណៈគ្រប់គ្រង ស្របតាមកាលបរិច្ឆេទដែលបានកំណត់និងគ្រោងទុក។ ទោះបីជាការប្រជុំត្រូវបានអនុវត្តតាមកាលវិភាគកំណត់ក៏ដោយ ការចេញរបាយការណ៍លទ្ធផលប្រចាំអាណត្តិ ឬរបាយការណ៍សង្ខេបប្រចាំឆ្នាំនៅតែមិនទាន់មានលក្ខណៈជាប្រព័ន្ធនោះទេ ខណៈដែលការមានប្រព័ន្ធប្រឹក្សាភិបាលត្រឹមត្រូវជួយធានាថាការសម្រេចចិត្តមានភាពតម្លាភាព និងមានការចូលរួមពីភាគីពាក់ព័ន្ធ។

*តារាង ៣.២.១ ៖ សមិទ្ធផលការងារក្រុមប្រឹក្សាភិបាល*

| តួនាទីភារកិច្ច | សមិទ្ធផលការងារ៥ឆ្នាំ |
|---|---|
| - ពិនិត្យ និងអនុម័តគម្រោងផែនការ ឬថវិការយៈពេលវែង ខ្លី ឬមធ្យម<br>- ប្រជុំរៀងរាល់ឆមាស ពិនិត្យមើលរបាយការណ៍។ | - លទ្ធផលការអនុវត្តផែនការយុទ្ធសាស្ត្រ<br>- ពិនិត្យផែនការសកម្មភាព<br>- ប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ<br>- អនុសាសន៍ក្រុមប្រឹក្សាភិបាល |

### ខ. គណៈគ្រប់គ្រង

សាកលវិទ្យាល័យបានរៀបចំគណៈគ្រប់គ្រង ដែលដើរតួនាទីជាក្រុមប្រឹក្សាប្រតិបត្តិ ដោយមានសមាសភាពពីគណៈគ្រប់គ្រងជាន់ខ្ពស់ (សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង) និង គ្រប់គណៈគ្រប់គ្រងដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពសំខាន់ៗ ដូចជា ការបង្រៀននិងរៀន ការស្រាវជ្រាវ សេវាសង្គម និង សេវាគាំទ្រនានានៅសាកលវិទ្យាល័យ។

*តារាង ៣.២.២ ៖ សមិទ្ធផលការងារគណៈគ្រប់គ្រង*

| តួនាទីភារកិច្ច | សមិទ្ធផលការងារ៥ឆ្នាំ |
|---|---|
| - ពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រង<br>- រៀបចំពិនិត្យ និងតាមដានការអនុវត្តគោលការណ៍ បទបញ្ញត្តិ និងលិខិតបទដ្ឋាន<br>- កែលម្អ និងធ្វើវិសោធនកម្មលិខិតបទដ្ឋានរបស់សាកលវិទ្យាល័យ | - ផែនការយុទ្ធសាស្ត្រ ២០២០-២០២៥<br>- បញ្ញត្តិនិស្សិត សាស្ត្រាចារ្យ បុគ្គលិក<br>- គោលការណ៍សម្រាប់អនុវត្ត និងគ្រប់គ្រងប្រព័ន្ធក្រេឌីត<br>- គោលការណ៍ដំឡើងឋានៈគ្រូ<br>- គោលការណ៍ស្រាវជ្រាវ<br>- គ្រប់ជំនាញ និងគ្រប់កម្រិតអនុវត្តប្រព័ន្ធក្រេឌីត<br>- ការិយាល័យធានាគុណភាពអប់រំផ្ទៃក្នុង សហការជាមួយភាគីពាក់ព័ន្ធនៃសាកលវិទ្យាល័យ |

| តួនាទីភារកិច្ច | សមិទ្ធផលការងារ៥ឆ្នាំ |
|---|---|
| | ដើម្បីអនុវត្តនូវគោលនយោបាយកិច្ចធានាគុណភាពអប់រំផ្ទៃក្នុង<br>- កសាងបន្ថែមបន្ទប់ពិសោធន៍ ៣ ដែលមានកុំព្យូទ័រ ១០៣ គ្រឿង និងធ្វើបច្ចុប្បន្នភាពសូហ្វវែរ។ |

**គ. ក្រុមប្រឹក្សាអប់រំ**

ក្រុមប្រឹក្សាអប់រំមានសមាសភាព៥រូប (សាកលវិទ្យាធិការជាប្រធាន សាកលវិទ្យាធិការរង៣រូបជាអនុប្រធាន និង នាយកសាលាក្រោយបរិញ្ញាបត្រ និងមហាវិទ្យាល័យ ជាសាមាជិក) ដើម្បីរៀបចំអភិវឌ្ឍកម្មវិធីសិក្សាថ្មីស្របទៅនឹងនិន្នាការផ្លាស់ប្តូរនៃទីផ្សារការងារដ៏ឆាប់រហ័សនាពេលបច្ចុប្បន្ន និងអនាគត។

*តារាង ៣.២.៣ ៖ សមិទ្ធផលការងារក្រុមប្រឹក្សាអប់រំ*

| តួនាទីភារកិច្ច | សមិទ្ធផលការងារ៥ឆ្នាំ |
|---|---|
| - កែលម្អកម្មវិធីសិក្សាទៅជាប្រព័ន្ធក្រេឌីត (ណែនាំ និងសហការជាមួយមហាវិទ្យាល័យ)<br>- អភិវឌ្ឍកម្មវិធីសិក្សាថ្មី (ណែនាំ និងសហការជាមួយមហាវិទ្យាល័យ)<br>- កែលម្អកម្មវិធីសិក្សា (ណែនាំ និងសហការជាមួយមហាវិទ្យាល័យ) តាមបរិបទនៃសេដ្ឋកិច្ច និងបច្ចេកវិទ្យាឌីជីថល<br>- រៀបចំរបាយការណ៍ស្នើទៅក្រុមប្រឹក្សាភិបាល<br>- ត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា | - កែលម្អកម្មវិធីសិក្សាទៅជាប្រព័ន្ធក្រេឌីត (ណែនាំ និងសហការជាមួយមហាវិទ្យាល័យ) កម្មវិធីសិក្សាលើគ្រប់ជំនាញ និងកម្រិតសិក្សាបានត្រូវអនុវត្តតាមប្រព័ន្ធក្រេឌីត<br>- អភិវឌ្ឍកម្មវិធីសិក្សាថ្មី (ណែនាំ និងសហការជាមួយមហាវិទ្យាល័យ) ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ<br>- ជំនាញរដ្ឋបាលសាធារណៈ<br>- ជំនាញភាសាអង់គ្លេសសម្រាប់ធុរកិច្ច<br>- កែលម្អកម្មវិធីសិក្សា (ណែនាំ និងសហការជាមួយមហាវិទ្យាល័យ) តាមបរិបទនៃសេដ្ឋកិច្ច និងបច្ចេកវិទ្យាឌីជីថល ២០-៣០% នៃគ្រប់ជំនាញតាមវគ្គសិក្សានីមួយៗ<br>- រៀបចំរបាយការណ៍ស្នើទៅក្រុមប្រឹក្សាភិបាលស្នើសុំសេចក្តីសម្រេច<br>- ត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សាវាយតម្លៃគ្រូ (ចូលរួមពីនិស្សិត)<br>- សមាជិកក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាប្រតិបត្តិ និងក្រុមប្រឹក្សាអប់រំ |

ជារួមក្រុមប្រឹក្សាភិបាលបានអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងារស្របតាមលក្ខខន្តិកៈ ហើយគណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំបានប្រជុំពិភាក្សាគ្នារៀងរាល់ត្រីមាស ដើម្បីពិនិត្យមើល និងកែលម្អកម្មវិធីសិក្សា។

## ៣. សមាជិកក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាប្រតិបត្តិ និងក្រុមប្រឹក្សាអប់រំ មានគុណវុឌ្ឍិ និងជំនាញស្របតាមតួនាទីភារកិច្ច

ក្រុមប្រឹក្សាភិបាលមានសមាសភាពសរុបចំនួន៥រូប ក្នុងនោះមានសញ្ញាបត្របណ្ឌិត១រូប បរិញ្ញាបត្រជាន់ខ្ពស់២រូប បរិញ្ញាបត្រ១រូប និងទាបជាងបរិញ្ញាបត្រ១រូប។ គណៈគ្រប់គ្រងមានសមាសភាពសរុបចំនួន ១៣នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិត២រូប បរិញ្ញាបត្រជាន់ខ្ពស់៩រូប និងបរិញ្ញាបត្រ២រូប។ ក្រុមប្រឹក្សាអប់រំមានសមាសភាពសរុបចំនួន ៨នាក់ ក្នុងនោះមានសញ្ញាបត្របណ្ឌិត២រូប និងបរិញ្ញាបត្រជាន់ខ្ពស់៦រូប ដូចមានបញ្ជាក់លម្អិតនៅក្នុងក្រាហ្វិក ៣.២.២។

*ក្រាហ្វិក ៣.២.២ ៖ គុណវុឌ្ឍិរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំ*




ក្រុមប្រឹក្សាភិបាលមានសមាសភាពសរុបចំនួន៥រូប មានបទពិសោធន៍លើសពី១០ឆ្នាំ។ គណៈគ្រប់គ្រង មានបទពិសោធន៍ទាបជាង៣ឆ្នាំ២រូប ៣-៥ឆ្នាំចំនួន២រូប ៦-១០ឆ្នាំចំនួន២រូប និងលើសពី១០ឆ្នាំចំនួន៧រូប។ ក្រុមប្រឹក្សាអប់រំ មានបទពិសោធន៍ទាបជាង៣ឆ្នាំ១រូប ៣-៥ឆ្នាំចំនួន១រូប ៦-១០ឆ្នាំចំនួន១រូប និងលើសពី១០ឆ្នាំចំនួន៥រូប ដូចមានបញ្ជាក់លម្អិតនៅក្នុងក្រាហ្វិក ៣.២.៣។

តាមលទ្ធផលនៃការអនុវត្តត្រង់ចំណុចទី២នៃស្តង់ដា២នេះ និង គុណវុឌ្ឍិនិងបទពិសោធន៍ខាងលើបញ្ជាក់បានថា ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំមានគុណវុឌ្ឍិ និងបទពិសោធន៍ស្របតាមតួនាទីនិងភារកិច្ច និងលក្ខខន្តិកៈ ហើយបានអនុវត្តស្របតាមគោលការណ៍របស់សាកលវិទ្យាល័យ។

*ក្រាហ្វិក ៣.២.៣ ៖ បទពិសោធន៍របស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាប្រតិបត្តិ*




### ៤. សង្គតិភាពរវាងផែនការអភិវឌ្ឍន៍ជាមួយនឹងចក្ខុវិស័យ បេសកកម្ម និង គោលបំណង

សាកលវិទ្យាល័យបានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០២០-២០២៥) ស្របទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលអណត្តិទី៧ ដោយមានការចូលរួមពីគ្រប់មហាវិទ្យាល័យ និងការិយាល័យពាក់ព័ន្ធ ហើយបានវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ដោយអនុវត្តបានភាគច្រើននៃផែនការយុទ្ធសាស្ត្រ ព្រមទាំងបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស និងឆ្នាំ ប៉ុន្តែពុំមានរបាយការណ៍ពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ដែលបង្ហាញពីចំនួនកម្មវិធី ចង្កោមសកម្មភាព និង សូចនាករ ដែលបានអនុវត្ត និងសម្រេចបាន។ ការគ្រប់គ្រងផែនការយុទ្ធសាស្ត្រត្រូវការបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃសមស្រប ដើម្បីធានាថាការអនុវត្តអាចវាស់វែង និងទទួលខុសត្រូវបាន។ ការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ និងបញ្ចប់ផែនការយុទ្ធសាស្ត្រអាចជាកត្តាសំខាន់ក្នុងការបង្ហាញភាពទទួលខុសត្រូវ និងស្ថេរភាពនៃការអភិវឌ្ឍសាកលវិទ្យាល័យប្រកបដោយនិរន្តរភាព។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួររៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រដែលបង្ហាញពីចំនួនកម្មវិធី ចង្កោមសកម្មភាព និងសូចនាករដែលបានអនុវត្ត និងសម្រេចបាន។

### ៥. ការវាយតម្លៃប្រសិទ្ធភាពការងារនៃក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានធ្វើស្វ័យវាយតម្លៃការងាររបស់ខ្លួនជាប្រចាំរៀងរាល់ឆ្នាំ តាមរយៈការកំណត់ពេលវេលាប្រជុំច្បាស់លាស់ និងបានប្រៀបធៀបសមិទ្ធផលការងារក្នុងរយៈពេលប្រាំឆ្នាំ។ តាមលទ្ធផលវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល សាកលវិទ្យាល័យបានសម្រេចនូវការបញ្ចូលបច្ចេកវិទ្យាថ្មីៗក្នុងការបណ្តុះបណ្តាល ការពិនិត្យនិងកែលម្អកម្មវិធីសិក្សាឱ្យស្របនឹងយុទ្ធសាស្ត្របញ្ចកោណរបស់រដ្ឋាភិបាល ការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និង ការស្នើសុំឱ្យមានការធ្វើសវនកម្មពីខាងក្រៅ។

*តារាង ៣.២.៤ ៖ លទ្ធផលនៃការវាយតម្លៃប្រសិទ្ធភាពការងារក្រុមប្រឹក្សាភិបាល*

| ល.រ | បរិយាយ | ភាគរយអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | 2020 | 2021 | 2022 | 2023 | 2024 |
| ១ | ការចូលរួមកិច្ចប្រជុំ | 80% | 90% | 96% | 96% | 96% |
| ២ | ការសម្រេចចិត្តដោយផ្អែកលើមូលដ្ឋានទិន្នន័យនិងព័ត៌មាន | 85% | 95% | 98% | 98% | 98% |
| ៣ | ប្រសិទ្ធភាពនៃការដឹកនាំនិងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រ | 90% | 96% | 97% | 98% | 98% |
| ៤ | ប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ | 98% | 99% | 99% | 99% | 99% |
| ៥ | ការកែលម្អគុណភាពសិក្សា | 90% | 96% | 98% | 98% | 98% |

តារាង ៣.២.៤ បង្ហាញថា ចាប់តាំងពីឆ្នាំ២០២០ រហូតដល់ ២០២៤ ឃើញថា ភាគរយនៃការចូលរួមប្រជុំមានការកើនឡើងពី ៨០%-៩៨% ការសម្រេចចិត្តដោយផ្អែកលើមូលដ្ឋានទិន្នន័យនិងព័ត៌មានកើនឡើងពី ៨៥%-៩៨% ប្រសិទ្ធភាពនៃការដឹកនាំនិងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រកើនឡើងពី ៩០%-៩៨% ប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុកើនពី ៩៨%-៩៩% និង ការកែលម្អគុណភាពសិក្សាកើនឡើងពី ៩០%-៩៨%។ ជារួម ក្រុមប្រឹក្សាភិបាលបានធ្វើស្វ័យវាយតម្លៃការងាររបស់ខ្លួនជាប្រចាំរៀងរាល់ឆ្នាំ តាមរយៈការកំណត់ពេលវេលាប្រជុំច្បាស់លាស់ និងបានប្រៀបធៀបសមិទ្ធផលការងារក្នុងរយៈពេលប្រាំឆ្នាំ។

**ចំណុចខ្លាំង**

- ក្រុមប្រឹក្សាភិបាលបានអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងារស្របតាមលក្ខខន្តិកៈ ហើយគណៈគ្រប់គ្រងនិងក្រុមប្រឹក្សាអប់រំបានប្រជុំពិភាក្សាគ្នារៀងរាល់ត្រីមាសដើម្បីពិនិត្យមើល និងកែលម្អកម្មវិធីសិក្សា
- ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំមានគុណវុឌ្ឍិ និងបទពិសោធន៍ស្របតាមតួនាទីនិងភារកិច្ច និងលក្ខខន្តិកៈ ហើយបានអនុវត្តស្របតាមគោលការណ៍របស់សាកលវិទ្យាល័យ
- ក្រុមប្រឹក្សាភិបាលបានធ្វើស្វ័យវាយតម្លៃការងាររបស់ខ្លួនជាប្រចាំរៀងរាល់ឆ្នាំ តាមរយៈការកំណត់ពេលវេលាប្រជុំច្បាស់លាស់ និងបានប្រៀបធៀបសមិទ្ធផលការងារក្នុងរយៈពេលប្រាំឆ្នាំ។

**ចំណុចអនុវត្តបានល្អ**

- បានតែងតាំងមុខតំណែងភាគច្រើននៃរចនាសម្ព័ន្ធគ្រប់គ្រង និងអនុវត្តស្របតាមអនុក្រឹត្យនៃការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ ប៉ុន្តែពុំទាន់បានតែងតាំងមុខតំណែងព្រឹទ្ធបុរសមហាមហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងទេសចរណ៍, មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច សាលាក្រោយបរិញ្ញាបត្រ និង ប្រធានការិយាល័យហិរញ្ញវត្ថុ
- បានអនុវត្តភាគច្រើននៃផែនការយុទ្ធសាស្ត្រ ហើយបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស និងឆ្នាំ ប៉ុន្តែពុំមានរបាយការណ៍ពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ដែលបង្ហាញពីចំនួនចំនួនចង្អោមកម្មវិធី និង សូចនាករ ដែលបានអនុវត្តនិងសម្រេចបាន។

**សេចក្តីសន្និដ្ឋាន**

ជារួម សាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា២។ ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំមានគុណវុឌ្ឍិ និងបទពិសោធន៍ស្របតាមតួនាទីនិងភារកិច្ច ហើយបាន អនុវត្ត និងត្រួតពិនិត្យសកម្មភាពការងារស្របតាមលក្ខខន្តិកៈ ហើយគណៈគ្រប់គ្រងនិងក្រុមប្រឹក្សាអប់រំបាន ប្រជុំពិភាក្សាគ្នារៀងរាល់ត្រីមាសដើម្បីពិនិត្យមើល និងកែលម្អកម្មវិធីសិក្សា។ ក្រុមប្រឹក្សាភិបាលបានធ្វើស្វ័យ វាយតម្លៃការងាររបស់ខ្លួនជាប្រចាំរៀងរាល់ឆ្នាំ តាមរយៈការកំណត់ពេលវេលាប្រជុំច្បាស់លាស់ និងបានប្រៀប ធៀបសមិទ្ធផលការងារក្នុងរយៈពេលប្រាំឆ្នាំ។ សាកលវិទ្យាល័យបានតែងតាំងមុខតំណែងភាគច្រើននៃរចនា សម្ព័ន្ធគ្រប់គ្រង និងអនុវត្តស្របតាមអនុក្រឹត្យនៃការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ ប៉ុន្តែពុំទាន់បានតែងតាំង មុខតំណែងព្រឹទ្ធបុរសមហាមហាវិទ្យាល័យពាណិជ្ជសាស្ត្រនិងទេសចរណ៍ មហាវិទ្យាល័យនីតិសាស្ត្រនិងសេដ្ឋកិច្ច សាលាក្រោយបរិញ្ញាបត្រ និង ប្រធានការិយាល័យហិរញ្ញវត្ថុ។ សាកលវិទ្យាល័យបានអនុវត្តភាគច្រើននៃ ផែនការយុទ្ធសាស្ត្រ ហើយបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស និងឆ្នាំ ប៉ុន្តែពុំមានរបាយ ការណ៍ពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ដែលបង្ហាញពីចំនួនកម្មវិធី ចង្កោមសកម្មភាព និង សូចនាករ ដែលបានអនុវត្តនិងសម្រេចបាន។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា២ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវ៖

- ពុំមាន។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា២ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរ៖

- តែងតាំងមុខតំណែងព្រឹទ្ធបុរសមហាវិទ្យាល័យពាណិជ្ជសាស្ត្រនិងទេសចរណ៍ មហាវិទ្យាល័យ នីតិសាស្ត្រនិងសេដ្ឋកិច្ច សាលាក្រោយបរិញ្ញាបត្រ និង ប្រធានការិយាល័យហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការ យុទ្ធសាស្ត្រដែលបង្ហាញពីចំនួនកម្មវិធី ចង្កោមសកម្មភាព និង សូចនាករ ដែលបានអនុវត្ត និង សម្រេចបាន។

## ៣.៣. ស្តង់ដា៣៖ បុគ្គលិកអប់រំ

**របកគំហើញ**

### ១. គុណវុឌ្ឍិនិងបទពិសោធន៍គ្រូបង្រៀន

ឆ្នាំសិក្សា ២០២៤-២០២៥ សាកលវិទ្យាល័យមានគ្រូបង្រៀនសរុបចំនួន ១៣០នាក់ ក្នុងនោះមានគ្រូ បង្រៀនដែលមានគុណវុឌ្ឍិបណ្ឌិតនិងមានបទពិសោធន៍ទាបជាង៣ឆ្នាំមានចំនួន ៣នាក់ ៣-៥ឆ្នាំ ចំនួន២ នាក់ និង លើសពី១០ឆ្នាំ ចំនួន ១៤នាក់ ព្រមទាំងមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់និង មានបទពិសោធន៍ទាបជាង៣ឆ្នាំចំនួន ២៣នាក់ ៣-៥ឆ្នាំ ចំនួន២៤នាក់ ៦-១០ឆ្នាំ ចំនួន២១នាក់ និង លើស ពី១០ឆ្នាំ ចំនួន៤៣នាក់។

*ក្រាហ្វិក ៣.៣.១ ៖ គុណវុឌ្ឍិនិងបទពិសោធន៍របស់គ្រូបង្រៀនពេញម៉ោង និងវេលាការ*




ក្រាហ្វិក ៣.៣.១ បង្ហាញថាគ្រូបង្រៀនពេញម៉ោងនិងវេលាការមានបទពិសោធន៍ក្នុងការបង្រៀនទាបជាង៣ឆ្នាំ មានចំនួន២០% ៣-៥ឆ្នាំ ចំនួន២០% ៦-១០ឆ្នាំ ចំនួន១៦% និង លើសពី១០ឆ្នាំ ចំនួន៤៤%។ ទោះបីជាសាកលវិទ្យាល័យមានគ្រូបង្រៀនដែលមានបទពិសោធន៍ទាបជាង៣ឆ្នាំ មានរហូតដល់២០%នៃគ្រូបង្រៀនសរុប ១៣០នាក់ ក៏ដោយ ប៉ុន្តែគ្រូបង្រៀនទាំងនោះគឺមានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត។ គ្រូបង្រៀនទាំងអស់មានគុណវុឌ្ឍិចាប់ពីបរិញ្ញាជាន់ខ្ពស់ ដល់បណ្ឌិត និង មានបទពិសោធន៍ក្នុងការបង្រៀនស្របតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ព្រមទាំងបានបង្រៀនស្របតាមជំនាញ និងកម្រិតបណ្តុះបណ្តាល។

### ២. ធនធានគ្រូបង្រៀនពេញម៉ោង

សាកលវិទ្យាល័យមានធនធានគ្រូបង្រៀនពេញម៉ោងតាមឆ្នាំនីមួយៗដូចខាងក្រោម៖

- **ឆ្នាំ២០២០ ៖** មានគ្រូបង្រៀនពេញម៉ោងស្មើនឹង ៣៤% នៃគ្រូបង្រៀនសរុប ១៥៧នាក់។
- **ឆ្នាំ២០២១ ៖** មានគ្រូបង្រៀនពេញម៉ោងស្មើនឹង ២៩% នៃគ្រូបង្រៀនសរុប ១២៩នាក់។
- **ឆ្នាំ២០២២ ៖** មានគ្រូបង្រៀនពេញម៉ោងស្មើនឹង ២៨% នៃគ្រូបង្រៀនសរុប ១២៧នាក់។
- **ឆ្នាំ២០២៣ ៖** មានគ្រូបង្រៀនពេញម៉ោងស្មើនឹង ២៧% នៃគ្រូបង្រៀនសរុប ១១៨នាក់។
- **ឆ្នាំ២០២៤ ៖** មានគ្រូបង្រៀនពេញម៉ោងស្មើនឹង ២៧% នៃគ្រូបង្រៀនសរុប ១១៨នាក់។
- **ឆ្នាំ២០២៥ ៖** មានគ្រូបង្រៀនពេញម៉ោងស្មើនឹង ១៦% នៃគ្រូបង្រៀនសរុប ១៣០នាក់។

*ក្រាហ្វិក ៣.៣.២ ៖ ធនធានគ្រូបង្រៀនពេញម៉ោងនិងវេលាការ*




ក្រាហ្វិក ៣.៣.២ បង្ហាញថា សាកលវិទ្យាល័យមានធនធានគ្រូបង្រៀនពេញម៉ោងស្ថិតនៅក្នុងចន្លោះពី ១៦% ទៅ ៣៤% ចាប់តាំងពីឆ្នាំ២០២០ មកដល់ឆ្នាំ២០២៥។ គ្រូបង្រៀនពេញម៉ោងមានការធ្លាក់ចុះជារៀងរាល់ឆ្នាំ ដែលមានភាគរយខ្ពស់បំផុតដល់៣៤%នៅឆ្នាំ២០២០ និងទាបបំផុតដល់១៦%នៅឆ្នាំ២០២៥។ សាកលវិទ្យាល័យមានគ្រូបង្រៀនពេញម៉ោងតែ១៦% ដែលភាគរយនៃគ្រូបង្រៀនពេញម៉ោងនេះពុំទាន់ស្រប តាមគោលការណ៍ណែនាំ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។ គ្រូបង្រៀនពេញម៉ោងមានតិចជាងគ្រូបង្រៀនវេលាការជារៀងរាល់ឆ្នាំ នេះមានន័យថាសាកលវិទ្យាល័យពឹងផ្អែកលើគ្រូបង្រៀនវេលាការខ្លាំងជាងគ្រូបង្រៀនពេញម៉ោង ដែលការណ៍នេះគប្បីសាកលវិទ្យាល័យ បង្កើនគ្រូបង្រៀនពេញម៉ោងតាមរយៈការបំលែងគ្រូបង្រៀនវេលាការដែលមានសមត្ថភាពខ្ពស់ទៅជាគ្រូបង្រៀនពេញម៉ោង ឬការជ្រើសរើសគ្រូបង្រៀនពេញម៉ោងបន្ថែមទៀត។

### ៣. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

សាកលវិទ្យាល័យបានកំណត់កម្មវិធីចំនួន៧ សម្រាប់ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជារៀងរាល់ឆ្នាំ ប៉ុន្តែសាកលវិទ្យាល័យបានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននេះបានតែចំនួន២៥ ស្មើនឹង ៧១.៤៣% នៃសកម្មភាព៥ឆ្នាំសរុបចំនួន៣៥ ចាប់ពីឆ្នាំពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៤។ តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន១៤នាក់បានឆ្លើយថា បានចូលរួមក្នុងកម្មវិធីអវឌ្ឍសមត្ថភាពគ្រូបង្រៀនទាំងអស់គ្នា ដូចជាការអភិវឌ្ឍកម្មវិធីសិក្សា, ការរៀបចំប្លង់មុខវិជ្ជា, វិធីសាស្ត្របង្រៀនជាដើម និង តាមរយៈការស្ទង់មតិរបស់គ្រូបង្រៀន១០៤នាក់ គ្រូបង្រៀន៨៤.៦% បានឆ្លើយថាបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ដូចជាស្តង់ដាសមត្ថភាពជំនាញទេសចរណ៍ជាតិនិងអាស៊ាន, ការស្រាវជ្រាវ, វិធីបង្រៀនតាមបែបថ្មីក្នុងសម័យឌីជីថល, Economic Policy Training,វគ្គបណ្តុះបណ្តាលគរុកោសល្យ, AI training, Andragology, ការគ្រប់គ្រងថ្នាក់រៀន, ការបញ្ច្រាបកម្មវិធីសិក្សា, របៀបសរសេរប្លង់មេរៀន...។

### ៤. ការដំឡើងឋានៈគ្រូបង្រៀន

សាកលវិទ្យាល័យពុំបានដំឡើងឋានៈដល់គ្រូបង្រៀនទេ ពីព្រោះសាកលវិទ្យាល័យទើបតែបានរៀបចំគោលការណ៍ដំឡើងឋានៈគ្រូបង្រៀននៅថ្ងៃទី២ ខែមករា ឆ្នាំ២០២៥ ប៉ុណ្ណោះ។ តាមរយៈការធ្វើបទបង្ហាញរបស់សាកលវិទ្យាល័យបានបង្ហាញថា សាកលវិទ្យាល័យកំពុងពិភាក្សាជាមួយថ្នាក់ដឹកនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ដើម្បីឱ្យការឡើងឋានៈនៅទីនេះស្មើនឹងឋានៈគ្រូបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈផងដែរ។ បច្ចុប្បន្ននេះ សាកលវិទ្យាល័យបានអនុញ្ញាតឱ្យគ្រូបង្រៀនដាក់ពាក្យស្នើសុំដំឡើងឋានៈទៅតាមគោលការណ៍របស់សាកលវិទ្យាល័យ។ តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន១៤នាក់ មានគ្រូបង្រៀនម្នាក់បានឆ្លើយថា គាត់បានដាក់ពាក្យស្នើសុំដំឡើងឋានៈតាមគោលការណ៍របស់សាកលវិទ្យាល័យរួចរាល់ហើយ និង តាមរយៈការស្ទង់មតិរបស់គ្រូបង្រៀន១០៤នាក់ គ្រូបង្រៀន ៨២.៧% បានឆ្លើយថាពុំបានឡើងឋានៈគ្រូបង្រៀន។

### ៥. ការរក្សាឯកសារទុកគ្រូបង្រៀនពេញម៉ោង វេលាការ និង បុគ្គលិក

សាកលវិទ្យាល័យបានរក្សាទុកឯកសារគ្រូបង្រៀនទាំងផ្នែករឹង និងទន់ នៅតាមមហាវិទ្យាល័យនីមួយៗ។ តាមរយៈការសង្កេត និង ការសម្ភាសជាមួយគណៈគ្រប់គ្រងមហាវិទ្យាល័យនីមួយៗបានឱ្យដឹងថា នៅក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ ពុំមានឯកសារគ្រូបង្រៀននៅក្នុងក្រុណូចំនួន៧នាក់ក្នុងចំណោមគ្រូបង្រៀន៤២នាក់ និង នៅក្នុងក្រុណូនីមួយៗពុំមានឯកសារគ្រប់គ្រាន់ទៀតផង។ នៅក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យា ឯកសារគ្រូបង្រៀនដាក់ក្នុងក្រុណូតែមួយ ពុំបានញែកឯកសារទៅតាមឈ្មោះគ្រូបង្រៀនម្នាក់ៗឡើយ។ នៅក្នុងមហាវិទ្យាល័យពាណិជ្ជសាស្ត្រនិងទេសចរណ៍ និង មហាវិទ្យាល័យនីតិសាស្ត្រនិងសេដ្ឋកិច្ច ពុំទាន់មានឯកសាររបស់គ្រូបង្រៀនគ្រប់គ្រាន់នៅក្នុងក្រុណូ ហើយមហាវិទ្យាល័យទាំងបួនពុំមានប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀនផ្នែកទន់ត្រឹមត្រូវនៅឡើយដែរ។

### ៦. ប្រាក់បៀវត្សនិងផលប្រយោជន៍នានា

សាកលវិទ្យាល័យមានសេចក្ដីសម្រេច ស្ដីពីការកំណត់កម្រៃអត្រាប្រាក់ម៉ោងជូនដល់គ្រូបង្រៀនឧត្តមសិក្សាសម្រាប់ការបង្រៀន លេខ០៦១/១៥ សភពអ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការជ្រើសរើសគ្រូបង្រៀនឧត្តមសិក្សា។ ការដំឡើងប្រាក់ម៉ោងបង្រៀនដល់គ្រូបង្រៀនធ្វើឡើងនៅរៀងរាល់ដំណាច់ឆ្នាំសិក្សា ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ និង ស្ថានភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យ។ នៅក្នុងឆ្នាំ២០២៤ និង ២០២៥ សាកលវិទ្យាល័យបានដំឡើងអត្រាប្រាក់ម៉ោងបង្រៀនដល់គ្រូបង្រៀនចំនួន ២១រូប និង បានលើកទឹកចិត្តគ្រូបង្រៀន តាមរយៈការបញ្ចុះតម្លៃសិក្សាសម្រាប់ក្រុមគ្រួសារនិងសាមីខ្លួនផ្ទាល់មួយចំនួន។ តាមរយៈការសម្ភាសគ្រូបង្រៀនមួយចំនួនបានលើកឡើងថា អត្រាប្រាក់ម៉ោងបង្រៀននៅមានកម្រិត និង ពុំដែលបានទទួលអត្ថប្រយោជន៍អ្វីទេក្រៅពីប្រាក់ម៉ោងបង្រៀន និង តាមរយៈការស្ទង់មតិរបស់គ្រូបង្រៀន១០៤នាក់ គ្រូបង្រៀន ៥៥.៨% ពេញចិត្តប្រាក់បៀវត្ស និង ផលប្រយោជន៍នានារបស់សាកលវិទ្យាល័យ។ ជារួម គ្រូបង្រៀនភាគច្រើនពុំទាន់ពេញចិត្តប្រាក់បៀវត្សនិងផលប្រយោជន៍នានារបស់សាកលវិទ្យាល័យ។

### ៧. កញ្ចប់ថវិកាសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់គ្រូបង្រៀន និង បុគ្គលិក

សាកលវិទ្យាល័យបានវិភាជថវិកាសម្រាប់សកម្មភាពអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និង បុគ្គលិករៀង

រាល់ឆ្នាំ និង បានប្រើប្រាស់ថវិកានេះលើការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និង បុគ្គលិកបាន ៧៧.៣៧%។ ចាប់ពីឆ្នាំ២០២០-២០២៥ សាកលវិទ្យាល័យបានរៀបចំវគ្គបណ្ដុះបណ្ដាល និង សិក្ខាសាលាមួយចំនួន ដូចជា ការសរសេរប្លង់មេរៀនលម្អិតដោយប្រើប្រាស់គោលការណ៍ Constructive Alignment និង ការរំលឹកឡើងវិញនូវអ្វីដែលហៅថាការធានាគុណភាពអប់រំផ្ទៃក្នុងនៅឧត្តមសិក្សា, AI "Introduction to Generative AI: Empowering University Workers and Lecturers", វិធីសាស្រ្តបង្រៀននិងរៀនពីអ្នកជំនាញឯកទេសមកពីសាកលវិទ្យាល័យដៃគូ AIT, Bangkok, Thailand ,"Refresher Training Workshop on QA and SAR 2023", កិច្ចប្រជុំចែករំលែកបទពិសោធន៍ក្នុងការរៀបរៀងសៀវភៅ ជាដើម។ តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន១៤នាក់ បានឆ្លើយថា បានចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និង តាមរយៈស្ទង់មតិបុគ្គលិក ៦១នាក់ មានបុគ្គលិក ៦០.៧% បានឆ្លើយថា គ្រូបង្រៀនបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាព។

**៨. ការកំណត់ទំហំភារកិច្ចនិងការទទួលខុសត្រូវ**

សាកលវិទ្យាល័យមានបទបញ្ញត្តិសម្រាប់គ្រូបង្រៀនឆ្នាំ២០២១ និងកិច្ចសន្យាគ្រូបង្រៀនដែលបានចែងយ៉ាងច្បាស់អំពីតួនាទីភារកិច្ចនៅក្នុងជំពូកទី៣នៃបទបញ្ញត្តិគ្រូបង្រៀន និង ក្នុងប្រការ៥នៃកិច្ចសន្យាគ្រូបង្រៀន ដើម្បីធានាបានគុណភាពក្នុងការបង្រៀននិងរៀន។ គ្រូបង្រៀនម្នាក់ៗបង្រៀនមិនលើស២៤ម៉ោងក្នុងមួយសប្តាហ៍ និង ៣មុខវិជ្ជាក្នុងមួយឆមាស។ តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន១៤នាក់ គ្រូបង្រៀនទាំងអស់បង្រៀនមិនលើស២៤ម៉ោងក្នុងមួយសប្តាហ៍ និង ៣មុខវិជ្ជាក្នុងមួយឆមាស និង តាមរយៈការស្ទង់មតិរបស់គ្រូបង្រៀន១០៤នាក់ គ្រូបង្រៀន ៨៩.៤% បានឆ្លើយថា ទំហំការងារបង្រៀនមានលក្ខណៈសមស្រប និង ១០.៦% មិនសមស្រប និង គ្រូបង្រៀន១០០% បានឆ្លើយថាបង្រៀនមិនលើស៣មុខវិជ្ជាក្នុងមួយឆមាស ។

**៩. ការវាយតម្លៃបុគ្គលិកអប់រំ**

សាកលវិទ្យាល័យមានគោលការណ៍និងនីតិវិធីវាយតម្លៃគ្រូបង្រៀនច្បាស់លាស់។ ការវាយតម្លៃគ្រូបង្រៀនធ្វើឡើងនៅរៀងរាល់ដំណាច់ឆមាស/វគ្គ (Term) នីមួយៗ តាមរយៈនិស្សិត និង គណៈគ្រប់គ្រង។ ការវាយតម្លៃគ្រូបង្រៀនតាមរយៈនិស្សិត ប្រព្រឹត្តទៅដោយការចាត់ចែងនៃមហាវិទ្យាល័យសាមីតាមរយៈ Google Form ដែលមានទម្រង់វាយតម្លៃផ្តោតលើចំណុចមួយចំនួន ដូចជា ព័ត៌មានទូទៅ, វិធីសាស្រ្តបង្រៀន, សម្ភារៈ និង ឯកសារបង្រៀន, ទំនួលខុសត្រូវ និង ឥរិយាបទរបស់គ្រូ, លទ្ធផលនៃការសិក្សារបស់និស្សិត និង សំណូមពរ។ ការវាយតម្លៃគ្រូបង្រៀនពីគណៈគ្រប់គ្រងតាមរយៈការិយាល័យធានាគុណភាពអប់រំផ្ទៃក្នុង និង ការចុះសង្កេតដោយផ្ទាល់ពីព្រឹទ្ធបុរស។ តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន១៤នាក់ គ្រូបង្រៀនទាំងអស់ទទួលបានការវាយតម្លៃ រៀងរាល់១ឆមាសម្តងពីនិស្សិត និង ការិយាល័យធានាគុណភាពផ្ទៃក្នុង។ តាមរយៈស្ទង់មតិរបស់និស្សិត៦៦១នាក់ និស្សិត៨៤.១% បានឆ្លើយថា បានវាយតម្លៃគ្រូបង្រៀនជាប្រចាំ។

**១០. ការផ្តល់យោបល់កែលម្អ**

គ្រូបង្រៀនទាំងអស់ទទួលបានលទ្ធផលវាយតម្លៃរៀងរាល់ចុងឆមាសនីមួយៗ ពីមហាវិទ្យាល័យរបស់ខ្លួនតាមរយៈការជួបផ្ទាល់ អ៊ីម៉ែល តេឡេក្រាម (Telegram) ជាដើម។ តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន១៤នាក់ គ្រូបង្រៀនទាំងអស់ឆ្លើយថា បានទទួលលទ្ធផលវាយតម្លៃរៀងរាល់ឆមាសពីគណៈគ្រប់គ្រង

មហាវិទ្យាល័យ តាមរយៈអ៊ីម៉ែល និងតេឡេក្រាម។ តាមរយៈស្ទង់មតិរបស់គ្រូបង្រៀន១០៤នាក់ គ្រូបង្រៀន ៨៤.១% បានឆ្លើយថាបានទទួលយោបល់កែលម្អទៅលើលទ្ធផលវាយតម្លៃជាប្រចាំ។

**១១. កញ្ចប់ថវិកាសម្រាប់គាំទ្រដល់ការស្រាវជ្រាវ**

សាកលវិទ្យាល័យបានវិភាជថវិកាសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍសម្រាប់ឆ្នាំ២០២៣ និង២០២៤ តែពុំបានយកទៅអនុវត្តលើសកម្មភាពស្រាវជ្រាវទេ។ តាមរយៈការសម្ភាសជាមួយគ្រូបង្រៀន១៤នាក់ បានឆ្លើយថា គួរមានកញ្ចប់ថវិកាសម្រាប់ការស្រាវជ្រាវ បោះពុម្ពស្នាដៃ និង បោះពុម្ពសៀវភៅតាមមុខវិជ្ជា និង គួរបង្កើនថវិកាគាំទ្រដល់ការស្រាវជ្រាវ និង អភិវឌ្ឍគម្រោងស្រាវជ្រាវបន្ថែមទៀត។ គណៈគ្រប់គ្រងបានឆ្លើយថា សាកលវិទ្យាល័យមានការិយាល័យស្រាវជ្រាវ១ស្ថិតនៅក្នុងថ្នាក់ក្រោយបរិញ្ញាបត្រសម្រាប់ការស្រាវជ្រាវ ប៉ុន្តែពុំមានប្រធានបទនៅក្នុងផែនការប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀនឡើយ។ ការិយាល័យស្រាវជ្រាវមានតួនាទីលើកទឹកចិត្តដល់គ្រូបង្រៀនឱ្យចូលរួមក្នុងការស្រាវជ្រាវ។ តាមរយៈការស្ទង់មតិរបស់គ្រូបង្រៀន១០៤នាក់ គ្រូបង្រៀន៥៨.៧% បានឆ្លើយថាបានវិភាជថវិកាគាំទ្រដល់ការស្រាវជ្រាវសមស្រប។

**ចំណុចខ្លាំង**

- គុណវឌ្ឍិ បទពិសោធន៍ និង ជំនាញរបស់គ្រូបង្រៀនស្របតាមកម្រិតបណ្តុះបណ្តាល និង មុខវិជ្ជាបង្រៀន
- ការបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗមិនលើស២៤ម៉ោងក្នុងមួយសប្តាហ៍ និង ៣មុខវិជ្ជាក្នុងមួយឆមាស
- បានវាយតម្លៃគ្រូបង្រៀនរៀងរាល់ឆមាស ដោយប្រើវិធីសាស្ត្រវាយតម្លៃច្រើនយ៉ាង
- គ្រូបង្រៀនម្នាក់ៗបានទទួលលទ្ធផលវាយតម្លៃ នៅរៀងរាល់ចុងឆមាសនីមួយៗ។

**ចំណុចអនុវត្តបានល្អ**

- ចំនួនគ្រូបង្រៀនពេញម៉ោងពុំទាន់ស្របតាមគោលការណ៍របស់ គ.ទ.ក
- បានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកភាគច្រើនធៀបនឹងផែនការ និងកញ្ចប់ថវិកាដែលបានកំណត់
- បានរៀបចំគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន ប៉ុន្តែពុំទាន់បានដំឡើងឋានៈគ្រូបង្រៀន

**ចំណុចកែលម្អ**

- សំណុំឯកសាររបស់គ្រូបង្រៀនពុំទាន់បានរក្សាទុកស្របតាមការណែនាំរបស់ គ.ទ.ក និងពុំទាន់រៀបចំជាប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀន
- គ្រូបង្រៀនភាគច្រើនពុំទាន់ពេញចិត្តប្រាក់បៀវត្សនិងផលប្រយោជន៍នានារបស់សាកលវិទ្យាល័យ
- មានកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន ប៉ុន្តែពុំទាន់បានចំណាយលើសកម្មភាពស្រាវជ្រាវ។

**សេចក្តីសន្និដ្ឋាន**

ជារួម សាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា៣។ គុណវឌ្ឍិ បទពិសោធន៍ និង ជំនាញរបស់គ្រូបង្រៀនស្របតាមកម្រិតបណ្តុះបណ្តាល និង មុខវិជ្ជាបង្រៀន។ ការបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗមិនលើស២៤ម៉ោងក្នុងមួយសប្តាហ៍ និង ៣មុខវិជ្ជាក្នុងមួយឆមាស។ សាកលវិទ្យាល័យ

បានវាយតម្លៃគ្រូបង្រៀនរៀងរាល់ឆមាស ដោយប្រើវិធីសាស្ត្រវាយតម្លៃច្រើនយ៉ាង និង គ្រូបង្រៀនទទួលលទ្ធផលវាយតម្លៃនៅរៀងរាល់ចុងឆមាសនីមួយៗ។ ចំនួនគ្រូបង្រៀនពេញម៉ោងពុំទាន់ឆ្លើយតបពេញលេញតាមគោលការណ៍របស់ គ.ទ.ក។ សាកលវិទ្យាល័យបានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកភាគច្រើនធៀបនឹងផែនការនិងកញ្ចប់ថវិកាដែលបានកំណត់ ព្រមទាំងបានរៀបចំគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន។ ទន្ទឹមនឹងនេះ សាកលវិទ្យាល័យមានចំណុចកែលម្អមួយចំនួន ដោយសំណុំឯកសាររបស់គ្រូបង្រៀនពុំទាន់បានរក្សាទុកស្របតាមការណែនាំរបស់ គ.ទ.ក និងពុំទាន់រៀបចំជាប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀន។ គ្រូបង្រៀនភាគច្រើនពុំទាន់ពេញចិត្តប្រាក់បៀវត្សនិងផលប្រយោជន៍នានា។ សាកលវិទ្យាល័យមានកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន ប៉ុន្តែពុំទាន់បានចំណាយលើសកម្មភាពស្រាវជ្រាវ។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា៣ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវៈ

- សិក្សាស្រាវជ្រាវពីតម្រូវការគ្រូបង្រៀន និងកែសម្រួលអត្រាប្រាក់ម៉ោងបង្រៀននិងផលប្រយោជន៍នានាសម្រាប់រក្សាគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ទាំងគ្រូបង្រៀនពេញម៉ោង និងវេលាការ
- រក្សាទុកសំណុំឯកសាររបស់គ្រូបង្រៀនឱ្យស្របតាមការណែនាំរបស់ គ.ទ.ក និង រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀន
- អនុវត្តកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន ឱ្យស្របតាមផែនការដែលបានកំណត់។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា៣ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរៈ

- ជ្រើសរើសគ្រូបង្រៀនពេញម៉ោងបន្ថែមទៀត
- អនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកឱ្យស្របតាមផែនការ និងកញ្ចប់ថវិកាដែលបានកំណត់
- អនុវត្តគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន។

**៣.៤. ស្តង់ដា៤៖ កម្មវិធីអប់រំ**

**របកគំហើញ**

**១. កម្មវិធីអប់រំមានលទ្ធផលសិក្សារំពឹងទុកស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ**

កម្មវិធីអប់រំ ៩៤% មានលទ្ធផលសិក្សារំពឹងទុកស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ប៉ុន្តែកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់មុខជំនាញទីផ្សារ និង កម្មវិធីឆ្នាំសិក្សាមូលដ្ឋានពុំទាន់មានលទ្ធផលសិក្សារំពឹងទុក។ ចំណែកកឯម្មវិធីបរិញ្ញាបត្ររង មុខជំនាញរដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ និងវិទ្យាសាស្ត្រកុំព្យូទ័រពុំបានបែងចែកលទ្ធផលសិក្សារំពឹងទុកទៅតាមប្រភេទ (domains) ដែលបានចែងដោយក្របខ័ណ្ឌគុណវុឌ្ឍិជាតិ។ សាកលវិទ្យាល័យបានបែងចែកជំនាញចិត្តចលនានៅក្នុងមុខជំនាញ គ្រប់គ្រងការដឹកជញ្ជូន វិទ្យាសាស្ត្រកុំព្យូទ័រ ហិរញ្ញវត្ថុនិងធនាគារ គ្រប់គ្រងប្រព័ន្ធព័ត៌មាន និង ភាសាអង់គ្លេសអប់រំ ប៉ុន្តែពុំទាន់មានជំនាញចិត្តចលនានៅក្នុងមុខជំនាញគណនេយ្យ។ កម្មវិធីអប់រំភាគច្រើននៃសាកលវិទ្យាល័យមានផែនទីផ្គូផ្គង

រវាង CLOs និង PLOs ប៉ុន្តែមានផែនទីផ្ទផ្ទង់សង្ខេបរវាងមុខវិជ្ជា និង PLOs (curriculum maps) តាមទម្រង់នាយកដ្ឋានឧត្តមសិក្សាបានតែ ៥ កម្មវិធីប៉ុណ្ណោះ។

*តារាង ៣.៤.១ ៖ ចំនួនលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធី*

| ល.រ | កម្រិតសិក្សា និងឯកទេស | ចំនួនលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធី ស្របជាមួយផ្នែកទាំង៥នៃក្របខណ្ឌគុណវុឌ្ឍិជាតិ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ក.គ.ជ១ | ក.គ.ជ២ | ក.គ.ជ៣ | ក.គ.ជ៤ | ក.គ.ជ៥ | |
| **បរិញ្ញាបត្រជាន់ខ្ពស់** | | | | | | | |
| 1 | គ្រប់គ្រង | 3 | 3 | 4 | 1 | 0 | 11 |
| 2 | ហិរញ្ញវត្ថុនិងធនាគារ | 3 | 3 | 4 | 1 | 0 | 11 |
| 3 | នីតិសាស្ត្រ | 3 | 5 | 2 | 1 | 0 | 11 |
| 4 | គោលនយោបាយសាធារណៈ | 3 | 5 | 2 | 1 | 0 | 11 |
| 5 | រដ្ឋបាលសាធារណៈ | 3 | 4 | 3 | 1 | 0 | 11 |
| 6 | ទំនាក់ទំនងអន្តរជាតិ | 4 | 3 | 3 | 1 | 0 | 11 |
| 7 | ទីផ្សារ | 0 | 0 | 0 | 0 | 0 | 0 |
| **បរិញ្ញាបត្រ** | | | | | | | |
| 1 | គ្រប់គ្រង | 3 | 3 | 2 | 2 | 0 | 10 |
| 2 | គណនេយ្យ | 1 | 5 | 2 | 1 | 0 | 9 |
| 3 | ទីផ្សារ | 3 | 4 | 2 | 2 | 0 | 11 |
| 4 | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | 3 | 4 | 2 | 2 | 0 | 11 |
| 5 | គ្រប់គ្រងការដឹកជញ្ជូន | 3 | 1 | 4 | 2 | 4 | 14 |
| 6 | ពាណិជ្ជកម្មអន្តរជាតិ | 3 | 3 | 3 | 2 | 0 | 11 |
| 7 | នីតិសាធារណៈ | 3 | 5 | 2 | 1 | 0 | 11 |
| 8 | អភិវឌ្ឍន៍សេដ្ឋកិច្ច | 3 | 4 | 1 | 2 | 0 | 10 |
| 9 | ហិរញ្ញវត្ថុនិងធនាគារ | 4 | 4 | 1 | 2 | 0 | 11 |
| 10 | ទំនាក់ទំនងអន្តរជាតិ | 3 | 2 | 4 | 2 | 0 | 11 |
| 11 | រដ្ឋបាលសាធារណៈ | 3 | 4 | 2 | 1 | 0 | 10 |
| 12 | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | 4 | 4 | 2 | 2 | 0 | 12 |
| 13 | វិទ្យាសាស្ត្រកុំព្យូទ័រ | 1 | 5 | 1 | 1 | 1 | 9 |
| 14 | ភាសាអង់គ្លេសអប់រំ | 3 | 4 | 2 | 1 | 0 | 10 |
| 15 | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | 3 | 4 | 2 | 1 | 0 | 10 |
| **បរិញ្ញាបត្ររង** | | | | | | | |
| ១ | គ្រប់គ្រង | 5 | 4 | 2 | 2 | 0 | 13 |
| ២ | គណនេយ្យ | 5 | 4 | 2 | 2 | 0 | 13 |
| ៣ | ទីផ្សារ | 5 | 4 | 2 | 2 | 0 | 13 |
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | 5 | 4 | 2 | 1 | 0 | 12 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | នីតិសាធារណៈ | 7 | 5 | 2 | 0 | 0 | 14 |
| ៦ | រដ្ឋបាលសាធារណៈ | | | | | | 12 |
| ៧ | អភិវឌ្ឍន៍សេដ្ឋកិច្ច | 4 | 4 | 4 | 0 | 0 | 12 |
| ៨ | ហិរញ្ញវត្ថុនិងធនាគារ | 5 | 4 | 4 | 4 | 1 | 18 |
| ៩ | ទំនាក់ទំនងអន្តរជាតិ | | | | | | 14 |
| ១០ | វិទ្យាសាស្ត្រកុំព្យូទ័រ | | | | | | 12 |
| ១១ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | 4 | 1 | 1 | 1 | 1 | 8 |
| ១២ | ភាសាអង់គ្លេសអប់រំ | 5 | 4 | 3 | 3 | 1 | 16 |
| ១៣ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | 5 | 4 | 3 | 3 | 1 | 16 |
| **ឆ្នាំសិក្សាមូលដ្ឋាន** | | | | | | | |
| ១ | ឆ្នាំសិក្សាមូលដ្ឋាន | 0 | 0 | 0 | 0 | 0 | 0 |
| **សរុប កម្មវិធី ៣៤ នៃ ៣៦ កម្មវិធី មានលទ្ធផលសិក្សារំពឹងទុកចំនួន** | | | | | | | 399 |

**ប្រភេទលទ្ធផលសិក្សានៃគុណវុឌ្ឍិជាតិ**

- **ក.គ.ជ១** ៖ ចំណេះដឹង
- **ក.គ.ជ២** ៖ ជំនាញក្នុងការគិត (ចំណេះដឹងវិភាគ)
- **ក.គ.ជ៣** ៖ ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ
- **ក.គ.ជ៤** ៖ ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង
- **ក.គ.ជ៥** ៖ ជំនាញចិត្តចលនា

## ២. ប្លង់មុខវិជ្ជាលម្អិត

សាកលវិទ្យាល័យបានធ្វើបច្ចុប្បន្នភាពទម្រង់ប្លង់មេរៀនលម្អិត ដោយអនុវត្តតាមទ្រឹស្តីបន្សីគ្នានៃលទ្ធផលសិក្សារំពឹងទុក (វិធីសាស្ត្របង្រៀន និង វិធីសាស្ត្រវាយតម្លៃ - Constructive Alignment) នៃក្របខណ្ឌអប់រំដោយផ្តោតលើលទ្ធផល (Outcome-Based Education)។ ធាតុសំខាន់នៃប្លង់មេរៀនលម្អិត (Course Syllabus) រួមមាន ១. ព័ត៌មានទូទៅនៃមុខវិជ្ជា និង គ្រូបង្រៀន ២. ពណ៌នាមុខវិជ្ជា ៣. លទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា (Course Learning Outcome – CLOs) ៤. តារាងខ្លឹមសារមេរៀន និងសកម្មភាព (ក. សប្តាហ៍ ខ. ខ្លឹមសារមេរៀន គ. លទ្ធផលសិក្សានៃមេរៀន (LLOs) ឃ. វិធីសាស្ត្របង្រៀន ង. វិធីសាស្ត្រវាយតម្លៃ) ៥. ការជ្រើសរើសមុខវិជ្ជា និង លក្ខខណ្ឌសិក្សាឱ្យបានជោគជ័យ ៦. សៀវភៅសិក្សា និងឯកសារសិក្សាផ្សេងៗ និង ៧. សេចក្តីណែនាំកិច្ចការស្រាវជ្រាវ និង និទ្ទេសបទ (Assignment Guideline and Rubric)។

៨៦% នៃមុខវិជ្ជាទាំងអស់ មានប្លង់មុខវិជ្ជាលម្អិត ប៉ុន្តែភាគច្រើនត្រឹមឆ្នាំសិក្សា ២០២១-២០២២។ រីឯកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់មុខជំនាញទីផ្សារ និង បរិញ្ញាបត្ររងមុខជំនាញរដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ និង វិទ្យាសាស្ត្រកុំព្យូទ័រ ពុំមានប្លង់មុខវិជ្ជាលម្អិតនោះទេ។

*តារាង ៣.៤.២ ៖ ចំនួនប្លង់មុខវិជ្ជាលម្អិត (រួមទាំងមុខវិជ្ជាជ្រើសរើស Electives)*

| ល.រ | កម្រិតកម្មវិធីអប់រំ និងឯកទេស | ចំនួនមុខវិជ្ជា | ចំនួនប្លង់មុខវិជ្ជាលម្អិត |
|---|---|---|---|
| **បរិញ្ញាបត្រជាន់ខ្ពស់** | | | |
| ១ | គ្រប់គ្រង | ១៣ | ១៣ |
| ២ | ហិរញ្ញវត្ថុនិងធនាគារ | ១៣ | ១៣ |

| | | | |
|---|---|---|---|
| ៣ | នីតិសាស្ត្រ | ១៣ | ១៣ |
| ៤ | គោលនយោបាយសាធារណៈ | ១៣ | ១៣ |
| ៥ | រដ្ឋបាលសាធារណៈ | ១៣ | ១៣ |
| ៦ | ទំនាក់ទំនងអន្តរជាតិ | ១៣ | ១៣ |
| ៧ | ទីផ្សារ | ១៣ | ០ |
| **បរិញ្ញាបត្រ** | | | |
| ១ | គ្រប់គ្រង | ៣២ | ៣២ |
| ២ | គណនេយ្យ | ៣២ | ៣២ |
| ៣ | ទីផ្សារ | ៣២ | ៣១ |
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | ៣២ | ៣២ |
| ៥ | គ្រប់គ្រងការដឹកជញ្ជូន | ៣២ | ២៦ |
| ៦ | ពាណិជ្ជកម្មអន្តរជាតិ | ៣២ | ៣០ |
| ៧ | ច្បាប់ | ៣២ | ៣២ |
| ៨ | អភិវឌ្ឍន៍សេដ្ឋកិច្ច | ៣២ | ២៩ |
| ៩ | ហិរញ្ញវត្ថុនិងធនាគារ | ៣២ | ២៧ |
| ១០ | ទំនាក់ទំនងអន្តរជាតិ | ៣២ | ១១ |
| ១១ | រដ្ឋបាលសាធារណៈ | ៣២ | ៣២ |
| ១២ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | ៣២ | ៣២ |
| ១៣ | វិទ្យាសាស្ត្រកុំព្យូទ័រ | ៣២ | ៣២ |
| ១៤ | ភាសាអង់គ្លេសអប់រំ | ៣២ | ៣២ |
| ១៥ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | ៣២ | ៣២ |
| **ឆ្នាំសិក្សាមូលដ្ឋាន** | | | |
| ១ | ឆ្នាំសិក្សាមូលដ្ឋាន | ៨ | ៨ |
| **បរិញ្ញាបត្ររង** | | | |
| ១ | គ្រប់គ្រង | ២០ | ២០ |
| ២ | គណនេយ្យ | ១៩ | ១៩ |
| ៣ | ទីផ្សារ | ២០ | ២០ |
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | ១៩ | ១៩ |
| ៥ | ច្បាប់ | ១៩ | ១៩ |
| ៦ | រដ្ឋបាលសាធារណៈ | ២០ | ០ |
| ៧ | អភិវឌ្ឍន៍សេដ្ឋកិច្ច | ១៨ | ១៦ |
| ៨ | ហិរញ្ញវត្ថុនិងធនាគារ | ២០ | ២០ |

| | | | |
|---|---|---|---|
| ៩ | ទំនាក់ទំនងអន្តរជាតិ | ២០ | ០ |
| ១០ | វិទ្យាសាស្ត្រកុំព្យូទ័រ | ២០ | ០ |
| ១១ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | ២០ | ២២ |
| ១២ | ភាសាអង់គ្លេសអប់រំ | ២០ | ២០ |
| ១៣ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | ២០ | ២០ |
| សរុប | | ៨៣៤ | ៧២១ (៨៦%) |

### ៣. យន្តការកំណត់ក្រេឌីតនិងគោលការណ៍ផ្ទេរក្រេឌីត

គ្រឹះស្ថានបានកំណត់ចំនួនក្រេឌីតសិក្សា និងអនុវត្តស្របតាមប្រព័ន្ធក្រេឌីត។ សាកលវិទ្យាល័យមានលិខិតស្នើសុំបណ្តុះបណ្តាល អនុក្រឹត្យឆ្នាំ២០០២ និងប្រកាសទទួលស្គាល់មុខជំនាញថ្មីឆ្នាំ២០១៧ និង ២០២៣។ សាកលវិទ្យាល័យមានសេចក្តីណែនាំឆ្នាំ២០២១ ស្តីពីការអនុវត្តប្រព័ន្ធក្រេឌីតពេញលេញ រួមទាំងបរិញ្ញាបត្ររយៈពេលបីឆ្នាំ និងលិខិតទទួលស្គាល់ពីអគ្គនាយកដ្ឋានឧត្តមសិក្សាឆ្នាំ២០២២សម្រាប់កម្មវិធីតាមប្រព័ន្ធក្រេឌីតពេញលេញ។ សាកលវិទ្យាល័យអនុវត្តការបង្រៀនតាមវគ្គសិក្សា (Term) ដែលក្នុងនោះសម្រាប់វគ្គសិក្សាខែមករា និង វគ្គសិក្សាខែឧសភា ដោយនិស្សិតពេញម៉ោងអាចសិក្សា ពី ៥ ទៅ ៧ មុខវិជ្ជា និង សម្រាប់វគ្គសិក្សាខែកញ្ញា និស្សិតពេញម៉ោងអាចសិក្សា ៣ មុខវិជ្ជា។ ដូច្នេះ ការកំណត់ចំនួនក្រេឌីតសរុបបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តិ។

*តារាង ៣.៤.៣ ៖ រយៈពេលសិក្សានិងចំនួនក្រេឌីតសរុប*

| កម្រិតសិក្សា និងមុខជំនាញ | រយៈពេលសិក្សា | | ចំនួនក្រេឌីតអប្បរមា |
|---|---|---|---|
| | ពេញម៉ោង | មិនពេញម៉ោង | |
| **បរិញ្ញាបត្រជាន់ខ្ពស់** | | | |
| គ្រប់មុខជំនាញ | ២ ឆ្នាំ | ៣ ឆ្នាំ | ៤៥ |
| **បរិញ្ញាបត្រ** | | | |
| គ្រប់មុខជំនាញ | ៣ ឬ ៣.៥០ ឆ្នាំ | ៦ ឆ្នាំ | ១២០ |
| **បរិញ្ញាបត្ររង** | | | |
| គ្រប់មុខជំនាញ | ២ ឆ្នាំ | ៣ ឆ្នាំ | ៦០ |

សាកលវិទ្យាល័យបានអនុវត្ត១ក្រេឌីតសិក្សា សម្រាប់ការសិក្សាទ្រឹស្តី ស្មើនឹង១៥ម៉ោង ការសិក្សាប្រតិបត្តិ/អនុវត្តគ្រាប់ ស្មើនឹង ៣០ម៉ោង ការអនុវត្តជាក់ស្តែង ស្មើនឹង ៤៥ម៉ោង ការចូលរួមសង្គម/សេវាសហគមន៍ ស្មើនឹង ៤៥ម៉ោង និង កម្មសិក្សា ស្មើនឹង ៤៥ម៉ោង។

*តារាង ៣.៤.៤ ៖ ប្រភេទនៃកម្មវិធីសិក្សា ចំនួនក្រេឌីត និងចំនួនម៉ោងសិក្សា*

| ល.រ | ប្រភេទនៃកម្មវិធីសិក្សា | ចំនួនក្រេឌីត | ចំនួនម៉ោង | ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ |
|---|---|---|---|---|
| ១ | ការសិក្សាទ្រឹស្តី | ១ក្រេឌីត | ១៥ ម៉ោង | ១៥ ម៉ោង |
| ២ | ការសិក្សាប្រតិបត្តិ/អនុវត្តគ្រាប់ | ១ក្រេឌីត | ៣០ ម៉ោង | ៣០ ម៉ោង |
| ៣ | ការអនុវត្តជាក់ស្តែង | ១ក្រេឌីត | ៤៥ ម៉ោង | ៤៥ ម៉ោង |

| | | | | |
|---|---|---|---|---|
| ៤ | សង្គម/សហគមន៍ | ១ក្រេឌីត | ៤៥ ម៉ោង | ៤៥ ម៉ោង |
| ៥ | កម្មសិក្សា | ១ក្រេឌីត | ៤៥ ម៉ោង | ៤៥ ម៉ោង |

**៤. ប្លង់មុខវិជ្ជាលម្អិតមានការពិពណ៌នាអំពីលទ្ធផលសិក្សារបស់និស្សិត**

៨៦% នៃមុខវិជ្ជាទាំងអស់ មានលទ្ធផលសិក្សារំពឹងទុក ដោយមានបញ្ជាក់ពីចំណេះដឹង ជំនាញ និង/ឬ អាកប្បកិរិយាដែលនិស្សិតនឹងទទួលបាន។ កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់មុខជំនាញទីផ្សារ បរិញ្ញាបត្ររងមុខជំនាញរដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ និង វិទ្យាសាស្ត្រកុំព្យូទ័រ ពុំមានលទ្ធផលសិក្សារំពឹងទុកទេ។

*តារាង ៣.៤.៥ ៖ ចំនួនលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា*

| ល.រ | កម្រិតកម្មវិធីអប់រំ និងមុខជំនាញ | ចំនួនមុខវិជ្ជា | ចំនួនមុខវិជ្ជាដែលមានការពិពណ៌នាលទ្ធផលសិក្សារបស់និស្សិត |
|---|---|---|---|
| **បរិញ្ញាបត្រជាន់ខ្ពស់** | | | |
| ១ | គ្រប់គ្រង | ១៣ | ១៣ |
| ២ | ហិរញ្ញវត្ថុនិងធនាគារ | ១៣ | ១៣ |
| ៣ | នីតិសាស្ត្រ | ១៣ | ១៣ |
| ៤ | គោលនយោបាយសាធារណៈ | ១៣ | ១៣ |
| ៥ | រដ្ឋបាលសាធារណៈ | ១៣ | ១៣ |
| ៦ | ទំនាក់ទំនងអន្តរជាតិ | ១៣ | ១៣ |
| ៧ | ទីផ្សារ | ១៣ | ០ |
| **បរិញ្ញាបត្រ** | | | |
| ១ | គ្រប់គ្រង | ៣២ | ៣២ |
| ២ | គណនេយ្យ | ៣២ | ៣២ |
| ៣ | ទីផ្សារ | ៣២ | ៣១ |
| ៤ | គ្រប់គ្រងសណ្ឋាគារ និង ទេសចរណ៍ | ៣២ | ៣២ |
| ៥ | គ្រប់គ្រងការដឹកជញ្ជូន | ៣២ | ២៦ |
| ៦ | ពាណិជ្ជកម្មអន្តរជាតិ | ៣២ | ៣០ |
| ៧ | ច្បាប់ | ៣២ | ៣២ |
| ៨ | អភិវឌ្ឍន៍សេដ្ឋកិច្ច | ៣២ | ២៩ |
| ៩ | ហិរញ្ញវត្ថុនិងធនាគារ | ៣២ | ២៧ |
| ១០ | ទំនាក់ទំនងអន្តរជាតិ | ៣២ | ១១ |
| ១១ | រដ្ឋបាលសាធារណៈ | ៣២ | ៣២ |
| ១២ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | ៣២ | ៣២ |
| ១៣ | វិទ្យាសាស្ត្រកុំព្យូទ័រ | ៣២ | ៣២ |

| | | | |
|---|---|---|---|
| ១៤ | ភាសាអង់គ្លេសអប់រំ | ៣២ | ៣២ |
| ១៥ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | ៣២ | ៣២ |
| **ឆ្នាំសិក្សាមូលដ្ឋាន** | | | |
| ១ | ឆ្នាំសិក្សាមូលដ្ឋាន | ៨ | ៨ |
| **បរិញ្ញាបត្ររង** | | | |
| ១ | គ្រប់គ្រង | ២០ | ២០ |
| ២ | គណនេយ្យ | ១៩ | ១៩ |
| ៣ | ទីផ្សារ | ២០ | ២០ |
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | ១៩ | ១៩ |
| ៥ | ច្បាប់ | ១៩ | ១៩ |
| ៦ | រដ្ឋបាលសាធារណៈ | ២០ | ០ |
| ៧ | អភិវឌ្ឍន៍សេដ្ឋកិច្ច | ១៨ | ១៦ |
| ៨ | ហិរញ្ញវត្ថុនិងធនាគារ | ២០ | ២០ |
| ៩ | ទំនាក់ទំនងអន្តរជាតិ | ២០ | ០ |
| ១០ | វិទ្យាសាស្ត្រកុំព្យូទ័រ | ២០ | ០ |
| ១១ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | ២០ | ២២ |
| ១២ | ភាសាអង់គ្លេសអប់រំ | ២០ | ២០ |
| ១៣ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | ២០ | ២០ |
| **សរុប** | | **៨៣៤** | **៧២១ (៨៦%)** |

**៥. វិធីសាស្ត្រវាយតម្លៃឆ្លើយតបទៅនឹងលទ្ធផលសិក្សារំពឹងទុក**

គ្រឹះស្ថានបានប្រើវិធីសាស្ត្រច្រើនយ៉ាងក្នុងការវាយតម្លៃនិស្សិត ហើយ ៧៣% នៃមុខវិជ្ជាទាំងអស់មានការផ្ទៀងផ្ទាត់រវាងវិធីសាស្ត្រវាយតម្លៃ ទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា។ ប៉ុន្តែគ្រឹះស្ថានពុំបានផ្ទៀងផ្ទាត់រវាងវិធីសាស្ត្រវាយតម្លៃបញ្ចប់ការសិក្សា (ដូចជា កម្មសិក្សា គម្រោងស្រាវជ្រាវ និក្ខេបបទ) ទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធីនោះទេ។ ចំពោះវិធីសាស្ត្រវាយតម្លៃក្នុងមុខវិជ្ជា បទបញ្ញត្តិ សម្រាប់គ្រូបង្រៀន ខែតុលា ឆ្នាំ ២០២១ ជំពូកទី៦ បានកំណត់វិធីសាស្ត្រវាយតម្លៃច្បាស់លាស់ ដោយបែងចែកជាបីប្រភេទ គឺការសិក្សាក្នុងថ្នាក់ ការសិក្សាអនឡាញ និងការហាត់ការ (Internship)។

- **ការសិក្សាប្រភេទទី១ ៖ ការសិក្សាក្នុងថ្នាក់ ចែកចេញជា៣ជម្រើស**

**ជម្រើសទី១**

1. Ongoing Class Assessment (Formative Assessment) – 75%
   a. Class Attendance & Participant – 10%

b. Quiz at least 7 times – 25%
c. Assignment at least 2 – 20%
d. Mid-term Exam – 20%

2. Final Exam ( Summative Assessment ) – 25%

**ជម្រើសទី២**

1. Ongoing Class Assessment ( Formative Assessment ) – 75%
    a. Class Attendance & Participant – 10%
    b. Quiz at least 5 times – 20%
    c. Minor Assignment at least 3 – 20%
    d. Major Assignment – 25%
2. Final Exam ( Summative Assessment ) – 25%

**ជម្រើសទី៣**

1. Ongoing Class Assessment ( Formative Assessment ) – 35%
    a. Class Attendance & Participant – 10%
    b. Quiz at least 5 times – 25%
2. Term Project – 65% ( the percentage of each component depends on lecturers ).

The component includes:

a. Project Proposal
b. Project Progress Report
c. Final Report

- **ការសិក្សាប្រភេទទី២៖ ការសិក្សាអនឡាញ ចែកចេញជា៣ជម្រើស**

**ជម្រើសទី០១**

1. Ongoing Class Assessment ( Formative Assessment ) – 75%
    a. Class Attendance & Participant – 10%
    b. Quiz at least 7 times – 35%
    c. Assignment at least 2 – 30%
2. Final Exam ( Summative Assessment ) – 25%

**ជម្រើសទី០២**

1. Ongoing Class Assessment ( Formative Assessment ) – 100%
    a. Class Attendance & Participant – 10%
    b. Quiz at least 5 times – 25%
    c. Minor Assignment at least 3 – 30%
    d. Major Assignment – 35%

**ជម្រើសទី០៣**

1. Ongoing Class Assessment ( Formative Assessment ) – 35%
    a. Class Attendance & Participant – 10%
    b. Quiz at least 5 times – 25%
2. Team project – 65% ( the percentage of each component depends on lecturers )
    a. Project Proposal
    b. Project Progress Report
    c. Final Report

- **ការសិក្សាប្រភេទទី៣៖ ហាត់ការ (Internship Report)**
    a. Class attendance & participation – 10%
    b. Reflective Journal – 5%
    c. Report and Presentation of the Organization – 10%
    d. Report & Presentation ( 4 ) – 20%
    e. Final Report – 35%
    f. Self-evaluation – 10%
    g. Site supervisor – 10%

សាកលវិទ្យាល័យមាននិទ្ទេសបទខ្លះៗ ប៉ុន្តែពុំបានបង្ហាញភស្តុតាងនៃការប្រើប្រាស់និទ្ទេសបទ និងមានគំរូរបាយការណ៍ស្រាវជ្រាវជាក្រុមក្នុងមុខវិជ្ជានៃមហាវិទ្យាល័យនានា២៥ក្បាល ព្រមទាំងមានគំរូកំណែកិច្ចការស្រាវជ្រាវ (Assignment) និស្សិត៣៦នាក់ និងយោបល់ត្រឡប់ពីគ្រូបង្រៀន ប៉ុន្តែគ្មានការប្រើប្រាស់និទ្ទេសបទ។

*តារាង ៣.៤.៦ ៖ ការផ្ទៀងផ្ទាត់រវាងវិធីសាស្ត្រវាយតម្លៃទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា*

| ល.រ | កម្រិតកម្មវិធីអប់រំ និងមុខជំនាញ | ចំនួនមុខវិជ្ជា | ការផ្ទៀងផ្ទាត់រវាងវិធីសាស្ត្រវាយតម្លៃ និង CLO |
|---|---|---|---|
| **បរិញ្ញាបត្រជាន់ខ្ពស់** | | | |
| ១ | គ្រប់គ្រង | ១៣ | ១០ |
| ២ | ហិរញ្ញវត្ថុនិងធនាគារ | ១៣ | ១០ |
| ៣ | នីតិសាស្ត្រ | ១៣ | ៩ |
| ៤ | គោលនយោបាយសាធារណៈ | ១៣ | ១០ |
| ៥ | រដ្ឋបាលសាធារណៈ | ១៣ | ១០ |
| ៦ | ទំនាក់ទំនងអន្តរជាតិ | ១៣ | ៩ |
| ៧ | ទីផ្សារ | ១៣ | ០ |
| **បរិញ្ញាបត្រ** | | | |
| ១ | គ្រប់គ្រង | ៣២ | ២៩ |

| | | | |
|---|---|---|---|
| ២ | គណនេយ្យ | ៣២ | ៣១ |
| ៣ | ទីផ្សារ | ៣២ | ២៦ |
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | ៣២ | ៣២ |
| ៥ | គ្រប់គ្រងការដឹកជញ្ជូន | ៣២ | ២២ |
| ៦ | ពាណិជ្ជកម្មអន្តរជាតិ | ៣២ | ១២ |
| ៧ | ច្បាប់ | ៣២ | ២៦ |
| ៨ | អភិវឌ្ឍន៍សេដ្ឋកិច្ច | ៣២ | ២១ |
| ៩ | ហិរញ្ញវត្ថុនិងធនាគារ | ៣២ | ២០ |
| ១០ | ទំនាក់ទំនងអន្តរជាតិ | ៣២ | ៣ |
| ១១ | រដ្ឋបាលសាធារណៈ | ៣២ | ២៤ |
| ១២ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | ៣២ | ៣០ |
| ១៣ | វិទ្យាសាស្ត្រកុំព្យូទ័រ | ៣២ | ៣២ |
| ១៤ | ភាសាអង់គ្លេសអប់រំ | ៣២ | ៣២ |
| ១៥ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | ៣២ | ៣២ |
| **ឆ្នាំសិក្សាមូលដ្ឋាន** | | | |
| ១ | ឆ្នាំសិក្សាមូលដ្ឋាន | ៨ | ៨ |
| **បរិញ្ញាបត្ររង** | | | |
| ១ | គ្រប់គ្រង | ២០ | ២០ |
| ២ | គណនេយ្យ | ១៩ | ៨ |
| ៣ | ទីផ្សារ | ២០ | ២០ |
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | ១៩ | ១៩ |
| ៥ | ច្បាប់ | ១៩ | ៦ |
| ៦ | រដ្ឋបាលសាធារណៈ | ២០ | ០ |
| ៧ | អភិវឌ្ឍន៍សេដ្ឋកិច្ច | ១៨ | ៧ |
| ៨ | ហិរញ្ញវត្ថុនិងធនាគារ | ២០ | ១១ |
| ៩ | ទំនាក់ទំនងអន្តរជាតិ | ២០ | ០ |
| ១០ | វិទ្យាសាស្ត្រកុំព្យូទ័រ | ២០ | ០ |
| ១១ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | ២០ | ២២ |
| ១២ | ភាសាអង់គ្លេសអប់រំ | ២០ | ២០ |
| ១៣ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | ២០ | ០ |
| **សរុប** | | | |
| | **សរុប** | **៨៣៤** | **៦០៧ (៧៣%)** |

ជាសរុប ៧៣% នៃមុខវិជ្ជាទាំងអស់ មានការផ្ទផ្ទងរវាងវិធីសាស្រ្តវាយតម្លៃ ទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជាបានត្រឹមត្រូវ។ មុខវិជ្ជាដទៃទៀតពុំមានការផ្ទផ្ទង ឬមានការផ្ទផ្ទងលើសឬខ្វះចំនួនលទ្ធផលសិក្សា។

សាកលវិទ្យាល័យពុំបានផ្ទផ្ទងរវាងវិធីសាស្រ្តវាយតម្លៃបញ្ចប់ការសិក្សា ទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធីនោះទេ។ ចំពោះវិធីសាស្រ្តវាយតម្លៃបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ សាកលវិទ្យាល័យមានសេចក្តីណែនាំអំពីកម្មសិក្សា គឺនិស្សិតចាប់ពីឆ្នាំទី២ឡើង អាចចាប់ផ្តើមធ្វើកម្មសិក្សាបាន។ សាកលវិទ្យាល័យមានគំរូរបាយការណ៍កម្មសិក្សា (internship report) ១២ក្បាល។ បទបញ្ញត្តិ PPIU សម្រាប់គ្រូបង្រៀន ខែតុលា ឆ្នាំ ២០២១ ជំពូកទី១៤ តម្រូវកម្មសិក្សា ប៉ុន្តែលោកសាកលវិទ្យាធិការរងជាន់ខ្ពស់បានបញ្ជាក់ថា ក្នុងការអនុវត្តនៃគ្រឹះស្ថាន និស្សិតពុំធ្វើកម្មសិក្សាក៏បាន។ សាកលវិទ្យាល័យមានគំរូសំណុំឯកសារកម្មសិក្សាបង្រៀន (teaching practicum portfolio) ៣០ក្បាល និងមានភស្តុតាងនៃការប្រើប្រាស់និទ្ទេសបទក្នុងសំណុំឯកសារកម្មសិក្សាបង្រៀនទាំងនោះ។

ចំពោះវិធីសាស្រ្តវាយតម្លៃបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ សាកលវិទ្យាល័យមានគំរូគម្រោងស្រាវជ្រាវបញ្ចប់ ២៩ក្បាល (គ្រូណែនាំ១រូប) និងមានភស្តុតាងនៃការប្រើប្រាស់និទ្ទេសបទវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ(នៃនិក្ខេបបទ) របស់និស្សិត៤នាក់ ដោយគណៈកម្មការ៣រូប។ សាកលវិទ្យាល័យពុំមានសេចក្តីណែនាំអំពីភាពខុសគ្នារវាងគម្រោងស្រាវជ្រាវនិងនិក្ខេបបទ។

## ៦. ការពិនិត្យនិងកែលម្អកម្មវិធីអប់រំ

សាកលវិទ្យាល័យបានបង្កើតក្រុមប្រឹក្សាអភិវឌ្ឍកម្មវិធីសិក្សា និងតែងតាំងគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សាតាមមហាវិទ្យាល័យ និងក្រុមការងារកែលម្អកម្មវិធីសិក្សាតាមមុខជំនាញ។ គ្រឹះស្ថានបានពិនិត្យនិងកែលម្អកម្មវិធីអប់រំចំនួន៣៣ (៩២%) ស្របតាមយន្តការដែលបានកំណត់ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ជាពិសេសនៅក្នុងគម្រោងកែលម្អឧត្តមសិក្សា (HEIP)។ កម្មវិធីដែលពុំទាន់បានកែលម្អ រួមមានកម្មវិធីឆ្នាំសិក្សាមូលដ្ឋាន បរិញ្ញាបត្ររងទំនាក់ទំនងអន្តរជាតិ និងបរិញ្ញាបត្ររងវិទ្យាសាស្រ្តកុំព្យូទ័រ។

*តារាង ៣.៤.៧ ៖ ចំនួនកម្មវិធីអប់រំបានកែលម្អ*

| ល.រ | កម្រិតកម្មវិធីអប់រំ និងមុខជំនាញ | ការកែលម្អ |
|---|---|---|
| **បរិញ្ញាបត្រជាន់ខ្ពស់** | | |
| ១ | គ្រប់គ្រង | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ២ | ហិរញ្ញវត្ថុនិងធនាគារ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៣ | នីតិសាស្រ្ត | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៤ | គោលនយោបាយសាធារណៈ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៥ | រដ្ឋបាលសាធារណៈ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៦ | ទំនាក់ទំនងអន្តរជាតិ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៧ | ទីផ្សារ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| **បរិញ្ញាបត្រ** | | |
| ១ | គ្រប់គ្រង | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ២ | គណនេយ្យ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៣ | ទីផ្សារ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |

| | | |
|---|---|---|
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៥ | គ្រប់គ្រងការដឹកជញ្ជូន | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៦ | ពាណិជ្ជកម្មអន្តរជាតិ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៧ | ច្បាប់ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៨ | អភិវឌ្ឍន៍សេដ្ឋកិច្ច | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៩ | ហិរញ្ញវត្ថុនិងធនាគារ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១០ | ទំនាក់ទំនងអន្តរជាតិ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១១ | រដ្ឋបាលសាធារណៈ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១២ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១៣ | វិទ្យាសាស្ត្រកុំព្យូទ័រ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១៤ | ភាសាអង់គ្លេសអប់រំ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១៥ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| **ឆ្នាំសិក្សាមូលដ្ឋាន** | | |
| ១ | ឆ្នាំសិក្សាមូលដ្ឋាន | ពុំបានកែលម្អកម្មវិធី |
| **បរិញ្ញាបត្ររង** | | |
| ១ | គ្រប់គ្រង | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ២ | គណនេយ្យ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៣ | ទីផ្សារ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៤ | គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៥ | ច្បាប់ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៦ | រដ្ឋបាលសាធារណៈ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៧ | អភិវឌ្ឍន៍សេដ្ឋកិច្ច | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៨ | ហិរញ្ញវត្ថុនិងធនាគារ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ៩ | ទំនាក់ទំនងអន្តរជាតិ | ពុំបានកែលម្អកម្មវិធី |
| ១០ | វិទ្យាសាស្ត្រកុំព្យូទ័រ | ពុំបានកែលម្អកម្មវិធី |
| ១១ | គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១២ | ភាសាអង់គ្លេសអប់រំ | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| ១៣ | ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម | បានកែលម្អរចនាសម្ព័ន្ធកម្មវិធី (សៀវភៅព័ត៌មានឆ្នាំ២០២៤) |
| **សរុប** | | **៣៣ (៩២%)** |

**ចំណុចខ្លាំង**

- កម្មវិធីអប់រំស្ទើរតែទាំងអស់ មានលទ្ធផលសិក្សារំពឹងទុកស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ
- គ្រឹះស្ថានបានកំណត់ចំនួនក្រេឌីតសិក្សាបានត្រឹមត្រូវ និងអនុវត្តស្របតាមប្រព័ន្ធក្រេឌីត
- បានពិនិត្យនិងកែលម្អកម្មវិធីអប់រំស្របតាមយន្តការដែលបានកំណត់ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

**ចំណុចអនុវត្តបានល្អ**

- ភាគច្រើននៃមុខវិជ្ជាទាំងអស់ មានប្លង់មុខវិជ្ជាលម្អិត (ជំនាញឯកទេសបរិញ្ញាបត្រជាន់ខ្ពស់ទីផ្សារ បរិញ្ញាបត្ររងរដ្ឋបាលសាធារណៈ ទំនាក់ទំនងអន្តរជាតិ វិទ្យាសាស្ត្រកុំព្យូទ័រ ភាសាអង់គ្លេសធុរកិច្ច)

- ភាគច្រើននៃមុខវិជ្ជាទាំងអស់ មានលទ្ធផលសិក្សារំពឹងទុក
- បានប្រើវិធីសាស្ត្រច្រើនយ៉ាងក្នុងការវាយតម្លៃនិស្សិត ហើយបានផ្ទួរផ្គងរវាងលទ្ធផលសិក្សារំពឹងទុក វិធីសាស្ត្របង្រៀន និង វិធីសាស្ត្រវាយតម្លៃ។

**សេចក្តីសន្និដ្ឋាន**

ជារួម សាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា៤។ កម្មវិធីអប់រំស្ទើរតែទាំងអស់ មានលទ្ធផលសិក្សារំពឹងទុកស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ។ ភាគច្រើននៃមុខវិជ្ជាទាំងអស់មានប្លង់មុខវិជ្ជាលម្អិត និងលទ្ធផលសិក្សារំពឹងទុក។ គ្រឹះស្ថានបានកំណត់ចំនួនក្រេឌីតសរុបបានត្រឹមត្រូវ និងអនុវត្តស្របតាមប្រព័ន្ធក្រេឌីត។ គ្រូបង្រៀនបានប្រើវិធីសាស្ត្រច្រើនយ៉ាងក្នុងការវាយតម្លៃនិស្សិត ហើយបានផ្ទួផ្គងរវាងលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា និង វិធីសាស្ត្រវាយតម្លៃ។ មិនតែប៉ុណ្ណោះ សាកលវិទ្យាល័យបានពិនិត្យនិងកែលម្អកម្មវិធីអប់រំស្របតាមយន្តការដែលបានកំណត់ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា៤ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវ៖

- ពុំមាន។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា៤ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរ៖

- សរសេរនិងធ្វើបច្ចុប្បន្នកម្ម ប្លង់មុខវិជ្ជាលម្អិត រួមទាំងលទ្ធផលសិក្សារំពឹងទុក ឱ្យបានគ្រប់កម្មវិធីអប់រំ
- ផ្ទួផ្គងវិធីសាស្ត្រវាយតម្លៃនៃមុខវិជ្ជា ទៅនឹងលទ្ធផលសិក្សារំពឹងទុក ឱ្យបានគ្រប់មុខវិជ្ជាទាំងអស់ ក៏ដូចជាផ្ទួផ្គងវិធីសាស្ត្រវាយតម្លៃបញ្ចប់ការសិក្សា ទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃគ្រប់កម្មវិធីអប់រំ។

**៣.៥. ស្តង់ដា៥៖ សេវានិស្សិត**

**របកគំហើញ**

**១. គោលនយោបាយឬគោលការណ៍ ស្តីពីការជ្រើសរើសនិស្សិតចូលរៀន**

បេក្ខជនចូលរៀនថ្នាក់បរិញ្ញាបត្រត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និទ្ទេសរួម ពី A ដល់ E ឬសញ្ញាបត្រដែលមានតម្លៃស្មើ។ បេក្ខជនចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។ សាកលវិទ្យាល័យមានបញ្ជីបេក្ខជនប្រឡង និងជ្រើសរើសចូលរៀនដោយអនុវត្តបានយ៉ាងត្រឹមត្រូវ និងមានការចូលរួមត្រួតពិនិត្យពីគណៈគ្រប់គ្រង និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។ សាកលវិទ្យាល័យអនុវត្តស្របតាមគោលការណ៍ណែនាំ លេខ០៩ អយក. សណន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីលក្ខខណ្ឌតម្រូវវិញ្ញាសា និងមុខវិជ្ជាសម្រាប់ការជ្រើសរើសនិស្សិតឱ្យចូលសិក្សាតាមមុខជំនាញ នៃកម្រិតបរិញ្ញាបត្រ។ សាកលវិទ្យាល័យមានគោលការណ៍ និងនីតិវិធីច្បាស់លាស់ក្នុងការជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្នុងគោលបំណងធានានូវការជ្រើសរើសនិស្សិតចូលសិក្សាប្រកបដោយតម្លាភាព ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ និងគោលការណ៍ដែលមានចែងជាធរមាន។ តាមការអនុវត្តគោលការណ៍និងនីតិវិធីខាងលើ សាកលវិទ្យាល័យសម្រេចជ្រើសរើសនិស្សិតបាននៅក្នុងឆ្នាំសិក្សា២០២០ ចំនួន ៥៩៤នាក់ ក្នុងនោះថ្នាក់

បរិញ្ញាបត្រជាន់ខ្ពស់៣៣នាក់ និងបរិញ្ញាបត្រចំនួន ៥៦១នាក់។ ឆ្នាំ២០២១ ជ្រើសរើសបានចំនួន ៧៨១នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៥នាក់ បរិញ្ញាបត្រចំនួន ៤៦២នាក់ និងបរិញ្ញាបត្ររងចំនួន ២៩៤នាក់។ ឆ្នាំ២០២២ ជ្រើសរើសបានចំនួន ៨៤៤នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣៤នាក់ បរិញ្ញាបត្រចំនួន ៤៥៨នាក់ និងបរិញ្ញាបត្ររងចំនួន ៣៥២នាក់។ ឆ្នាំ២០២៣ ជ្រើសរើសបានចំនួន ៨៨៤នាក់ ក្នុងនោះ បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៩នាក់ បរិញ្ញាបត្រចំនួន ៤៩២នាក់ និងបរិញ្ញាបត្ររងចំនួន ៣៦៣នាក់។ ឆ្នាំ ២០២៤ ជ្រើសរើសបានចំនួន ១ ០៤៥នាក់ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣៧នាក់ បរិញ្ញាបត្រចំនួន ៧២០នាក់ និងបរិញ្ញាបត្ររងចំនួន ២៨៨នាក់។

*ក្រាហ្វិក ៣.៥.១ ៖ ស្ថិតិនិស្សិតជ្រើសរើសចូលសិក្សាតាមឆ្នាំនីមួយៗ*




## ២. គុណវុឌ្ឍិ និង បទពិសោធន៍របស់អ្នកគ្រប់គ្រងនិងបុគ្គលិកប្រតិបត្តិ

នាយកដ្ឋានសិក្សា និង ការិយាល័យផ្តល់ប្រឹក្សានិស្សិតនិងព័ត៌មាន ជាសេនាធិការក្នុងកិច្ចការសេវានិស្សិតរបស់សាកលវិទ្យាល័យ។ នាយកដ្ឋានសិក្សាមានសមាសភាពសរុបចំនួន ១២នាក់ ស្រី ៥នាក់ និង ការិយាល័យផ្តល់ប្រឹក្សានិស្សិតនិងព័ត៌មានមានសមាសភាព ១០នាក់ ស្រី ៧នាក់។ ក្រុមការងារទាំងអស់នេះ ទាំងនៅក្នុងនាយកដ្ឋានសិក្សានិងការិយាល័យប្រឹក្សានិស្សិតនិងព័ត៌មាន មានគុណវុឌ្ឍិសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២នាក់ ដែលមានបទពិសោធន៍លើសពី១០ឆ្នាំ បរិញ្ញាបត្រចំនួន ៥នាក់ ក្នុងនោះមាន បទពិសោធន៍ ៣-៥ឆ្នាំ ចំនួន ៣នាក់ និង ៦-១០ឆ្នាំ ចំនួន ២នាក់ និង ទាបជាងបរិញ្ញាបត្រចំនួន ១៥នាក់ ដែលមានបទពិសោធន៍ទាបជាង៣ឆ្នាំ។ បុគ្គលិកដែលមានគុណវុឌ្ឍិទាបជាងបរិញ្ញាបត្រជានិស្សិតហាត់ការ ដែលទទួលបានប្រាក់ឧបត្ថម្ភ។ សាកលវិទ្យាល័យបានជ្រើសរើសនិស្សិតហាត់ការដោយផ្តល់ប្រាក់ឧបត្ថម្ភ ដើម្បីជួយកិច្ចការនិស្សិត ដែលការជ្រើសនិស្សិតស្ម័គ្រចិត្តមកជួយបម្រើការងារនេះគឺជាវិធីសន្សំសំចៃដ៏ល្អ ប៉ុន្តែ ស្ថិរភាពនៃការងារក៏នៅមានកម្រិតផងដែរ។ ជារួម បុគ្គលិកគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិភាគច្រើនមាន គុណវុឌ្ឍិស្របតាមតួនាទីភារកិច្ច។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួរបង្កើនបុគ្គលិកសេវានិស្សិតពេញ

ម៉ោងបន្ថែមទៀតដែលមានកម្រិតគុណវុឌ្ឍិនិងបទពិសោធន៍ខ្ពស់ ដើម្បីជានាស្ថិរភាពនៃការងារ និងការឆ្លើយតបទៅនឹងតម្រូវការនិស្សិត។

*ក្រាហ្វិក ៣.៥.២ ៖ គុណវុឌ្ឍិនិងបទពិសោធន៍អ្នកគ្រប់គ្រងនិងបុគ្គលិកប្រតិបត្តិសេវានិស្សិត*




### ៣. សេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និង កម្មវិធីអប់រំសុខភាព

សាកលវិទ្យាល័យមានបន្ទប់សង្គ្រោះបឋមនៅនឹងកន្លែង មានទូសម្រាប់រក្សាឱសថសង្គ្រោះបឋម គ្រែ និងខ្នើយសម្រាក ដោយទទួលបានការជ្រោមជ្រែងពីយុវជនកាកបាទក្រហមប្រចាំសាកលវិទ្យាល័យដែលបានទទួលការបណ្តុះបណ្តាល ដើម្បីផ្តល់សេវាសង្គ្រោះបឋមក្នុងករណីចាំបាច់ ប៉ុន្តែសាកលវិទ្យាល័យពុំទាន់មានគិលានុបដ្ឋាយិកាប្រចាំការនៅឡើយ។ ដើម្បីបន្តការគាំទ្រសេវាប្រឹក្សាសុខភាពបន្ថែមទៀតដល់និស្សិត សាកលវិទ្យាល័យមានកិច្ចសហការល្អប្រសើរជាមួយមន្ទីរពេទ្យបង្អែកក្រុង មន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យព្រះអង្គឌួង និង ជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាមករណីមានតម្រូវការឈាមសង្គ្រោះជីវិត។

ចាប់តាំងពីឆ្នាំ ២០២១-២០២៥ មាននិស្សិតស្រី ១នាក់ ទទួលបានសេវាប្រឹក្សាសុខភាពផ្លូវចិត្ត មាននិស្សិតសរុប ៤៥នាក់ ស្រី ២៧នាក់ទទួលបានសេវាសុខភាព និង មាននិស្សិត១០០នាក់ ស្រី ៦៥នាក់ ទទួលបានការអប់រំសុខភាព។ តាមរយៈការវាយតម្លៃដោយសាកលវិទ្យាល័យឃើញថានិស្សិតមានការពេញចិត្ត ៥០%-៥៥% លើការផ្តល់សេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និងកម្មវិធីអប់រំសុខភាព និង តាមការផ្ទៀងផ្ទាត់បន្ថែម ក្នុងទំហំសំណាកនិស្សិត ៦៦១នាក់ មាន ៥៩.១% បានបញ្ជាក់ថាសាកលវិទ្យាល័យបានផ្តល់សេវាសុខភាពនិងកម្មវិធីអប់រំសុខភាពបានល្អ និង ៦១% ថាបានផ្តល់សេវាសុខភាពផ្លូវចិត្តបានល្អ។ ជារួម និស្សិតភាគច្រើនពេញចិត្តលើសេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និងកម្មវិធីអប់រំសុខភាព ដែលជាមធ្យមប្រហែល ៥៦%។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួរពង្រឹងការផ្តល់សេវាសុខភាពផ្លូវចិត្ត សេវាសុខភាព និង កម្មវិធីអប់រំសុខភាពឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។

### ៤. គោលនយោបាយឬគោលការណ៍ស្តីពីការផ្តល់អាហារូបករណ៍

សាកលវិទ្យាល័យបាន និងកំពុងអនុវត្តការផ្តល់អាហារូបករណ៍សិក្សា តាមរយៈគោលការណ៍របស់ខ្លួនយ៉ាងត្រឹមត្រូវ។ គោលការណ៍ផ្តល់អាហារូបករណ៍ រួមមាន អាហារូបករណ៍តាមនិទ្ទេស អាហារូបករណ៍ក្រុមគ្រួសារបុគ្គលិក អាហារូបករណ៍តាមការប្រឡងប្រជែង និង អាហារូបករណ៍តាមរយៈក្រសួងស្ថានប័ននានា ដូចមានបញ្ជាក់លម្អិតនៅក្នុងតារាង ៣.៥.១។

*តារាង ៣.៥.១ ៖ លក្ខខណ្ឌនៃការផ្តល់អាហារូបករណ៍*

| ល.រ | ប្រភេទអាហារូបករណ៍ | និទ្ទេស | តម្លៃ | ចំនួននិស្សិត (នាក់) | ចំនួនឆ្នាំផ្តល់ជូន (ឆ្នាំ) |
|---|---|---|---|---|---|
| ១ | តាមនិទ្ទេស | A | 100% | 30 | 4 |
| | | B | 50% | 50 | 2 |
| | | C | 30% | 100 | 2 |
| ២ | ក្រុមគ្រួសារ | A-E | 20% | មិនកំណត់ | 4 |
| ៣ | ប្រឡងប្រជែង | A-E | 100% | 5 | 4 |
| | | | 50% | 30 | 2 |
| | | | 30% | 250 | 2 |
| ៤ | តាមក្រសួងស្ថាប័ន | A-E | តាមការស្នើ | តាមការជាក់ស្តែង | |

ដោយផ្អែកតាមលក្ខខណ្ឌខាងលើនេះ សាកលវិទ្យាល័យបានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រនៅឆ្នាំ ២០២០ ចំនួន ៣៤២នាក់ ឆ្នាំ២០២១ ចំនួន ៣១៧នាក់ ឆ្នាំ២០២២ ចំនួន ២៩៤នាក់ ឆ្នាំ២០២៣ ចំនួន ២៨៩នាក់ និង ឆ្នាំ២០២៤ ចំនួន ២៩៦នាក់។

## ៥. ការណែនាំឬការតម្រង់ទិសនិស្សិតចូលរៀនថ្មី

សាកលវិទ្យាល័យបានរៀបចំវគ្គតម្រង់ទិសនិស្សិតថ្មីនៅដើមឆ្នាំ គឺចាប់ពីឆ្នាំ២០២៣មក ដោយឡែកចាប់ពីឆ្នាំ២០២០-២០២២ គឺពុំបានរៀបចំវគ្គតម្រង់ទិសនិស្សិតថ្មីនោះទេ ដោយកត្តាការរីករាលដាលនៃជំងឺកូវីដ១៩ ហើយខ្លឹមសារតម្រង់ទិស រួមមាន រចនាសម្ព័ន្ធកម្មវិធីសិក្សា លទ្ធផលសិក្សារំពឹងទុក ប្រព័ន្ធអប់រំ បទប្បញ្ញត្តិនិងច្បាប់សិក្សា បណ្ណាល័យនិងប្រព័ន្ធស្វែងរកព័ត៌មាន សេវាអ៊ីនធឺណែតវ៉ាយហ្វាយ សេវាកម្មសុខភាពនិងសុវត្ថិភាព ការប្រើប្រាស់បរិក្ខារសិក្សា វិធីគ្រប់គ្រងពេលវេលា វិធីសិក្សាសម្រេចលទ្ធផលខ្ពស់ វិធីសាស្ត្រស្វែងរកឯកសារសិក្សា ការចូលរួមសហគមន៍ ការចូលរួមសិក្ខាសាលានិងសន្និសីទ កម្មសិក្សាទស្សនកិច្ចសិក្សា សីលធម៌វិជ្ជាជីវៈ ការប្រើប្រាស់ប្រព័ន្ធអប់រំឌីជីថល វិធានការទប់ស្កាត់ការប្រើប្រាស់ការងាររបស់អ្នកដទៃ ការប្រឹក្សាអាជីព ឱកាសអាហារូបករណ៍និងការរៀនបន្ត។ នៅឆ្នាំ២០២៣ តម្រង់ទិសនិស្សិតបាន ៧១.៤% នៃនិស្សិតថ្មីសរុប ៩៣៨នាក់ និង នៅឆ្នាំ២០២៤ តម្រង់ទិសនិស្សិតថ្មីបាន ៦៩.៣% នៃនិស្សិតថ្មីសរុបចំនួន ៩២៩នាក់។ ជាមធ្យមក្នុងរយៈពេលពីរចុងក្រោយនេះ សាកលវិទ្យាល័យអនុវត្តបាន ៧០.៣៥%។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួរបន្តរៀបចំផែនការណែនាំតម្រង់ទិសនិស្សិតថ្មីដែលពុំទាន់ទទួលបាន ដោយប្រើប្រាស់វិធីសាស្ត្រនិងមធ្យោបាយឱ្យបានច្រើនយ៉ាង ហើយជ្រើសរើសខ្លឹមសារសំខាន់ៗដែលជាជំនួយដល់និស្សិតក្នុងការសិក្សាបន្ត។

*តារាង ៣.៥.២ ៖ ស្ថិតិនិស្សិតថ្មីទទួលបានការណែនាំតម្រង់ទិស*

| ឆ្នាំ | ចំនួននិស្សិតសរុប | ចំនួននិស្សិតចូលរួមតម្រង់ទិស | %និស្សិតចូលរួមការតម្រង់ទិស |
|---|---|---|---|
| ២០២៣ | 938 | 670 | 71.4 |
| ២០២៤ | 929 | 644 | 69.3 |

## ៦. ប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សា

ការផ្តល់ប្រឹក្សាយោបល់លើការសិក្សា គឺមហាវិទ្យាល័យជាអ្នកទទួលបន្ទុក ចំណែកឯការិយាល័យទំនាក់ទំនងអន្តរជាតិ ផ្តល់យោបល់ដល់និស្សិតដែលមានបំណងទៅសិក្សានៅសាកលវិទ្យាល័យដៃគូក្រៅប្រទេស។ ចាប់ពីឆ្នាំ២០២០-២០២៤ សាកលវិទ្យាល័យបានដាក់ចេញនូវកម្មវិធីប្រឹក្សាយោបល់ចំនួន១៣ រួមមាន ជំនាញក្នុងការសិក្សា ការគ្រប់គ្រងពេលវេលា ជំនួយខាងផ្នែកបច្ចេកវិទ្យា ការប្រឹក្សាលើការផ្អាកឬព្យួរការសិក្សា ការចាប់ផ្តើមការសិក្សាថ្មី ប្រព័ន្ធប្រឹក្សាជាមួយគ្រូ/បុគ្គលិក ការផ្លាស់ប្តូរជំនាញ ជំនាញនៃការសិក្សានៅមហាវិទ្យាល័យ ការជ្រើសរើសមុខវិជ្ជាសិក្សា ការបកស្រាយវាយតម្លៃនៃការសិក្សា ការបកស្រាយពីផលប៉ះពាល់នៃការបោះបង់ការសិក្សា ការផ្លាស់ប្តូរការសិក្សានៅក្រៅប្រទេស និង ការសិក្សាតាមប្រព័ន្ធ COIL។ ឆ្នាំសិក្សា ២០២៣-២០២៤ មាននិស្សិតសរុបចំនួន ៩៣៨នាក់ ស្រី ៥០៧នាក់ និង ឆ្នាំសិក្សា ២០២៤-២០២៥ មាននិស្សិតសរុបចំនួន ៩២៩នាក់ ស្រី ៥៣១នាក់ ទទួលបានការប្រឹក្សាយោបល់លើការសិក្សា ហើយមហាវិទ្យាល័យ និង ការិយាល័យទំនាក់ទំនងអន្តរជាតិបានចូលរួមដោះស្រាយចប់ជាស្ថាពរទាំងអស់គ្រប់ករណី ប៉ុន្តែពុំទាន់បានវាយតម្លៃនិងប្រៀបធៀបលទ្ធផលវាយតម្លៃដើម្បីកែលម្អ។ ករណីនេះគប្បីសាកលវិទ្យាល័យត្រូវវាយតម្លៃប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សាជារៀងរាល់ឆ្នាំ និងប្រើប្រាស់លទ្ធផលវាយតម្លៃដើម្បីប្រៀបធៀបនិងកែលម្អ។

## ៧. សកម្មភាពបន្ថែមលើការសិក្សា និង កម្មវិធីហ្វឹកហាត់ការងារ

សាកលវិទ្យាល័យមានសកម្មភាពន្ថែមលើការសិក្សា និងការចុះហ្វឹកហាត់ការងារ តាមរយៈសកម្មភាពសំខាន់ៗ រួមមាន ទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេស កម្មសិក្សា ហាត់ការ ការផ្លាស់ប្តូរនិស្សិតសិក្សា ការចូលរួមសិក្ខាសាលា/វគ្គបណ្តុះបណ្តាល/សន្និសីទ ក្លឹបតន្ត្រី ដូចមានលម្អិតនៅក្រាហ្វិក ៣.៥.៣។

*ក្រាហ្វិក ៣.៥.៣ ៖ ស្ថិតិនិស្សិតបានចូលរួមក្នុងសកម្មភាពបន្ថែមលើការសិក្សា និងហ្វឹកហាត់ការងារ*



ក្រាហ្វិក ៣.៥.៣ បង្ហាញថា ចាប់តាំងពីឆ្នាំ២០២០-២០២៤ និស្សិតបានចូលរួមទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេសចន្លោះពី ៩-៧៩នាក់ កម្មសិក្សា ៩នាក់ ហាត់ការចន្លោះពី ៤-៨៤នាក់ ការផ្លាស់ប្តូរនិស្សិតសិក្សាចន្លោះពី ៥-៤៦នាក់ សិក្ខាសាលា/វគ្គបណ្តុះបណ្តាល/សន្និសីទចន្លោះពី ៥០-១៩០នាក់ និង ក្លឹបតន្ត្រី ៤នាក់។ តាមរយៈក្រាហ្វិកនេះឃើញថានិស្សិតចូលរួមក្នុងការហ្វឹកហាត់ការងារមានចំនួនតិចតួចនៅឡើយនៅតាមឆ្នាំនីមួយៗ និងតាមរយៈការសម្ភាសបន្ថែម និស្សិតបានលើកឡើងថា សាកលវិទ្យាល័យបានជួយសម្របសម្រួលដល់និស្សិតដែលបានស្នើសុំក្នុងកម្មវិធីហ្វឹកហាត់ការងារ ដែលការណ៍នេះមានន័យថាសាកលវិទ្យាល័យពុំទាន់បានរៀបចំគោលការណ៍ហ្វឹកហាត់ការងារច្បាស់លាស់នៅឡើយ។ ជាមួយគ្នានេះ នៅពេលសម្ភាស និយោជកបានស្នើសុំឱ្យសាកលវិទ្យាល័យតម្រូវឱ្យនិស្សិតនៅក្នុងកម្មវិធីចាំបាច់មួយចំនួនឆ្លងកាត់កម្មវិធីហ្វឹកហាត់ការងារ នៅពេលនិស្សិតកំពុងសិក្សា។ ជារួមនិស្សិតមានឱកាស និងបានចូលរួមហ្វឹកហាត់ការងារបន្ថែមលើការសិក្សា ប៉ុន្តែពុំទាន់បានរៀបចំគោលការណ៍។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួររៀបចំគោលការណ៍ ស្តីពីការហ្វឹកហាត់ការងារឱ្យបានច្បាស់លាស់នៅលើកម្មវិធីអប់រំដែលចាំបាច់មួយចំនួន។

## ៨. ការអភិវឌ្ឍអាជីព និង ជួយរកការងារឱ្យនិស្សិត

សាកលវិទ្យាល័យបានជួយនិស្សិតក្នុងការអភិវឌ្ឍអាជីព និងជួយរកការងារឱ្យនិស្សិតធ្វើ តាមរយៈការទំនាក់ទំនងស្ថាប័នដៃគូ មហាវិទ្យាល័យ និង ការិយាល័យពាក់ព័ន្ធមួយចំនួន។ មហាវិទ្យាល័យ និងគ្រូបង្រៀនបានដឹកនាំនិស្សិតចូលរួមសិក្ខាសាលា ស្តីពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងអាជីពការងារក្នុងវិស័យផ្សេងៗ និង បានរៀបចំនិងអញ្ជើញវាគ្មិនធ្វើបឋកថាផ្តល់ជាថ្នាលក្នុងការពិចារណាអាជីព ។ល។ ការិយាល័យផ្តល់ប្រឹក្សានិស្សិតនិងព័ត៌មានដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលរៀបចំប្រវត្តិរូបខណៈនាយកដ្ឋានសិក្សា និងការិយាល័យពាក់ព័ន្ធនានាចូលរួមសកម្មក្នុងការផ្សព្វផ្សាយបន្តពាល់ឱកាសការងារដល់និស្សិតក្នុងគ្រប់បណ្តាញបញ្ជូនព័ត៌មាននៅក្នុងសាកលវិទ្យាល័យ។ ទោះបីជាយ៉ាងណាក៏ដោយ សេវាកម្មរបស់ការិយាល័យផ្តល់ប្រឹក្សានិស្សិតនិងព័ត៌មាន ពុំទាន់បានផ្សព្វផ្សាយទូលំទូលាយដល់និស្សិតគ្រប់ៗគ្នា ចំណែកឯ ការដឹកនាំ និងការណែនាំតាមមហាវិទ្យាល័យក៏ពុំទាន់មានលក្ខណៈជាប្រព័ន្ធ និងការចងក្រងឯកសារសកម្មភាពទាំងឡាយក៏ពុំមានលក្ខណៈច្បាស់លាស់នៅឡើយដែរ។ ក្នុងការជំរុញសេវាកម្មទាំងនេះឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យបន្តផ្សព្វផ្សាយបន្ថែមអំពីសេវាកម្មរបស់ការិយាល័យផ្តល់ប្រឹក្សានិស្សិតនិងព័ត៌មាន និង តួនាទីរបស់មហាវិទ្យាល័យក្នុងការពង្រឹងការអភិវឌ្ឍអាជីពនិងជួយរកការងារឱ្យនិស្សិត តាមរយៈបណ្តាញសង្គមរបស់សាកលវិទ្យាល័យ និង ការផ្តល់ព័ត៌មានតាមមហាវិទ្យាល័យ និងការិយាល័យពាក់ព័ន្ធ ព្រមទាំងតាមដានប្រសិទ្ធភាពនៃការផ្សព្វផ្សាយ។ តាមរយៈការខិតខំប្រឹងប្រែងដូចនេះ នៅឆ្នាំ២០២២មាននិស្សិតចំនួន ២៨៥នាក់ នៅឆ្នាំ២០២៣ មាននិស្សិតចំនួន ៣២០នាក់ និង នៅឆ្នាំ២០២៤ មាននិស្សិតចំនួន ៣៧០នាក់ ទទួលបានការងារធ្វើ។ ជារួមសាកលវិទ្យាល័យបានផ្សព្វផ្សាយនិងជួយរកការងារឱ្យនិស្សិត ប៉ុន្តែពុំទាន់បានតាមដានអំពីលទ្ធផលការងាររបស់និស្សិត។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួរតាមដានអំពីលទ្ធផលការងាររបស់និស្សិត ដើម្បីបន្តកែលម្អវិធានការផ្សេងៗ និងការរៀបចំផែនការអភិវឌ្ឍអាជីពនិស្សិតឱ្យបានច្បាស់លាស់។

## ៩. ការស្រាវជ្រាវអំពីលទ្ធផលនិស្សិតដែលបញ្ចប់ការសិក្សា

សាកលវិទ្យាល័យបានរៀបចំក្រុមការងារ ដោយមានរចនាសម្ព័ន្ធនិងការទទួលខុសត្រូវច្បាស់លាស់ ក្នុង

នោះមានប្រធាន១រូប អនុប្រធាន២ និងសមាជិក ដឹកនាំ រៀបចំការស្រាវជ្រាវ ការកំណត់កម្រងសំណួរ ចំនួនអ្នកឆ្លើយ។ល។ សម្រាប់ការសិក្សាស្រាវជ្រាវនៃឆ្នាំនីមួយៗ ទៅលើនិស្សិតក្រោយបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និង បរិញ្ញាបត្របត្រជាន់ខ្ពស់ ដើម្បីស្វែងយល់ពីភាពជោគជ័យក្នុងការទទួលបានការងារធ្វើរបស់និស្សិត និងរកឱ្យឃើញនូវចំណុចខ្វះខាតសម្រាប់ធ្វើការកែលម្អកម្មវិធីសិក្សា ក៏ដូចជាការបង្រៀននិងរៀន។ ការសិក្សានេះធ្វើឡើងដោយមានលក្ខណៈស្រាវជ្រាវបែបវិទ្យាសាស្ត្រ មានការផ្តោតទៅលើចំនួនឬភាគរយនិស្សិតបញ្ចប់ការសិក្សាបានទទួលការងារធ្វើនៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្ត នៅក្នុងសហគ្រាសធុនតូចមធ្យម កម្រិតប្រាក់បៀវត្សរ៍ ដែលទទួលបានតួនាទីនិងឋានៈ ភាពបន្សុីគ្នានៃផ្នែកទន់និងផ្នែករឹងនៃជំនាញចំណេះដឹងដែលទទួលបានពីសាកលវិទ្យាល័យ ដោយបានរៀបចំជារបាយការណ៍សិក្សាស្រាវជ្រាវ សម្រាប់ឆ្នាំ ២០២២ ឆ្នាំ២០២៣ និង ឆ្នាំ២០២៤។

### ១០. សេវាជួយសហគមន៍ និង សកម្មភាពជួយសង្គមផ្សេងៗ

សាកលវិទ្យាល័យ បានផ្តល់ឱកាសជាច្រើនឱ្យនិស្សិតចូលរួមក្នុងកិច្ចការសហគមន៍ និងធ្វើសកម្មភាពជួយសង្គមក្នុងគ្រប់រូបភាព និង គ្រប់បណ្តាញរបស់សាកលវិទ្យាល័យ តាមរយៈក្លឹបកាកបាទក្រហម ក្លឹបកាយរិទ្ធ និងក្រុមយុវជនរបស់សាកលវិទ្យាល័យ។ និស្សិតបានចូលរួមក្នុងកម្មវិធី អបអរសាទរទិវាសន្តិភាពកម្ពុជា ចិត្តខ្ញុំស្អាតខ្មែរស្អាត អបអរសាទរបាល់ទាត់មិត្តភាពកម្ពុជា-ថៃ ស្ម័គ្រចិត្ត គម្រោងរបស់ដៃគូសហការ ការដាំដើមឈើ មិត្តអប់រំមិត្ត វិជ្ជាសង្គ្រោះបឋម ការជួយដល់និស្សិតងាយរងគ្រោះ ក្រុមគ្រួសារយុវជនកាកបាទក្រហមកម្ពុជា ការប្រមូលមូលនិធិសម្រាប់មន្ទីរពេទ្យគន្ធបុប្ផា សប្បុរសធម៌ និង មនសិការពលរដ្ឋល្អ។ តាមរយៈរបាយការណ៍នៃការអនុវត្តកិច្ចការសហគមន៍ និងធ្វើសកម្មភាពជួយសង្គមក្នុងគ្រប់រូបភាពឃើញមាននិស្សិតចូលរួមចំនួន ៧៧០នាក់ នៅក្នុងឆ្នាំ២០២២ ៥១០នាក់ នៅក្នុងឆ្នាំ២០២៣ និង ៨៥៦នាក់ នៅក្នុងឆ្នាំ ២០២៤។ តាមលទ្ធផលស្ទង់មតិនិស្សិត ក្នុងទំហំសំណាក ៦៦១នាក់ មាន ៧៦% បានបញ្ជាក់ថាទទួលបានឱកាសចូលរួមសកម្មភាពសង្គមនិងសេវាសហគមន៍ និង តាមរយៈការសម្ភាស និស្សិតភាគច្រើនបានឯកភាពថាបានចូលរួមនៅក្នុងកិច្ចការទាំងអស់នេះដែរ។ ជារួម និស្សិតបានចូលរួមសកម្មភាពសង្គម និងសេវាសហគមន៍ ប៉ុន្តែពុំទាន់បានរៀបចំឱ្យមានផែនការច្បាស់លាស់នោះទេ ដែលការណ៍គប្បីសាកលវិទ្យាល័យគួររៀបចំផែនការក្នុងការផ្តល់សេវាសហគមន៍ និងសកម្មភាពជួយសង្គមប្រចាំឆ្នាំ ដោយបញ្ជាក់នូវចំនួនសកម្មភាព ចំនួនសមាសភាពអ្នកចូលរួម និង ប្រភពចំណូលចំណាយឱ្យបានច្បាស់លាស់។

### ១១. គោលនយោបាយ ឬគោលការណ៍ និង នីតិវិធី ក្នុងការដោះស្រាយបណ្តឹងតវ៉ារបស់និស្សិត

សាកលវិទ្យាល័យបាននិងកំពុងអនុវត្តគោលការណ៍ និង នីតិវិធីស្តីពីការដោះស្រាយបណ្តឹងតវ៉ារបស់និស្សិតចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីទទួលយកនូវរាល់ការរិះគន់ស្ថាបនាពីគ្រប់ភាគីពាក់ព័ន្ធរួមមាន និស្សិត អាណាព្យាបាល គ្រូបង្រៀន និង និយោជក។ ការទទួលការតវ៉ា រួមមាន ការទាក់ទងសេវាសិក្សា កម្មវិធីសិក្សា ការបង្រៀនរបស់គ្រូ សេវាគាំទ្រ សេវាផ្តល់ព័ត៌មាន ការប្រឹក្សាយោបល់ ហេដ្ឋារចនាសម្ព័ន្ធសេវាទូទៅ (សណ្តាប់ធ្នាប់ សន្តិសុខ អនាម័យ...) ។ ក្រុមប្រឹក្សាវិន័យជាអ្នកគ្រប់គ្រង និង ការិយាល័យប្រឹក្សានិស្សិតនិងព័ត៌មានគាំទ្រសម្របសម្រួលទទួលការតវ៉ា និង ភាគីពាក់ព័ន្ធ រួមមាន មហាវិទ្យាល័យ នាយកដ្ឋានការិយាល័យ ក្នុងកម្រិតបច្ចេកទេសជាអ្នកទទួលដោះស្រាយទៅតាមប្រភេទនៃការតវ៉ា។ លទ្ធផលនៃការតវ៉ាអាចបញ្ជូនតាមក្នុងរូបភាពផ្ទាល់មាត់ និង/ឬ លាយលក្ខណ៍អក្សរ។ រីឯរយៈពេលនៃការកំណត់ដោះស្រាយ

មានចែងច្បាស់នៅក្នុងគោលការណ៍ស្ដីពីការតវ៉ា ពេលគឺរាល់ការតវ៉ារបស់និស្សិតដែលមានចែងនៅក្នុងគោលការណ៍ត្រូវបានដោះស្រាយក្នុងរយៈពេលមិនលើសពី៧ (ប្រាំពីរ) ថ្ងៃនៃប្រតិទិនការងារ (ថ្ងៃចន្ទដល់ថ្ងៃសៅរ៍) រីឯការតវ៉ាទាំងឡាយណាដែលមិនមានចែងក្នុងគោលការណ៍នោះត្រូវដោះស្រាយប្រែប្រួលទៅតាមថេរៈវេលានិងប្រភេទនៃការតវ៉ា។ ការតវ៉ាចែកជាពីរប្រភេទធំៗ គឺ ការតវ៉ាសេវាសិក្សា និង ការតវ៉ាសេវាគាំទ្រ។ រាល់ការតវ៉ា និងដំណោះស្រាយត្រូវបានរៀបចំជារបាយការណ៍ច្បាស់លាស់ទៅតាមឆមាស/វគ្គសិក្សានីមួយៗ។ ក្នុងឆ្នាំសិក្សា ២០២១-២០២២ មានចំនួន៨ករណីសម្រាប់ឆមាសទី២ ឆ្នាំសិក្សា២០២២-២០២៣ មានចំនួន៧ករណីសម្រាប់ឆមាសទី១ និង២៨ករណីសម្រាប់ឆមាសទី២ និង ឆ្នាំសិក្សា២០២៣-២០២៤ មានចំនួន៩ករណីសម្រាប់ឆមាសទី១។ រាល់ការតវ៉ាខាងលើនេះ គឺសាកលវិទ្យាល័យដោះស្រាយបានទាំងអស់។

**១២. គោលការណ៍ស្ដីពីភាពជោគជ័យក្នុងការសិក្សា ការថែរក្សានិស្សិត និង អត្រាបញ្ចប់ការសិក្សា**

សាកលវិទ្យាល័យមាននិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យថ្នាក់បរិញ្ញាបត្រតាមជំនាន់នីមួយៗ ដូចខាងក្រោម។

- **ជំនាន់ទី១៧** : មានអត្រានិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៥៩% និង អត្រានិស្សិតបោះបង់ ៤១% នៃនិស្សិតសរុបចំនួន ៦៥៣នាក់។
- **ជំនាន់ទី១៨** : មានអត្រានិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៥៩% និង អត្រានិស្សិតបោះបង់ ៤១% នៃនិស្សិតសរុបចំនួន ៩៨៤នាក់។
- **ជំនាន់ទី១៩** : មានអត្រានិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៨៨% និង អត្រានិស្សិតបោះបង់ ១២% នៃនិស្សិតសរុបចំនួន ៦៤០នាក់។
- **ជំនាន់ទី២០** : មានអត្រានិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៥៥% និង អត្រានិស្សិតបោះបង់ ៤៥% នៃនិស្សិតសរុបចំនួន ៥០៥នាក់។

*ក្រាហ្វិក ៣.៥.៤ ៖ អត្រានិស្សិតថ្នាក់បរិញ្ញាបត្របញ្ចប់ការសិក្សា និងបោះបង់*



ក្រាហ្វិក ៣.៥.៤ បង្ហាញថា អត្រានិស្សិតបរិញ្ញាបត្របញ្ចប់ការសិក្សាចាប់ពីជំនាន់ទី១៧ ទៅដល់ជំនាន់ទី២០ មានភាគរយចន្លោះពី ៥៥%-៨៨% ដែលជាមធ្យមក្នុងមួយជំនាន់មានប្រហែលជា ៦៥.២៥% និង អត្រានិស្សិតបរិញ្ញាបត្របោះបង់ មានភាគរយចន្លោះពី ១២%-៤៥% ដែលជាមធ្យមក្នុងមួយជំនាន់មានប្រហែលជា ៣៤.៧៥%។

សាកលវិទ្យាល័យមាននិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យថ្នាក់បរិញ្ញាបត្ររង តាមជំនាន់នីមួយៗ ដូចខាងក្រោម។

- **ជំនាន់ទី១៧** : មានអត្រានិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៧៩% និង អត្រានិស្សិតបោះបង់ ២១% នៃនិស្សិតសរុបចំនួន ២៩៣នាក់។
- **ជំនាន់ទី១៨** : មានអត្រានិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៧៦% និង អត្រានិស្សិតបោះបង់ ២៤% នៃនិស្សិតសរុបចំនួន ៣៥២នាក់។
- **ជំនាន់ទី១៩** : មានអត្រានិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៨៤% និង អត្រានិស្សិតបោះបង់ ១៦% នៃនិស្សិតសរុបចំនួន ៣៥៤នាក់។

*ក្រាហ្វិក ៣.៥.៥ ៖ អត្រានិស្សិតថ្នាក់បរិញ្ញាបត្ររងបញ្ចប់ការសិក្សា និងបោះបង់*




ក្រាហ្វិក ៣.៥.៥ បង្ហាញថា អត្រានិស្សិតបរិញ្ញាបត្ររងបញ្ចប់ការសិក្សាចាប់ពីជំនាន់ទី១៧ ទៅដល់ជំនាន់ទី១៩ មានភាគរយចន្លោះពី ៧៦%-៨៤% ដែលជាមធ្យមក្នុងមួយជំនាន់មានប្រហែលជា ៧៩.៦៧% និង អត្រានិស្សិតបរិញ្ញាបត្របោះបង់ មានភាគរយចន្លោះពី ១៦%-២៤% ដែលជាមធ្យមក្នុងមួយជំនាន់មានប្រហែលជា ២០.៣៣%។

ជាសរុបរួមសាកលវិទ្យាល័យមានអត្រានិស្សិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងបញ្ចប់ការសិក្សាដោយជោគជ័យជាមធ្យមប្រហែលជា ៧២.៤៦% និង មានអត្រានិស្សិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងបោះបង់ចោលការសិក្សាជាមធ្យមប្រហែល ២៧.៥៤%។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួរកែលម្អគោលការណ៍ ស្តីពី

ភាពជោគជ័យក្នុងការសិក្សា ការថែរក្សានិស្សិត និង អត្រាបញ្ចប់ការសិក្សា ដោយប្រើប្រាស់លទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនិស្សិតដែលបោះបង់ចោលការសិក្សា ផ្ទេរចូល និងផ្ទេរចេញ ដើម្បីឱ្យអត្រាបញ្ចប់ការសិក្សាមានការកើនឡើង និងការបោះបង់ថយចុះជាបន្តបន្ទាប់។

**ចំណុចខ្លាំង**

- អនុវត្តការជ្រើសរើសនិស្សិតស្របតាមគោលការណ៍ដែលបានកំណត់
- បានផ្តល់អាហារូបករណ៍អនុលោមគោលការណ៍ដែលបានកំណត់
- បានធ្វើការស្រាវជ្រាវលើជំនាន់និស្សិតដែលបានបញ្ចប់ការសិក្សាប្រចាំឆ្នាំ
- បានដោះស្រាយការតវ៉ារបស់និស្សិត។

**ចំណុចអនុវត្តបានល្អ**

- បុគ្គលិកគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិភាគច្រើនមានគុណវុឌ្ឍិស្របតាមតួនាទីភារកិច្ច
- និស្សិតភាគច្រើនពេញចិត្តលើសេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និងកម្មវិធីអប់រំសុខភាព
- និស្សិតចូលរៀនថ្មីភាគច្រើនទទួលបានការណែនាំតម្រង់ទិស
- និស្សិតមានឱកាស និងបានចូលរួមហ្វឹកហាត់ការងារបន្ថែមលើការសិក្សា ប៉ុន្តែពុំទាន់បានរៀបចំគោលការណ៍
- បានផ្សព្វផ្សាយនិងជួយរកការងារឱ្យនិស្សិត ប៉ុន្តែពុំទាន់បានតាមដានអំពីលទ្ធផលការងាររបស់និស្សិត
- និស្សិតបានចូលរួមសកម្មភាពសង្គម និងសេវាសហគមន៍ ប៉ុន្តែពុំទាន់បានរៀបចំឱ្យមានផែនការ
- និស្សិតភាគច្រើនបញ្ចប់ការសិក្សាធៀបទៅនឹងចំនួននិស្សិតតាមជំនាន់នីមួយៗ។

**ចំណុចកែលម្អ**

- បានប្រឹក្សាយោបល់លើការសិក្សារបស់និស្សិត ប៉ុន្តែពុំទាន់បានវាយតម្លៃនិងប្រៀបធៀបលទ្ធផលវាយតម្លៃដើម្បីកែលម្អ។

**សេចក្តីសន្និដ្ឋាន**

ជារួមសាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា៥។ សាកលវិទ្យាល័យបានអនុវត្តការជ្រើសរើសនិស្សិត និងការផ្តល់អាហារូបករណ៍ ស្របតាមគោលការណ៍ដែលបានកំណត់ ព្រមទាំងបានធ្វើការស្រាវជ្រាវលើជំនាន់និស្សិតដែលបានបញ្ចប់ការសិក្សាប្រចាំឆ្នាំ និង បានដោះស្រាយរាល់ការតវ៉ារបស់និស្សិត។ បុគ្គលិកគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិភាគច្រើនមានគុណវុឌ្ឍិស្របតាមតួនាទីភារកិច្ច។ និស្សិតភាគច្រើនពេញចិត្តលើសេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និងកម្មវិធីអប់រំសុខភាព។ និស្សិតចូលរៀនថ្មីភាគច្រើនទទួលបានការណែនាំតម្រង់ទិស។ និស្សិតមានឱកាស និងបានចូលរួមហ្វឹកហាត់ការងារបន្ថែមលើការសិក្សា ប៉ុន្តែពុំទាន់បានរៀបចំគោលការណ៍ហ្វឹកហាត់ការងារ។ សាកលវិទ្យាល័យបានផ្សព្វផ្សាយនិងជួយរកការងារឱ្យនិស្សិត ប៉ុន្តែពុំទាន់បានតាមដានអំពីលទ្ធផលការងាររបស់និស្សិត។ និស្សិតបានចូលរួមសកម្មភាពសង្គម និងសេវាសហគមន៍ ប៉ុន្តែពុំទាន់បានរៀបចំឱ្យមានផែនការច្បាស់លាស់។ អត្រានិស្សិតភាគច្រើនបានបញ្ចប់ការសិក្សាតាមជំនាន់នីមួយៗ។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា៥ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវ៖

- វាយតម្លៃប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សាជារៀងរាល់ឆ្នាំ និងប្រើប្រាស់លទ្ធផលវាយតម្លៃដើម្បីប្រៀបធៀបនិងកែលម្អ។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា៥ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរ៖

- បង្កើនបុគ្គលិកសេវានិស្សិតពេញម៉ោងបន្ថែមទៀត ដែលមានកម្រិតគុណវុឌ្ឍិនិងបទពិសោធន៍ខ្ពស់ ដើម្បីជានាស្ថិរភាពនៃការងារ និងការឆ្លើយតបទៅនឹងតម្រូវការនិស្សិត
- វាយតម្លៃពីប្រសិទ្ធភាពលើការផ្តល់សេវាសុខភាពផ្លូវចិត្ត សេវាសុខភាព និង កម្មវិធីអប់រំសុខភាព ដើម្បីកែលម្អគុណភាពនៃសេវាកម្ម
- ណែនាំតម្រង់ទិសនិស្សិតថ្មីឱ្យបានទូលំទូលាយ
- រៀបចំគោលការណ៍ ស្តីពីការហ្វឹកហាត់ការងារឱ្យបានច្បាស់លាស់ឆ្លើយតបទៅនឹងតម្រូវការនៃកម្មវិធីអប់រំ
- តាមដានអំពីលទ្ធផលការងាររបស់និស្សិត ដើម្បីបន្តកែលម្អវិធានការផ្សេងៗ និងការរៀបចំផែនការអភិវឌ្ឍអាជីពនិស្សិតឱ្យបានច្បាស់លាស់
- រៀបចំផែនការក្នុងការផ្តល់សេវាសហគមន៍ និងសកម្មភាពជួយសង្គមប្រចាំឆ្នាំឱ្យបានច្បាស់លាស់
- សិក្សាអំពីមូលហេតុនៃការបោះបង់ចោលការសិក្សា ផ្ទេរចូល និងផ្ទេរចេញ ដើម្បីរៀបចំកែលម្អគោលការណ៍ ស្តីពីភាពជោគជ័យក្នុងការសិក្សា ការថែរក្សានិស្សិត និង អត្រាបញ្ចប់ការសិក្សា។

## ៣.៦. ស្តង់ដា៦៖ ធនធានសិក្សា

### របកគំហើញ

#### ១. បណ្ណាល័យមានកន្លែងអានគ្រប់គ្រាន់និងបរិយាកាសអំណោយផល

បណ្ណាល័យមានក្រឡាផ្ទៃ ១ ៦៤១.៨៥ ម៉ែត្រការ៉េ ដែលក្នុងនោះមានបន្ទប់អានចំនួន៣ ដោយបន្ទប់អានទី១មានទំហំ ៧៦.៤២ ម៉ែត្រការ៉េ បន្ទប់អានទី២ មានទំហំ ៦៧.១៥ ម៉ែត្រការ៉េ បន្ទប់អានទី៣ មានទំហំ ៦៧.៤៨ ម៉ែត្រការ៉េ និង បន្ទប់ VIP មួយ មានទំហំ ៩៥.០៩ម៉ែត្រការ៉េ។ ក្រៅពីនេះមានបន្ទប់ទីធ្លាដាក់ទូសៀវភៅអាន មានទំហំ ៩៧៨.២៦ម៉ែត្រការ៉េ បន្ទប់បុគ្គលិកមានទំហំ ៥៨.៧១ ម៉ែត្រការ៉េ បន្ទប់ដាក់កាតាប និងកុំព្យូទ័រមានទំហំ ១០១.១៤ ម៉ែត្រការ៉េ បន្ទប់ហ្វូតូកូពី មានទំហំ ៩៣.២៣ ម៉ែត្រការ៉េ និងច្រកចេញចូលបណ្ណាល័យមានទំហំ ១០៤.៣៧ ម៉ែត្រការ៉េ។ របាយការណ៍បញ្ជីវត្តមាននិស្សិតចូលអានប្រចាំខែ និងតាមវេនឆ្នាំ២០២៥ បង្ហាញថា ទិន្នន័យនិស្សិតចូលអានខ្ពស់បំផុតមានចំនួន ៣៩៥នាក់/១វេន។ ដូចនេះផលធៀបនៃក្រឡាផ្ទៃបណ្ណាល័យនឹងចំនួននិស្សិតចូលអានខ្ពស់បំផុតក្នុង១វេនមានចំនួន ៤.១០ម៉ែត្រការ៉េ/និស្សិតម្នាក់។ ជារួមបណ្ណាល័យមានទំហំសមស្របនឹងចំនួននិស្សិតចូលអានតាមវេន ដោយមានបរិយាកាសល្អ ទំនើប មានផាសុកភាព ស្ងប់ស្ងាត់ អំណោយផលដល់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន។

#### ២. ធនធានសៀវភៅនៅក្នុងបណ្ណាល័យ

សាកលវិទ្យាល័យ មានសៀវភៅគោល ឯកសារយោង សៀវភៅទូទៅ កាសែត ទស្សនាវដ្តី និងឯកសារ

ស្រាវជ្រាវចំនួន ២៦ ២៤៦ក្បាល ដែលក្នុងនោះមានសៀវភៅទូទៅចំនួន ១៩ ៣៨៣ក្បាល សៀវភៅតាមកម្មវិធីសិក្សាមានចំនួន ៦៨៨ក្បាល (សៀវភៅគោល ៣៦៥ក្បាល និងឯកសារយោងមានចំនួន ៣២៣ក្បាល) ទស្សនាវដ្តី កាសែត និងព្រឹត្តិបត្រការងារតាមស្ថាប័នមានចំនួន ២ ៥៨០ (កាសែត ៤១៥ និងទស្សនាវដ្តី ២ ១៦៥ក្បាល) អត្ថបទស្រាវជ្រាវរបស់និស្សិតមានចំនួន ៣ ៩៩៥ អត្ថបទ (សារណា ៨៥ និងកិច្ចការស្រាវជ្រាវ ៣ ៩១០)។ សាកលវិទ្យាល័យមានឯកសារអេឡិចត្រូនិក E-Books Library មានចំនួនសរុប ១ ៣៧១ក្បាល ក្នុងនោះមហាវិទ្យាល័យពាណិជ្ជកម្ម និងទេសចរណ៍មានចំនួន ៥០៨ក្បាល មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ចមានចំនួន ៣៧៨ក្បាល មហាវិទ្យាល័យវិទ្យាសស្ត្រព័ត៌មានវិទ្យាមានចំនួន ២០៥ក្បាល មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំមានចំនួន ៥១ក្បាល និង Assignment and Thesis មានចំនួន ២៣១ក្បាល។ តាមការសង្កេតនិងពិនិត្យសៀវភៅតម្កល់ក្នុងបណ្ណាល័យ ការសម្ភាសបុគ្គលិក និងពិនិត្យបញ្ជីឈ្មោះសៀវភៅក្នុងបណ្ណាល័យបង្ហាញថា សៀវភៅ ឯកសាយោង ទស្សនាវដ្តី និងឯកសារស្រាវជ្រាវភាគច្រើនមានអាយុកាលលើសពីដប់ឆ្នាំ។ គ្រូបង្រៀនមួយចំនួនបានសំណូមពរឱ្យបន្ថែមសៀវភៅគោល ឯកសាយោងជាពិសេសទស្សនាវដ្តីវិទ្យាសាស្ត្រថ្មីៗទាំង Hard និង Soft Copy ក្នុងបណ្ណាល័យសម្រាប់បម្រើការសិក្សាស្រាវជ្រាវរបស់និស្សិត គ្រូបង្រៀន ជាពិសេសសម្រាប់ គ្រូបង្រៀន និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ។

### ៣. បណ្ណារក្សនិងបុគ្គលិកបម្រើការក្នុងបណ្ណាល័យ

បណ្ណាល័យមានបុគ្គលិកសរុបចំនួន ៦នាក់ ក្នុងនោះ មានបណ្ណារក្ស ១នាក់ បុគ្គលិកទទួលបន្ទុកការងារសេវាកម្មឯកសារយោង ១នាក់ បុគ្គលិកទទួលបន្ទុកខ្ចី និងសងសៀវភៅ ១នាក់ បុគ្គលិកទទួលបន្ទុកផ្តល់ជំនួយបច្ចេកទេសនៃការប្រើប្រាស់បណ្ណាល័យ ១នាក់ បុគ្គលិកទទួលបន្ទុកការងារសេវាកម្មសៀវភៅនាំចេញ-នាំចូល ១នាក់ និងបុគ្គលិកទទួលបន្ទុកការងាររដ្ឋបាល ១នាក់។ ប៉ុន្តែជាក់ស្តែង បច្ចុប្បន្ននេះបណ្ណាល័យមានបុគ្គលិកចំនួន ៥នាក់ កំពុងបម្រើការក្នុងបណ្ណាល័យ។ បណ្ណារក្សបានទទួលការបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងបណ្ណាល័យ ចំណែកឯបុគ្គលិកផ្សេងទៀតបានទទួលការបណ្តុះបណ្តាលផ្ទៃក្នុង ស្តីពីការគ្រប់គ្រងបណ្ណាល័យពីបណ្ណារក្ស និងអតីតបណ្ណារក្ស។ តាមការសម្ភាស និងការស្ទង់មតិនិស្សិតបង្ហាញថា និស្សិតភាគច្រើនយល់ថាបុគ្គលិកបម្រើការក្នុងបណ្ណាល័យមានសមត្ថភាពពុំសូវពេញលេញក្នុងការគាំទ្រសេវាបណ្ណាល័យ។

### ៤. ពេលវេលាបម្រើសេវាកម្មរបស់បណ្ណាល័យ

បណ្ណាល័យបើកបម្រើអតិថិជន គ្រូបង្រៀន និស្សិត បុគ្គលិក និងសាធារណជន ពីថ្ងៃចន្ទ ដល់ថ្ងៃសៅរ៍ ចាប់ពីម៉ោង ០៨:០០នាទី ដល់ម៉ោង ១៩:៣០នាទី និង ថ្ងៃអាទិត្យ ចាប់ពីម៉ោង ០៩:០០នាទី ដល់ម៉ោង ១៦:០០នាទី។ តាមលទ្ធផលនៃការស្ទង់មតិក្នុងទំហំសំណាកគ្រូបង្រៀន ១០៤នាក់ មាន ៨៤.៦% យល់ថា ចំនួនម៉ោងបើកបម្រើសេវាបណ្ណាល័យស្របទៅនឹងតម្រូវការ។ បើតាមការស្ទង់មតិនិស្សិត ក្នុងទំហំសំណាក ៦៦១នាក់ មាននិស្សិត ៧៩.៣% យល់ថា ចំនួនម៉ោងបើកបម្រើសេវាបណ្ណាល័យស្របទៅនឹងតម្រូវការ។ តាមការសម្ភាស និស្សិត និងគ្រូបង្រៀនបង្ហាញថា គ្រូបង្រៀន និងនិស្សិតស្ទើរតែទាំងអស់យល់ថា ពេលវេលាបើកបម្រើសេវាបណ្ណាល័យរបស់សាកលវិទ្យាល័យឆ្លើយតបនឹងតម្រូវការរបស់និស្សិត និងគ្រូបង្រៀន។

### ៥. ការណែនាំ និងតម្រង់ ទិសអំពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ

សាកលវិទ្យាល័យបានរៀបចំកម្មវិធីតម្រង់ទិស ស្តីពីរបៀបប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗដោយផ្តោតលើចំណុចសំខាន់មួយចំនួន ដូចជា ពេលវេលាបើកនិងបិទបណ្ណាល័យ ធនធានសិក្សាក្នុង

បណ្ណាល័យ សេវាបណ្ណាល័យ គោលការណ៍ប្រើប្រាស់ និងគោលការណ៍ខ្ចីសង។ល។ តាមរបាយការណ៍ ស្តីពីការតម្រង់ទិសឆ្នាំ២០២៥បង្ហាញថា ការរៀបចំកម្មវិធីតម្រង់ទិសនិស្សិតចូលរៀនថ្មីធ្វើឡើងក្នុងខែមករា ដោយកម្មវិធីធ្វើឡើងចំនួនបីវេន (ព្រឹក រសៀល និងល្ងាច) ដែលមាននិស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចូលរួមសរុប ២៥៤នាក់។ តាមការសម្ភាសប្រធានបណ្ណាល័យបង្ហាញថា ការណែនាំតម្រង់ទិស ស្តីពីបណ្ណាល័យធ្វើជារៀងរាល់ឆ្នាំសម្រាប់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។ នាពេលបច្ចុប្បន្ននេះបណ្ណាល័យពុំទាន់បានការតម្រង់ទិសស្តីពីសេវាបណ្ណាល័យដល់គ្រូបង្រៀនឱ្យបានទូលំទូលាយនៅឡើយ ប៉ុន្តែគ្រោងនឹងធ្វើនាពេលអនាគតសម្រាប់គ្រូបង្រៀនទាំងអស់។ តាមការសម្ភាសគ្រូបង្រៀនបានបង្ហាញថា គ្រូបង្រៀនភាគច្រើនពុំទាន់ទទួលបានការណែនាំតម្រង់ទិសអំពីការប្រើប្រាស់សេវាបណ្ណាល័យ។ ជារួម សាកលវិទ្យាល័យបានរៀបចំការណែនាំតម្រង់ទិសសម្រាប់និស្សិតទើបចូលរៀនថ្មី ហើយនិស្សិតស្ទើតែទាំងអស់បានទទួលការណែនាំតម្រង់ទិសពីការប្រើប្រាស់បណ្ណាល័យ ទោះយ៉ាងណាគ្រូបង្រៀនភាគច្រើនពុំទាន់ទទួលបានការណែនាំតម្រង់ទិសពីការប្រើប្រាស់បណ្ណាល័យនៅឡើយ។

### ៦. ប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិក (E-library)

បណ្ណាល័យអេឡិចត្រូនិកមានកុំព្យូទ័រសរុបចំនួន ២១គ្រឿង ក្នុងនោះបណ្ណាល័យមានកុំព្យូទ័រសម្រាប់បុគ្គលិក ០៣ គ្រឿង កុំព្យូទ័រសម្រាប់ស្វែងរកសៀវភៅចំនួន ០៤គ្រឿង និងសម្រាប់និស្សិតស្រាវជ្រាវចំនួន ១៧គ្រឿង។ បណ្ណាល័យមានសៀវភៅអេឡិចត្រូនិក (E-books Library) ១ ១៤២ក្បាល និងមាន Assignment and Thesis ចំនួន ២៣១ អត្ថបទ បន្ថែមទៀត ។ និស្សិតនិងគ្រូបង្រៀនស្ទើតែទាំងអស់មានសិទ្ធប្រើប្រាស់ E-books ក្នុងតែបណ្ណាល័យប៉ុណ្ណោះ ពុំអាចទាញយកសៀវភៅ និងអត្ថបទស្រាវជ្រាវទាំងនោះពីចម្ងាយបានឡើយ។ តាមការសង្កេតជាក់ស្តែង E-books Library និងការសម្ភាសជាមួយបណ្ណារក្ស និស្សិត និងគ្រូបង្រៀនបង្ហាញថា សេវាបណ្ណាល័យអេឡិចត្រូនិករបស់បណ្ណាល័យស្ថិតត្រឹមកម្រិត Intranet ពុំទាន់អភិវឌ្ឍន៍ជាបណ្ណាល័យអេឡិចត្រូនិកពេញលេញ។ គ្រូបង្រៀនមួយចំនួនបានស្នើសុំឱ្យបណ្ណាល័យបន្ថែមសៀវភៅ និងទស្សនាវដ្តីស្រាវជាវ (Soft Copy) ថ្មីៗបន្ថែមទៀតក្នុងបណ្ណាល័យអេឡិចត្រូនិក ដើម្បីបម្រើឱ្យការសិក្សាស្រាវជ្រាវរបស់គ្រូបង្រៀន និងនិស្សិត ។

### ៧. ការធ្វើផែនការបណ្ណាល័យ

នៅក្នុងរបាយការណ៍ ស្តីពីផែនការថវិកាឆ្នាំ២០២៥ ផែនការបណ្ណាល័យគ្របដណ្តប់ ជាពិសេសទៅលើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិកបម្រើការបណ្ណាល័យ និងរៀបចំនិងធ្វើឱ្យប្រសើរឡើងវិញនូវប្រព័ន្ធ E-Library។ នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ ថវិកាសរុបសម្រាប់អភិវឌ្ឍផ្នែកបណ្ណាល័យចំនួន ៥០០ដុល្លារ (ការបណ្តុះបណ្តាលបុគ្គលិក និងសេវាបណ្ណាល័យនិងដំណើរការល្អ)។ តាមការសម្ភាសបុគ្គលិកបណ្ណាល័យបង្ហាញថា ចំនួនថវិកាសម្រាប់ការប្រើប្រាស់ក្នុងបណ្ណាល័យត្រូវបានប្រើប្រាស់ប្រហែល ៧០% ទៅ ៨០%។ ថវិកាភាគច្រើនប្រើប្រាស់ទៅលើសម្ភារ ឧបករណ៍ និងការអភិវឌ្ឍន៍បច្ចេកវិទ្យា Software ក្នុងបណ្ណាល័យជាដើម ។ ដោយសាពុំទាន់មានតម្រូវការទិញសៀវភៅចូល ទើបកន្លងមកពុំទាន់ទិញសៀវភៅចូលបន្ថែមថ្មីៗ។ ទោះយ៉ាងណា បណ្ណាល័យបានទទួលសៀវភៅ ទស្សនាវដ្តី លិខិតបទដ្ឋាន តាមរយៈការឧបត្ថម្ភពីស្ថាប័នផ្សេងៗជាដៃគូរ។

### ៨. បន្ទប់ពិសោធន៍ទូទៅ និងឯកទេស

សាកលវិទ្យាល័យមានបន្ទប់អនុវត្តទូទៅ និងឯកទេស ដូចជា ១. Computer Science Lab, Floor 7 (មានកុំព្យូទ័រចំនួន ៤១គ្រឿង និងកុំព្យូទ័រមេចំនួន ២គ្រឿង) ២. Accounting Lab, Floor 7 (មានកុំព្យូទ័រចំនួន ៥១គ្រឿង) ៣. Big Lab, Floor 5 (មានកុំព្យូទ័រចំនួន ៦០គ្រឿង) ៤. Small Lab, Floor 5 (មានកុំព្យូទ័រចំនួន ៤៤គ្រឿង) ៥. Repair Lab, Floor 7 (មានកុំព្យូទ័រចំនួន ១១គ្រឿង)។ ក្រៅពីនេះសាកលវិទ្យាល័យក៏មានថ្នាក់រៀនឆ្លាតវៃសម្រាប់ជំនាញគណនេយ្យ និងកុំព្យូទ័រផងដែរ។ តាមការសង្កេតបង្ហាញថា បន្ទប់នីមួយៗប្រដាប់ដោយបរិក្ខាពេញលេញសម្រាប់បម្រើឱ្យការបង្រៀន និងរៀន។ តាមការសម្ភាសនិស្សិត និងគ្រូបង្រៀនបង្ហាញថា គ្រូបង្រៀន និងនិស្សិតស្ទើតែទាំងអស់យល់ថា បន្ទប់អនុវត្តបំពាក់ដោយប្រដាប់បរិក្ខាទំនើបពេញលេញសម្រាប់ការបង្រៀននិងរៀន។ តាមរយៈលទ្ធផលនៃការស្ទង់មតិរបស់និស្សិត និងគ្រូបង្រៀនបង្ហាញថា និស្សិត ៧២.៣% និងគ្រូបង្រៀន ៨៨.៨% យល់ថាបន្ទប់អនុវត្តន៍ ឆ្លើយតបតម្រូវការនៃកម្មវិធីអប់រំបានគ្រប់គ្រាន់។

### ៩. ផែនការអភិវឌ្ឍបន្ទប់ពិសោធន៍/អនុវត្តន៍

តាមផែនការយុទ្ធសាស្ត្រឆ្នាំ (២០២០-២០២៥) ការិយាល័យហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាបានសហការជាមួយគ្រប់ ការិយាល័យ នាយកដ្ឋាន និងមហាវិទ្យាល័យ ដើម្បីធ្វើគម្រោងកែលម្អ Hardware & Software។ ក្នុងឆ្នាំ២០២៤ តាមរយៈគម្រោង HEIP (Higher Education Improvement Project) និងថវិកាបដិភាគ ៥% របស់សាកលវិទ្យាល័យ បានកែលម្អនិងបំពេញបន្ថែមនូវឧបករណ៍បច្ចេកវិទ្យាឌីជីថល ដើម្បីបំពេញតម្រូវការ និងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល។ តាមការពិនិត្យបង្ហាញថា សាកលវិទ្យាល័យបានអនុវត្តតាមផែនការរបស់ខ្លួនស្ទើតែទាំងស្រុង ។

*តារាង ៣.៦.១ ៖ ការអភិវឌ្ឍបន្ទប់អនុវត្តន៍តាមរយៈគម្រោង HEIP*

| ល.រ | ការបរិយាយ | ២០២២ | | ២០២៤ | |
|---|---|---|---|---|---|
| | | ផែនការ | ជាក់ស្តែង | ផែនការ | ជាក់ស្តែង |
| ១ | ឧបករណ៍ពិសោធន៍ | 3 Labs (HEIP) | 3 Labs (HEIP) | ផ្លាស់ប្តូរឧបករណ៍ LCD ចំនួន ១០ គ្រឿងដែលមានអាយុកាលយូរតាមបន្ទប់រៀន | បានពិនិត្យគ្រប់LCDក្នុងបន្ទប់សិក្សាគុណភាពនៅល្អអាចបន្តប្រើប្រាស់បាន |
| ២ | សម្ភារបម្រើឱ្យការពិសោធន៍ | 3 Labs (HEIP) | 3 Labs (HEIP) | ផ្លាស់ប្តូរកុំព្យូទ័រ ២០ គ្រឿង Computer នឹងត្រូវប្តូរក្នុងបន្ទប់ពិសោធន៍ (Big Labs) | បានពិនិត្យជាក់ស្តែង គ្រប់កំព្យូទ័រក្នុងបន្ទប់ Lab មានគុណភាពនៅល្អអាចបន្តប្រើប្រាស់បាន |

### ១០. ការបណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធន៍/អនុវត្តន៍

ការិយាល័យហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា មានបុគ្គលិកសរុបចំនួន ៥រូប ក្នុងនោះមានកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់និងមានបទពិសោធន៍ ៣-៥ឆ្នាំ ចំនួន ១រូប និង មានគុណវុឌ្ឍិទាបជាងបរិញ្ញាបត្រនិងបទពិសោធន៍ទាបជាង៣ឆ្នាំចំនួន ៤រូប។ បុគ្គលិកទាំង៥រូបទាំងនោះ រួមមានបុគ្គលិក Administration ១រូប, Assistance ១រូប, Operation ១រូប, Academic Support ១រូប និង Operation ១រូប។ បុគ្គលិកភាគច្រើនជានិស្សិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ដែលកំពុងសិក្សាក្នុងសាកលវិទ្យាល័យ។ តាមលទ្ធផលនៃការស្ទង់មតិ និងការសម្ភាសគ្រូបង្រៀននិងនិស្សិតបង្ហាញថា គ្រូបង្រៀននិងនិស្សិតភាគច្រើនយល់ថា បុគ្គលិកទទួលបន្ទុកបន្ទប់អនុវត្តឆ្លើយតបនឹងតម្រូវការរបស់និស្សិត និងគ្រូបង្រៀនក្នុងការគាំទ្របន្ទប់អនុវត្តន៍បានសមស្រប។

## ១១. គោលនយោបាយ ឬគោលការណ៍ស្ដីពីសុវត្ថិភាព

សាកលវិទ្យាល័យមានគោលការណ៍សុវត្ថិភាពនៃការប្រើប្រាស់បន្ទប់អនុវត្តឆ្នាំ២០១៩ ដែលកំណត់ពីប្រព័ន្ធសុវត្ថិភាព ដំណើរការប្រព័ន្ធសុវត្ថិភាព និងសុវត្ថិភាពអគ្គីភ័យ។ សាកលវិទ្យាល័យមានប្រព័ន្ធការពារ និងបំពង់ពន្លត់អគ្គីភ័យនៅគ្រប់ជាន់ រួមទាំងបណ្ណាល័យ បន្ទប់អនុវត្ត និង IT Office (Server Room) ព្រមទាំងមានបិទការប្រើប្រាស់ផងដែរ។ តាមលទ្ធផលនៃការស្ទង់មតិគ្រូបង្រៀន និងនិស្សិតបង្ហាញថា គ្រូបង្រៀនចំនួន ៧៦.១% និងនិស្សិត ៦៩% ឆ្លើយថា បុគ្គលិកទទួលបន្ទុកបន្ទប់អនុវត្តន៍បាន អនុវត្តស្របតាមគោលការណ៍សុវត្ថិភាពបានស្ទើតែពេញលេញ។ ទោះយ៉ាងណាតាមការសម្ភាសនិស្សិត និងគ្រូបង្រៀនបានបង្ហាញថា និស្សិតភាគច្រើនពុំដឹងពីការប្រើប្រាស់សម្ភារៈការពារសុវត្ថិភាព ដូចជា បំពង់ពន្លត់អគ្គីភ័យ នៅឡើយ ហើយសាកលវិទ្យាល័យពុំដែលបានរៀបចំឱ្យមាន Fire Drill ដើម្បីឱ្យនិស្សិត គ្រូបង្រៀន បុគ្គលិកនៅឡើយ។

## ១២. ធនធានបច្ចេកវិទ្យា និង អ៊ីនធឺណិត

និស្សិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រមានចំនួនផលធៀបនិស្សិត និងComputer៖ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រមានចំនួន (២៦៨:៤១ ឬ ៥:១) និស្សិតនិងរយៈពេលប្រើប្រាស់គិតជានាទី (១:៩៦៦)។ ចំណែកផលធៀបនិស្សិត និង Computer ផ្នែកជំនាញផ្សេងទៀតមានចំនួន (២៦២៨:៦៣ ឬ ៤២:១) និងរយៈពេលប្រើប្រាស់គិតជានាទី (១:១២០)។ សាកលវិទ្យាល័យមានបន្ទប់ដែលបំពាក់ដោយធនធានបច្ចេកវិទ្យា និងអ៊ីនធឺណិត ដូចជា(១).Repair Lab (២).Computer Modern Classroom 2 (៣).Computer Modern Classroom 4 (៤).Computer Smart Classroom (៥).Accounting Smart Classroom (៦).Computer Science Lab និង (៧). Accounting Lab ។

*តារាង ៣.៦.២ ៖ ធនធានបច្ចេកវិទ្យា និងល្បឿនអ៊ីនធឺណិតរបស់សាកលវិទ្យាល័យ*

| ល.រ | កម្មវិធីអប់រំ | ធនធានបច្ចេកវិទ្យា | | អ៊ីនធឺណិត | |
|---|---|---|---|---|---|
| | | ការបរិយាយ | ចំនួន | ការបរិយាយ | ទំហំល្បឿន |
| ១ | វិទ្យាសាស្ត្រកុំព្យូទ័រ | កុំព្យូទ័រ | ១៨៦ គ្រឿង | Internet EZECOM Floor 5 | 50 MB |
| ២ | គ្រប់គ្រងប្រព័ន្ធព័ត៌មាន | | | Internet EZECOM Floor 7 | 100 MB |
| ៣ | Accounting | | ៥០ គ្រឿង | | |

តាមលទ្ធផលនៃការស្ទង់មតិគ្រូបង្រៀន និងនិស្សិត បង្ហាញថា គ្រូបង្រៀនចំនួន ៦២.៥% ឆ្លើយថា អ៊ីនធឺណិតមានល្បឿនគ្រប់គ្រាន់ឆ្លើយតបនឹងការសិក្សាស្រាវជ្រាវ។ ចំណែកឯនិស្សិតចំនួន ៦០.៨% ឆ្លើយថា អ៊ីនធឺណិតមានល្បឿនគ្រប់គ្រាន់ឆ្លើយតបនឹងការសិក្សាស្រាវជ្រាវ។ តាមរយៈការសម្ភាស និស្សិតស្នើសុំឱ្យសាកលវិទ្យាល័យពិនិត្យល្បឿន WIFI និង ម៉ាស៊ីនត្រជាក់ក្នុងបន្ទប់អនុវត្ត នៅជាន់ទី៧ឡើងវិញ។

## ១៣. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា

សាកលវិទ្យាល័យបានរៀបចំវគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យាដល់គ្រូបង្រៀន តាមរយៈការរៀបចំសិក្ខាសាលាកសាងសមត្ថភាពគ្រូបង្រៀនលើការប្រើប្រាស់បច្ចេកវិទ្យា AI, ការបញ្ជូនគ្រូបង្រៀនទៅសិក្សាបន្ថែមយកបរិញ្ញាត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ, Lecturer's Capacity Building to Upskill in Computer Science Fields – Python, Lecturer's Capacity Building to Upskill in Computer Science Fields – Cyber Security, "Lecturer's Capacity Building to Upskill in Computer Science Fields – Artificial Intelligence, "Lecturer's Capacity Building to Upskill in Computer Science Fields – Data Science, និង"Lecturer's Capacity Building to Upskill in Computer Science Fields – Software

Engineering & Cloud Computing ។ល។ ចំណែកឯនិស្សិតទទួលបានការបណ្តុះបណ្តាលធនធានបច្ចេកវិទ្យាតាមរយៈកម្មវិធីសិក្សា មុខវិជ្ជា ICT។ តាមលទ្ធផលនៃការស្ទង់មតិនិស្សិតបង្ហាញថា និស្សិត ៧៩% ឆ្លើយថាបានទទួលការបណ្តុះបណ្តាលពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា។ តាមការសម្ភាសគ្រូបង្រៀនបង្ហាញថា គ្រូបង្រៀនវេលាការមួយចំនួនពុំបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់ធនធានបច្ចេកវិទ្យានោះទេ។

**១៤. បុគ្គលិកគាំទ្រនិងជួយសម្រួលផ្នែកបច្ចេកទេស**

ការិយាល័យហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា មានបុគ្គលិកសរុបចំនួន ០៥រូប ដែលក្នុងនោះរួមមានបុគ្គលិក Administration ០១ រូប, Assistance ០១រូប, Operation ០១ រូប, Academic Support ០១រូប និងOperation ០១រូប ដែលមានតួនាទីគាំទ្រផ្នែកបច្ចេកវិទ្យាក្នុងសាកលវិទ្យាល័យទាំងក្នុងបន្ទប់អនុវត្ត ថ្នាក់រៀន និងបច្ចេកវិទ្យាផ្សេងៗ ហើយបុគ្គលិកភាគច្រើនជានិស្សិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ដែលកំពុងសិក្សាក្នុងសាកលវិទ្យាល័យ។ តាមលទ្ធផលនៃការស្ទង់មតិ និងការសម្ភាសគ្រូបង្រៀន និងនិស្សិតបង្ហាញថា គ្រូបង្រៀន និងនិស្សិតភាគច្រើនយល់ថា បុគ្គលិកផ្នែកបច្ចេកវិទ្យា ឆ្លើយតបនឹងតម្រូវការរបស់និស្សិត និងគ្រូបង្រៀនក្នុងការគាំទ្រផ្នែកបច្ចេកវិទ្យាបានសមស្រប។

*តារាង ៣.៦.៣ ៖ ស្ថិតិបុគ្គលិកគាំទ្រនិងជួយសម្រួលផ្នែកបច្ចេកទេសទទួលបានការបណ្តុះបណ្តាល*

| ល.រ | វគ្គបណ្តុះបណ្តាល | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|---|---|
| ១ | Administration | ១នាក់ | - | - | - | - |
| ២ | Assistance | - | ១នាក់ | - | - | - |
| ៣ | Operation | - | - | ១នាក់ | - | - |
| ៤ | Academic Support | - | - | - | - | - |
| ៥ | Operation | - | - | - | - | ១នាក់ |
| សរុប | | ១នាក់ | ១នាក់ | ១នាក់ | ១នាក់ | ១នាក់ |

**ចំណុចខ្លាំង**

- បណ្ណាល័យមានទំហំសមស្របតាមចំនួននិស្សិតតាមវេនសិក្សា និងមានបរិយាកាសអំណោយផលដល់ការសិក្សា និងស្រាវជ្រាវ
- ម៉ោងបើកបណ្ណាល័យឆ្លើយតបនឹងតម្រូវការនិស្សិតនិងគ្រូបង្រៀន
- បន្ទប់ពិសោធន៍ទូទៅ និងឯកទេសឆ្លើយតបនឹងតម្រូវការនៃកម្មវិធី
- បានអនុវត្តតាមផែនការអភិវឌ្ឍន៍បន្ទប់អនុវត្ត។

**ចំណុចអនុវត្តបានល្អ**

- បុគ្គលិកបណ្ណាល័យភាគច្រើនបានទទួលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបណ្ណាល័យពីបណ្ណារក្ស
- និស្សិតស្ទើរតែទាំងអស់ និងគ្រូបង្រៀនភាគច្រើនទទួលបានការណែនាំតម្រង់ទិសពីការប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ
- បណ្ណាល័យមានថវិកាមួយចំនួនសម្រាប់គាំទ្រសេវាបណ្ណាល័យ
- សៀវភៅសិក្សា ឯកសារយោង និងទស្សនាវដ្តីវិទ្យាសាស្ត្រឆ្លើយតបទៅនឹងកម្មវិធីអប់រំ ប៉ុន្តែភាគច្រើនឯកសារយោងនិងទស្សនាវដ្តីវិទ្យាសាស្ត្រមានអាយុកាលលើសពី១០ឆ្នាំ

- បុគ្គលិកនៃបន្ទប់អនុវត្តន៍បានឆ្លងកាត់ការបណ្តុះបណ្តាល ប៉ុន្តែបុគ្គលិកមួយចំនួនពុំទាន់ឆ្លើយតបទៅនឹងតម្រូវការនិស្សិត
- បានអនុវត្តគោលការណ៍សុវត្ថិភាពរបស់សាកលវិទ្យាល័យភាគច្រើន
- បានផ្តល់ធនធានបច្ចេកវិទ្យានិងអ៊ីនធឺណិតបម្រើការបង្រៀននិងសិក្សាបានភាគច្រើន
- និស្សិតនិងគ្រូបង្រៀនភាគច្រើនទទួលបានការបណ្តុះបណ្តាលពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា
- បុគ្គលិកគាំទ្របច្ចេកវិទ្យាជួយសម្រួលបច្ចេកទេសតាមតម្រូវការភាគច្រើន។

**ចំណុចកែលម្អ**

- ពុំទាន់មានបណ្ណាល័យអេឡិចត្រូនិកសម្រាប់បម្រើឱ្យការសិក្សាស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន។

**សេចក្តីសន្និដ្ឋាន**

ជារួម សាកលវិទ្យាលយអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា៦។ បណ្ណាល័យមានទំហំសមស្របតាមចំនួននិស្សិតតាមវេនសិក្សា និង មានបរិយាកាសអំណោយផលដល់ការសិក្សានិងស្រាវជ្រាវ ហើយម៉ោងបើកបម្រើសេវាបណ្ណាល័យឆ្លើយតបនឹងតម្រូវការនិស្សិតនិងគ្រូបង្រៀន។ បុគ្គលិកបណ្ណាល័យភាគច្រើនបានទទួលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបណ្ណាល័យពីបណ្ណារក្ស។ និស្សិតស្ទើរតែទាំងអស់ និងគ្រូបង្រៀនភាគច្រើនទទួលបានការណែនាំតម្រង់ទិសពីការប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ។ សៀវភៅសិក្សា ឯកសារយោង និងទស្សនាវដ្តីវិទ្យាសាស្ត្រឆ្លើយតបទៅនឹងកម្មវិធីអប់រំ ប៉ុន្តែភាគច្រើនឯកសារយោងនិងទស្សនាវដ្តីវិទ្យាសាស្ត្រមានអាយុកាលលើសពី១០ឆ្នាំ។ បណ្ណាល័យមានថវិកាមួយចំនួនសម្រាប់គាំទ្រសេវាបណ្ណាល័យ។ សាកលវិទ្យាល័យពុំទាន់មានបណ្ណាល័យអេឡិចត្រូនិកសម្រាប់បម្រើឱ្យការសិក្សាស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន។

សាកលវិទ្យាល័យបានអនុវត្តតាមផែនការអភិវឌ្ឍន៍បន្ទប់អនុវត្ត ហើយបន្ទប់ពិសោធន៍ទូទៅ និងឯកទេសឆ្លើយតបនឹងតម្រូវការនៃកម្មវិធី។ បុគ្គលិកនៃបន្ទប់អនុវត្តន៍បានឆ្លងកាត់ការបណ្តុះបណ្តាល ប៉ុន្តែបុគ្គលិកមួយចំនួនពុំទាន់ឆ្លើយតបទៅនឹងតម្រូវការនិស្សិត។ សាកលវិទ្យាល័យ បានអនុវត្តគោលការណ៍សុវត្ថិភាពរបស់សាកលវិទ្យាល័យភាគច្រើន។

សាកលវិទ្យាល័យបានផ្តល់ធនធានបច្ចេកវិទ្យា និងអ៊ីនធឺណិតបម្រើការបង្រៀននិងសិក្សាបានភាគច្រើន ហើយបុគ្គលិកគាំទ្របច្ចេកវិទ្យាជួយសម្រួលបច្ចេកទេសតាមតម្រូវការបានភាគច្រើនផងដែរ។ និស្សិតនិងគ្រូបង្រៀនភាគច្រើនទទួលបានការបណ្តុះបណ្តាលពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា៦ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវ៖

- ធ្វើទំនើបកម្មបណ្ណាល័យអេឡិចត្រូនិក ឱ្យបានពេញលេញដើម្បីឱ្យនិស្សិត និងគ្រូបង្រៀនអាចទាញយកឯកសារផ្សេងៗពីចម្ងាយសម្រាប់សិក្សាស្រាវជ្រាវ ។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា៦ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរ៖

- ធ្វើបច្ចុប្បន្នកម្ម និងបន្ថែមសៀវភៅសិក្សា ឯកសាយោង ជាពិសេសទស្សនាវដ្តីវិទ្យាសាស្ត្រថ្មីៗទាំងឯកសាររឹង និងទន់ ( Hard and Soft Copy )

- បំប៉នសមត្ថភាពបុគ្គលិកក្នុងការគ្រប់គ្រងបណ្ណាល័យ និង ណែនាំតម្រង់ទិសគ្រូបង្រៀនអំពីការប្រើប្រាស់បណ្ណាល័យ និងធនធានធានសិក្សាផ្សេងៗ
- បំប៉នសមត្ថភាពបុគ្គលិកទទួលបន្ទុកបន្ទប់អនុវត្តន៍ឱ្យឆ្លើយតបទៅនឹងតម្រូវការនិស្សិត និងការអនុវត្តគោលការណ៍សុវត្ថិភាពនៃបន្ទប់អនុវត្តន៍នីមួយៗ
- បង្កើនការគាំទ្រធនធានបច្ចេកវិទ្យានិងអ៊ីនធឺណិតឱ្យឆ្លើយតបទៅនឹងតម្រូវការបង្រៀននិងរៀន
- បំប៉នសមត្ថភាពនិស្សិតនិងគ្រូបង្រៀនអំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា និងជំរុញបុគ្គលិកគាំទ្របច្ចេកទេសជួយសម្រួលបច្ចេកទេសឱ្យឆ្លើយតបតាមតម្រូវការ។

**៣.៧. ស្តង់ដា៧៖ ធនធានរូបវន្ត**

***របកគំហើញ***

***១. ភាពគ្រប់គ្រាន់នៃធនធានរូបវន្តសម្រាប់កម្មវិធីអប់រំ***

សាកលវិទ្យាល័យមានអគារសិក្សាផ្ទាល់ខ្លួន ដែលមានទីតាំងស្ថិតនៅអគារលេខ៣៦, ផ្លូវ១៦៩, សង្កាត់វាលវង់, ខណ្ឌ៧មករា, រាជធានីភ្នំពេញ ដែលមានផ្ទៃក្រឡា ៩ ១៧៨,៤៨ ម៉ែត្រការ៉េ ដោយមានលក្ខណៈធំទូលាយប្រកបដោយបរិស្ថានល្អ បំពាក់ដោយធនធានរូបវន្តទំនើបនិងសមស្របសម្រាប់កម្មវិធីអប់រំដែលកំពុងបណ្តុះបណ្តាល និង អំណោយផលដល់ការសិក្សាស្រាវជ្រាវរបស់និស្សិត និង គ្រូបង្រៀន។ បន្ទប់សិក្សានីមួយៗមានទំហំធំទូលាយ បំពាក់ដោយបរិក្ខារចាំបាច់សម្រាប់ការបង្រៀននិងរៀន និងមានចំនួនគ្រប់គ្រាន់។ ក្រៅពីបន្ទប់សិក្សា សាកលវិទ្យាល័យមានការិយាល័យគ្រប់គ្រាន់ និងធំទូលាយប្រកបដោយផាសុកភាព មានបន្ទប់ប្រជុំ សាលប្រជុំ បន្ទប់អនុវត្តកុំព្យូទ័រ បន្ទប់អនុវត្តជំនាញគណនេយ្យ បន្ទប់សាវនាការប្រឌិត បន្ទប់សិក្សាទំនើប (Smart Classroom) និងបណ្ណាល័យធំទូលាយ ប្រកបដោយបរិយាកាសល្អ អំណោយផលដល់ការសិក្សាស្រាវជ្រាវ។ បន្ទប់រៀន និងការិយាល័យគ្រប់គ្រាន់សម្រាប់ដំណើរការបង្រៀននិងរៀន ទាំងទ្រឹស្តី ការសិក្សាអនុវត្ត និងការងាររដ្ឋបាល។ ទំហំបន្ទប់នីមួយៗស្របតាមគោលការណ៍ណែនាំ ជាមធ្យមបន្ទប់សិក្សាទំហំចន្លោះពី ៩០ ទៅ ១១០ ម៉ែត្រការ៉េដែលរៀបចំឡើងសម្រាប់និស្សិតចន្លោះពី២០ទៅ២៥នាក់។ ជារួម សាកលវិទ្យាល័យមានធនធានរូបវន្តសម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ និងសកម្មភាពផ្សេងៗ រួមទាំងសកម្មភាពសិក្សានិងសកម្មភាពបន្ថែមដែលកំពុងសិក្សានិងអនាគតបានគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការ។

***២. ផាសុកភាព និងសុវត្ថិភាពនៃបរិស្ថានសិក្សា***

សាកលវិទ្យាល័យមានបរិស្ថានប្រកបដោយផាសុកភាព ទីតាំងល្អស្ថិតនៅកណ្តាលទីក្រុងភ្នំពេញ ទីធ្លាផ្លូវដើរក្នុងអគារសិក្សាធំទូលាយនិងមានពន្លឺគ្រប់គ្រាន់ មានកន្លែងចតយានយន្តបរិបូរណ៍ មានបន្ទប់ទឹកគ្រប់គ្រាន់ បន្ទប់សម្រាប់បុគ្គលិកសម្រាកនិងទទួលទានអាហារ ហាងកាហ្វេ អាហារដ្ឋាន ទីធ្លាសម្រាប់ស្វ័យសិក្សា (recreational area) ដែលមានពន្លឺ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ និងមានសួនបៃតង ដែលជួយសម្រួលដល់ការសម្រាកពីការសិក្សារបស់និស្សិត។ អគារសិក្សាត្រូវបានសាងសង់តាមស្តង់ដាបច្ចេកទេសត្រឹមត្រូវ មានជណ្តើរយន្ត ជណ្តើរជើង និង ច្រកចេញគ្រប់គ្រាន់ក្នុងករណីមានគ្រោះអាសន្ន។ នៅតាមជាន់នីមួយៗមានបំពាក់កាមេរ៉ាសុវត្ថិភាព និងបំពង់ពន្លត់អគ្គីភ័យ និងបំពង់ទឹក ព្រមទាំងមានបុគ្គលិកសន្តិសុខយាម២៤ម៉ោង។ សាកលវិទ្យាល័យក៏មានគោលការណ៍ណែនាំ និងបទបញ្ញាស្តីពីសុវត្ថិភាពនិងសន្តិសុខ និង ថ្មីៗនេះ

បានវាយតម្លៃអំពីប្រសិទ្ធភាព និងការយល់ដឹងនៃនិស្សិត គ្រូបង្រៀនទៅលើបទបញ្ញាទាំងនោះ ព្រមទាំងបានធ្វើការកែលម្អទៅតាមលទ្ធផលនៃការវាយតម្លៃបាន១០០%។

**៣. ការផ្សព្វផ្សាយ អនុវត្ត វាយតម្លៃប្រចាំពីបញ្ហាសុខភាព សុវត្ថិភាព និងសន្តិសុខ**

សាកលវិទ្យាល័យបានផ្សព្វផ្សាយ និងណែនាំដល់និស្សិត គ្រូបងៀន និងបុគ្គលិកទាំងអស់ ស្តីពីអនាម័យ សុវត្ថិភាព និង សន្តិសុខនៅអគារសិក្សានិងបរិវេណជុំវិញអគារ នៅរាល់ការប្រជុំប្រចាំឆមាស ព្រមទាំងលើកទឹកចិត្តឱ្យចូលរួមរក្សាអនាម័យ អនុវត្តគោលការណ៍សុវត្ថិភាពដោយផ្តើមចេញពីបុគ្គលម្នាក់ៗ។ សាកលវិទ្យាល័យមានសៀវភៅណែនាំស្តីពីសុខសុវត្ថិភាពនិងសន្តិសុខ គោលការណ៍គ្រប់គ្រងបន្ទប់អនុវត្តកុំព្យូទ័រ វិធានសន្តិសុខ ការប្រើប្រាស់ឧបករណ៍ពន្លត់អគ្គីភ័យក្នុងករណីចាំបាច់។ នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សបានចេញសេចក្តីណែនាំ និងផ្សព្វផ្សាយដល់គ្រប់បុគ្គលិកអំពីការហាមប្រើថង់ប្លាស្ទិចក្នុងបរិវេណសាកលវិទ្យាល័យ ក្នុងស្មារតីចូលរួមការពារបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រើថង់ប្លាស្ទិច។ ដើម្បីសុវត្ថិភាព និងសន្តិសុខ និស្សិតត្រូវពាក់កាតសម្គាល់ខ្លួន សម្រាប់ Scan ប្រើប្រាស់ជណ្តើរយន្ត។ វិធានសុវត្ថិភាពនិងសន្តិសុខ ត្រូវបានបិទជាផ្ទាំងរូបភាព លើក្តារខៀនព័ត៌មាន តាមបន្ទប់សិក្សា និងនៅទីតាំងសំខាន់ៗចាំបាច់មួយចំនួន ព្រមទាំងបានធ្វើការវាយតម្លៃពីការយល់ដឹងនិងការអនុវត្តជាប្រចាំដោយបុគ្គលិកផ្នែករដ្ឋបាលដោយបានធ្វើការកែលម្អឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញ ហើយសាកលវិទ្យាល័យកំពុងបន្តពង្រឹងសេវាកម្មជាបន្តនិងសហការជាមួយភាគីពាក់ព័ន្ធ ទាំងអ្នកផ្តល់សេវា និងអ្នកទទួលសេវាក្នុងការធ្វើឱ្យកាន់តែប្រសើរឡើងនូវការអនុវត្តបទបញ្ញា។

**៤. គោលនយោបាយ ឬគោលការណ៍សុវត្ថិភាពស្តីពីការគ្រប់គ្រងថែរក្សាប្រព័ន្ធព័ត៌មានអេឡិចត្រូនិក**

សាកលវិទ្យាល័យមានបន្ទប់ Servers ដើម្បីរក្សាទិន្នន័យប្រកបដោយសុវត្ថិភាព និងមានប្រព័ន្ធការងារអគ្គីភ័យធានាសុវត្ថិភាពរាល់ទិន្នន័យដែលបានរក្សាទុក។ រាល់ឯកសារត្រូវបានរក្សាទុកក្នុងប្រព័ន្ធ Servers និងបានថតចម្លងទុកជា Hardcopy ក្នុងក្រូណ្ឌតាមនាយកដ្ឋាន និងការិយាល័យនានាបច្ចុប្បន្ន។ ដោយបច្ចេកវិទ្យាមានការរីកចម្រើន សាកលវិទ្យាល័យបានថែរក្សាឯកសារនៅក្នុងប្រព័ន្ធ cloud និងមានការគ្រប់គ្រងច្បាស់លាស់ពីក្រុមការងារការិយាល័យបច្ចេកវិទ្យា (IT Office) និងត្រួតពិនិត្យដោយផ្ទាល់ពីសាកលវិទ្យាធិការរងទទួលបន្ទុក។ ក្នុងការអនុវត្តជាក់ស្តែង សាកលវិទ្យាល័យ ពុំដែលជួបប្រទះបញ្ហាបាត់បង់ ឬខូចខាតទិន្នន័យដែលបានរក្សាទុកកន្លងមកនោះទេ ដោយបានអនុវត្តតាមគោលការណ៍កំណត់បានយ៉ាងល្អប្រសើរ។ ប៉ុន្តែ សាកលវិទ្យាល័យ គួររៀបចំឱ្យមានការវាយតម្លៃប្រព័ន្ធគ្រប់គ្រងអេឡិចត្រូនិក ប្រព័ន្ធការពារអគ្គិភ័យ និងគុណភាពនៃឯកសារចម្លងទុក ដើម្បីបង្កើនសុវត្ថិភាពនៃការគ្រប់គ្រង និងគុណភាពរាល់ឯកសារចម្លងទុក។

**៥. ផែនការអភិវឌ្ឍន៍ធនធានរូបវន្ត**

សាកលវិទ្យាល័យមានផែនការសកម្មភាពប្រចាំឆ្នាំតាមនាយកដ្ឋាន និងការិយាល័យ ក្នុងនោះនាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្សមានផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អភិវឌ្ឍន៍ធនធានរូបវន្ត ដើម្បីបំពេញសេចក្តីត្រូវការក្នុងការបង្រៀននិងរៀន និងសេវាកម្មសិក្សា។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយសាកលវិទ្យាល័យទទួលបានថវិកាឧបត្ថម្ភពីគម្រោងនានាដែលចូលរួមជាចម្បងដល់ការអភិវឌ្ឍធនធានរូបវន្ត។ ចំពោះការអនុវត្តផែនការអភិវឌ្ឍធនធានរូបវន្តជាក់ស្តែង ការិយាល័យរដ្ឋបាលនិងធនធានមនុស្សបានយកចិត្តទុកដាក់ក្នុងការសិក្សាអំពីភាពចាំបាច់ និងតម្រូវការនៃការអភិវឌ្ឍធនធានរូបវន្ត រយៈពេលវែង ខ្លី បានច្បាស់លាស់ និងធ្វើការ

វាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍន៍ជាប្រចាំដោយគុណភាពការងារ និងប្រសិទ្ធភាពទៅតាមផែនការដែលបានកំណត់ ដោយមានការកត់ត្រាច្បាស់លាស់នូវរាល់ការចំណាយអភិវឌ្ឍធនធានរូបវន្ត ដែលកើតឡើងពីតម្រូវការជាក់ស្តែង ព្រមទាំងបានអនុវត្តសម្រេចតាមផែនការដែលបានកំណត់១០០%។

**ចំណុចខ្លាំង**

- មានធនធានរូបវន្តសម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ និងសកម្មភាពផ្សេងៗ រួមទាំងសកម្មភាពសិក្សានិងសកម្មភាពបន្ថែមដែលកំពុងសិក្សានិងអនាគតបានគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការ
- មានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាពរួមទាំងសុវត្ថិភាពចំណត និងសណ្តាប់ធ្នាប់ល្អប្រសើរ
- បានធ្វើការណែនាំនិងផ្សព្វផ្សាយពីការអនុវត្ត សុខភាព សុវត្ថិភាព សន្តិសុខនិងបានធ្វើការវាយតម្លៃជាប្រចាំ ព្រមទាំងបានធ្វើការកែលម្អឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញ។
- មានគោលការណ៍ ស្តីពីការគ្រប់គ្រង ថែរក្សាប្រព័ន្ធអេឡិចត្រូនិក ការការពារអគ្គីភ័យ ការថតចំលងព្រមទាំងបានអនុវត្តតាមគោលការណ៍កំណត់បានយ៉ាងល្អប្រសើរ
- មានផែនការអភិវឌ្ឍន៍ធនធានរូបវន្តច្បាស់លាស់ ព្រមទាំងបានអនុវត្តសម្រេចតាមផែនការដែលបានកំណត់១០០%។

**សេចក្តីសន្និដ្ឋាន**

សាកលវិទ្យាល័យអនុវត្តបានស្ទើរតែទាំងអស់ស្របតាមសូចនាករតម្រូវនៃស្តង់ដា៧។ សាកលវិទ្យាល័យមានធនធានរូបវន្តសម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ និងសកម្មភាពផ្សេងៗ ព្រមទាំងមានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព រួមទាំងសុវត្ថិភាពចំណត និងសណ្តាប់ធ្នាប់ល្អប្រសើរ។ សាកលវិទ្យាល័យបានធ្វើការណែនាំនិងផ្សព្វផ្សាយពីការអនុវត្តសុខភាព សុវត្ថិភាព សន្តិសុខ និងបានធ្វើការវាយតម្លៃជាប្រចាំ ព្រមទាំងបានធ្វើការកែលម្អឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញ។ សាកលវិទ្យាល័យបានអនុវត្តតាមគោលការណ៍ ស្តីពីការគ្រប់គ្រង ថែរក្សាប្រព័ន្ធអេឡិចត្រូនិក ការការពារអគ្គីភ័យ និងការថតចំលង ព្រមទាំងអនុវត្តសម្រេចបាន១០០%តាមផែនការអភិវឌ្ឍធនធានរូបវន្តដែលបានកំណត់។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា៧ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវ៖

- ពុំមាន។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា៧ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរ៖

- ពុំមាន។

## ៣.៨. ស្តង់ដា៨៖ ធនធានហិរញ្ញវត្ថុ

**របកគំហើញ**

**១. ស្ថិរភាពហិរញ្ញវត្ថុសម្រាប់ការចំណាយ**

សាកលវិទ្យាល័យមានប្រភពចំណូលចំនួនបី គឺចំណូលបានមកពីការបង់ថ្លៃការសិក្សា ចំណូលផ្សេងៗ និង ចំណូលពីគម្រោង។ ចំណូលបានមកពីការបង់ថ្លៃការសិក្សាសម្រាប់ការចំណាយប្រតិបត្តិការ ចំណូល

ផ្សេងៗសម្រាប់ការចំណាយលើការវិនិយោគ និង ចំណូលពីគម្រោងសម្រាប់ការចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍។ លើសពីនេះ ដើម្បីធានាបាននូវការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និង ស្ថិរភាពសម្រាប់ការចំណាយ សាកលវិទ្យាល័យបានដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុស្តីពីការប្រើប្រាស់ថវិកា គោលការណ៍ស្តីពីការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងហិរញ្ញវត្ថុ និង គោលការណ៍ស្តីពីសារពើពន្ធ ព្រមទាំងបានរៀបចំជារបាយការណ៍ចំណូលចំណាយ របាយការណ៍តារាងតុល្យការណ៍ របាយការណ៍លំហូរសាច់ប្រាក់ និង របាយការណ៍ទ្រព្យម្ចាស់ ដើម្បីពិនិត្យនិងតាមដានស្ថានភាពនិងសុខមាលភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យ។ ក្រុមប្រឹក្សាភិបាលបានពិនិត្យគម្រោងថវិកា បង្កើតយុទ្ធសាស្ត្រវិនិយោគទុន ប្រមូលមូលនិធិ និងអនុម័តផែនការសម្រាប់ការការពារផលប្រយោជន៍និស្សិត និងការស្រាវជ្រាវ ព្រមទាំងរៀបចំឱ្យមានកញ្ចប់ថវិកាបម្រុង ដើម្បីការពារហានិភ័យ និងមានដំណោះស្រាយ ក៏ដូចជាសង្គ្រោះនៅពេលមានវិនភាពសេដ្ឋកិច្ច ឬ វិបត្តិសង្គមជាដើម។

សាកលវិទ្យាល័យមានស្ថានភាពហិរញ្ញវត្ថុតាមឆ្នាំនីមួយៗដូចខាងក្រោម៖

- **ឆ្នាំ២០២០ ៖** មានចំណូលសរុបចំនួន ១ ០៣៥ ៧១៦.១៤ ដុល្លារ ចំណាយសរុបចំនួន ១ ១១៧ ៦១៤.៣៦ ដុល្លារ និង ខាតចំនួន ៨១ ៧៩៨.២២ ដុល្លារ។
- **ឆ្នាំ២០២១ ៖** មានចំណូលសរុបចំនួន ១ ០៤៨ ៦៤២.៤៨ ដុល្លារ ចំណាយសរុបចំនួន ១ ០៨៨ ៦៤៤.៨៦ ដុល្លារ និង ខាតចំនួន ៤០ ០០២.៣៨ ដុល្លារ។
- **ឆ្នាំ២០២២ ៖** មានចំណូលសរុបចំនួន ១ ២០១ ៣៤០.៣៧ ដុល្លារ ចំណាយសរុបចំនួន ១ ២២៩ ៤៧៦.៥៤ ដុល្លារ និង ខាតចំនួន ២៨ ១៣៦.១៧ ដុល្លារ។
- **ឆ្នាំ២០២៣ ៖** មានចំណូលសរុបចំនួន ១ ៩១៦ ២២៩.១៩ ដុល្លារ ចំណាយសរុបចំនួន ១ ២៤៩ ២៨៧.២៥ ដុល្លារ និង ចំណេញបានចំនួន ៦៦៦ ៩៤១.៩៤ ដុល្លារ។
- **ឆ្នាំ២០២៤ ៖** មានចំណូលសរុបចំនួន ១ ៤២៩ ៦៦៤.៥៧ ដុល្លារ ចំណាយសរុបចំនួន ១ ១៩៣ ៦៥៨.១៧ ដុល្លារ និង ចំណេញបានចំនួន ២៣៦ ០០៦.៤០ ដុល្លារ។

តាមមូលដ្ឋានទិន្នន័យខាងលើ ស្ថានភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យពុំសូវមានស្ថានភាពល្អនោះទេចាប់តាំងពីឆ្នាំ២០២០ មកដល់ឆ្នាំ២០២២ ប៉ុន្តែស្ថានភាពហិរញ្ញវត្ថុចាប់ផ្តើមមានភាពប្រសើរឡើងវិញនៅឆ្នាំ២០២៣ និងឆ្នាំ២០២៤។ ទោះបីជាមានស្ថានភាពហិរញ្ញវត្ថុពុំសូវល្អចាប់តាំងពីឆ្នាំ២០២០-២០២២ក៏ដោយ ប៉ុន្តែក្នុងអំឡុងរយៈពេល៥ឆ្នាំចុងក្រោយនេះ គឺចាប់ពីឆ្នាំ២០២០-២០២៤ សាកលវិទ្យាល័យបានបើកប្រាក់បៀវត្សនិងប្រាក់ឈ្នួលរបស់គ្រូបង្រៀន និងបុគ្គលិកគ្រប់ចំនួននិងទាន់ពេលកំណត់។

## ២. រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុមានសមាសភាពសរុបចំនួន ១០នាក់ ក្នុងនោះមានកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ដែលមានបទពិសោធន៍លើសពី១០ឆ្នាំចំនួន ១នាក់ បរិញ្ញាបត្រដែលមានបទពិសោធន៍តិចជាង៣ឆ្នាំ១នាក់ និង ៦-១០ឆ្នាំ ៣នាក់ និង ទាបជាងបរិញ្ញាបត្រដែលមានបទពិសោធន៍តិចជាង៣ឆ្នាំ ចំនួន ៥នាក់។ នាយកដ្ឋាននេះស្ថិតក្រោមការសម្របសម្រួលបន្ថែមពីសាកលវិទ្យាធិការរង ១នាក់ដែលមានគុណវុឌ្ឍិនិងមានបទពិសោធន៍ការងារជិត២០ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ។ នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុបានរៀបចំរបាយការណ៍ចំណូលចំណាយ របាយការណ៍តារាងតុល្យការណ៍ របាយការណ៍លំហូរសាច់ប្រាក់ និង របាយការណ៍ទ្រព្យម្ចាស់ជូនថ្នាក់ដឹកនាំតាមពេលវេលាកំណត់។

### ៣. ការរៀបចំផែនការថវិកាប្រចាំឆ្នាំ

សាកលវិទ្យាល័យបានរៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការអនុវត្តនូវសកម្មភាព។ នៅឆ្នាំ២០២០ មានផែនការថវិកាប្រចាំឆ្នាំចំនួន ៣៤ ៧០៥ដុល្លារ និង ចំណាយអស់ ២៨ ១៦៣.៨១ដុល្លារ ស្មើនឹង ៨១.១៥%។ ឆ្នាំ២០២១ មានផែនការថវិកាប្រចាំឆ្នាំចំនួន ២២ ១៥០ ដុល្លារ និង ចំណាយអស់ ២០ ០០៩.២៤ ដុល្លារ ស្មើនឹង ៩០.៣៣%។ ឆ្នាំ២០២២ មានផែនការថវិកាប្រចាំឆ្នាំចំនួន ១៣ ១៤២.៦៨ ដុល្លារ និង ចំណាយអស់ ១២ ២៧៨.១០ ដុល្លារ ស្មើនឹង ៩៣.៤២%។ ឆ្នាំ២០២៣ មានផែនការថវិកាប្រចាំឆ្នាំចំនួន ១០៤ ៦៤៦.៨០ ដុល្លារ និង ចំណាយអស់ ៩២ ៧៦៨.២០ ដុល្លារ ស្មើនឹង ៨៨.៦៤%។ ឆ្នាំ២០២៤ មានផែនការថវិកាប្រចាំឆ្នាំចំនួន ២៤ ៣៣៣ ដុល្លារ និង ចំណាយអស់ ១៤ ២៣៣.២៩ ដុល្លារ ស្មើនឹង ៥៨.៤៩%។ ការអនុវត្តថវិកាប្រចាំឆ្នាំពុំទាន់ស្របទៅនឹងផែនការថវិកាដែលបានកំណត់ ជាក់ស្តែងការអនុវត្តថវិកា គិតជាមធ្យមក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ គឺបានតែចំនួន ៨២.៤០%។ ការណ៍នេះគប្បីសាកលវិទ្យាល័យគួរពិនិត្យឡើងវិញនូវរាល់ការគ្រោងថវិកាប្រចាំឆ្នាំ ដោយធ្វើយ៉ាងណាឱ្យផែនការនិងការអនុវត្តមានភាពសង្គតិភាពនឹងគ្នា និង ពង្រឹងការអនុវត្តថវិកាប្រចាំឆ្នាំឱ្យសម្រេចបានតាមផែនការដែលបានកំណត់។

### ៤. ការចូលរួមពីថ្នាក់ដឹកនាំ និងផ្នែកពាក់ព័ន្ធក្នុងការរៀបចំផែនការថវិកា

តំណាងគ្រប់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ ការិយាល័យសាមីគ្រប់ផ្នែកចូលរួមក្នុងការរៀបចំគម្រោងថវិកា ដោយមានការប្រជុំបូកសរុបលទ្ធផលឆ្នាំចាស់ និងដាក់ផែនការសម្រាប់ឆ្នាំថ្មី។ យោងតាមគោលនយោបាយនៃការរៀបចំផែនការថវិកា គ្រប់ផ្នែកសំខាន់ៗដែលពាក់ព័ន្ធក្នុងដំណើរប្រតិបត្តិការសាកលវិទ្យាល័យ ត្រូវរៀបចំផែនការថវិកាប្រចាំឆ្នាំ ដើម្បីដាក់ស្នើមកប្រើប្រាស់ក្នុងឆ្នាំបន្ទាប់។ ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុមានតួនាទីប្រមូលទិន្នន័យ វិភាគ និងបើកកិច្ចប្រជុំពិភាក្សាលើការបែងចែកប្រភពថវិកា និងធនធានក្នុងសាកលវិទ្យាល័យជារួម ដោយមានតាមដំណាក់កាលពីកម្រិតគណៈគ្រប់គ្រងប្រតិបត្តិ រហូតដល់ក្រុមប្រឹក្សាភិបាល។ ការអនុវត្តរៀបចំផែនការថវិកា មានតាមដំណាក់កាលដូចមានរៀបរាប់ខាងក្រោម៖

- ពិនិត្យនិងវាយតម្លៃកញ្ចប់ថវិកាដែលបានប្រើប្រាស់ឆ្នាំកន្លងមក ដោយមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធ។
- គ្រប់ផ្នែកត្រូវធ្វើផែនការសកម្មភាពនិងកញ្ចប់ថវិកាឆ្នាំបន្ទាប់ ស្នើមកគណៈគ្រប់គ្រងដើម្បីពិនិត្យនិងដាក់បន្តទៅក្រុមប្រឹក្សាភិបាលអនុម័ត។
- កិច្ចប្រជុំពិភាក្សាអំពីកញ្ចប់ថវិកាដែលបានស្នើដោយមានការចោទសួរ និងឆ្លើយពីគណៈគ្រប់គ្រង និងអ្នកអនុវត្ត។
- រៀបចំសំណើកញ្ចប់ថវិការួមរបស់សាកលវិទ្យាល័យប្រចាំឆ្នាំ ដាក់ជូនទៅក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត។
- ប្រជុំក្រុមប្រឹក្សាភិបាលពិភាក្សាដើម្បីពិនិត្យនិងធ្វើសេចក្តីសម្រេច។
- ប្រកាសឱ្យប្រើប្រាស់ថវិកាផ្លូវការប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ។

### ៥. សវនកម្មហិរញ្ញវត្ថុ

សាកលវិទ្យាល័យជាគ្រឹះស្ថានភាគទុននិក ជាឯកត្តបុគ្គល ដែលក្រុមប្រឹក្សាភិបាលមិនតម្រូវឱ្យមានការធ្វើសវនកម្មនោះទេ ដោយគ្រាន់តែតម្រូវឱ្យរៀបចំ និងដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និង អនុលោម

តាមនីតិវិធី និងទម្រង់ដែលបានកំណត់ ដូចជា របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ផ្ញើជូនក្រុមប្រឹក្សាភិបាល។ ក្នុងន័យនេះ សាកលវិទ្យាល័យពុំបានអនុវត្តសវនកម្មនោះទេ។

**៦. ការបញ្ជូនផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍប្រចាំឆ្នាំ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្ម**

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ បានបញ្ជូនផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំតាមផ្នែក របាយការណ៍ហិរញ្ញវត្ថុ និង ការចំណាយតាមផ្នែក បានបញ្ជូនទៅសាកលវិទ្យាធិការ និង ចម្លងជូនក្រុមប្រឹក្សាភិបាលស្របតាមពេលវេលាដែលបានកំណត់។

**ចំណុចខ្លាំង**

- បានបើកប្រាក់បៀវត្សនិងប្រាក់ឈ្នួលរបស់គ្រូបង្រៀន និងបុគ្គលិកគ្រប់ចំនួននិងទាន់ពេលកំណត់
- បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំជូនថ្នាក់ដឹកនាំតាមពេលកំណត់
- មានតំណាងគ្រប់ភាគីពាក់ព័ន្ធបានចូលរួមក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ
- បានបញ្ជូនរបាយការណ៍ ចំណូល-ចំណាយ តារាងតុល្យការ របាយការណ៍លំហូរសាច់ប្រាក់ របាយការណ៍វិភាគហិរញ្ញវត្ថុ ទៅក្រុមប្រឹក្សាភិបាលទាន់ពេលវេលាដែលបានកំណត់។

**ចំណុចអនុវត្តបានល្អ**

- បានអនុវត្តថវិកាប្រចាំឆ្នាំបានភាគច្រើន។

**ចំណុចកែលម្អ**

- ពុំទាន់បានធ្វើសវនកម្ម។

**សេចក្តីសន្និដ្ឋាន**

ជារួម សាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា៨។ សាកលវិទ្យាល័យបានរៀបចំផែនការថវិកាប្រចាំឆ្នាំដោយមានការចូលរួមពីតំណាងគ្រប់ភាគីពាក់ព័ន្ធ និងបានអនុវត្តថវិកាប្រចាំឆ្នាំបានភាគច្រើន ព្រមទាំងបានរៀបចំរបាយការណ៍ចំណូល-ចំណាយ តារាងតុល្យការ របាយការណ៍លំហូរសាច់ប្រាក់ និង របាយការណ៍ទ្រព្យម្ចាស់ និងបានបញ្ជូនទៅក្រុមប្រឹក្សាភិបាលទាន់ពេលវេលាដែលបានកំណត់។ សាកលវិទ្យាល័យបានបើកប្រាក់បៀវត្សនិងប្រាក់ឈ្នួលរបស់គ្រូបង្រៀន និងបុគ្គលិកគ្រប់ចំនួននិងទាន់ពេលកំណត់។ ប៉ុន្តែសាកលវិទ្យាល័យពុំទាន់បានធ្វើសវនកម្ម។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា៨ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវៈ

- រៀបចំគោលការណ៍ ស្តីពីការធ្វើសវនកម្មផ្ទៃក្នុង និងអនុវត្តតាមគោលការណ៍ដែលបានកំណត់ និង/ឬធ្វើសវនកម្មពីខាងក្រៅ។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា៨ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរៈ

- ពិនិត្យនិងកែលម្អគម្រោងថវិកាប្រចាំឆ្នាំដែលអាចអនុវត្តបាន។

## ៣.៩. ស្តង់ដារ៩៖ ការធានាគុណភាពផ្ទៃក្នុង

### របកគំហើញ

### ១. ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង

សាកលវិទ្យាល័យបានបង្កើតគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ដោយមានប្រធាន អនុប្រធាន សមាជិក និងអនុកម្មការចំនួន១២ ដែលទទួលបន្ទុកស្តង់ដារនីមួយៗក្នុងការរៀបចំរបាយការណ៍ស្វ័យវាយតម្លៃ (SAR)។ ក្រោមគម្រោង Higher Education Improvement Project (HEIP) របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យបានរៀបចំ IQA Manual និងប្រព័ន្ធគ្រប់គ្រងធានាគុណភាពផ្ទៃក្នុង។ បន្ថែមពីនេះ នៅឆ្នាំ២០១៨ សាកលវិទ្យាល័យបានឆ្លងកាត់ការវាយតម្លៃពីក្រៅក្រោមគម្រោង EU-SHARE Institutional Assessment ដែលជាភស្តុតាងនៃភាពសកម្ម និងត្រៀមខ្លួនល្អក្នុងការទទួលស្គាល់គុណភាពអប់រំ។ ការបង្កើតប្រព័ន្ធ IQA មានរចនាសម្ព័ន្ធច្បាស់ និងមានការអនុវត្តតាមគម្រោងជាតិ និងអន្តរជាតិ បង្ហាញពីភាពចាប់អារម្មណ៍ និងកម្រិតត្រៀមខ្លួនខ្ពស់។ ទោះជាយ៉ាងណា ការបន្តធ្វើបច្ចុប្បន្នភាព IQA Manual និងការតាមដានការអនុវត្តស្តង់ដារតាមស្ថានភាពថ្មីនៅតែជាចំណុចគួរតែផ្តោតសំខាន់ ដើម្បីធានាបាននូវប្រព័ន្ធ IQA របស់សាកលវិទ្យាល័យមាននិរន្តរភាព។

### ២. ការចូលរួម និង សហការពីគណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់រួមទាំង បុគ្គលិក និស្សិត និង ភាគីពាក់ព័ន្ធ

ដំណើរការធានាគុណភាពអប់រំផ្ទៃក្នុង មានការចូលរួម និងសហការយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ចាប់តាំងពីគណៈគ្រប់គ្រង (គណៈគ្រប់គ្រងជាន់ខ្ពស់ និង គណៈគ្រប់គ្រង) គ្រូបង្រៀន និស្សិត និងបុគ្គលិកគាំទ្រគ្រប់ផ្នែក។ តាមរយៈការសម្ភាសន៍ជាមួយបុគ្គលិកអប់រំ ៣៩នាក់ ស្រី ៣នាក់ បានលើកឡើងថា បុគ្គលិកបានចូលរួមប្រជុំ ស្តីពីការផ្សព្វផ្សាយពីលទ្ធផលនៃការធានាគុណភាពផ្ទៃក្នុង និងតាមរយៈការសម្ភាសជាមួយនិស្សិត ៥៨នាក់ ស្រី ៣៧នាក់ និស្សិតបានចូលរួមក្នុងការវាយតម្លៃគ្រូ ប៉ុន្តែមិនបានដឹងពីដំណើរធានាគុណផ្ទៃក្នុងរបស់សាកលវិទ្យាល័យនោះទេ។ ជាមួយគ្នានេះផងដែរ តាមរយៈការស្ទង់មតិរបស់និស្សិតបានបង្ហាញថាមានតែ ៦៩% នៃនិស្សិត ដែលចូលរួមក្នុងដំណើរការ IQA ខណៈដែលភាគច្រើនមិនទាន់យល់ដឹងច្បាស់អំពីប្រព័ន្ធធានាគុណភាពរបស់សាកលវិទ្យាល័យ។ ការចូលរួមពីភាគីពាក់ព័ន្ធបង្ហាញថា ការផ្សព្វផ្សាយព័ត៌មាន និង Participatory QA Culture នៅមានកម្រិត ដូច្នេះផ្នែកធានាគុណភាព នៃសាកលវិទ្យាល័យគួរតែពង្រឹងយុទ្ធសាស្ត្រ ស្តីពី internal communication និង student-staff engagement ដើម្បីបង្កើនការយល់ដឹង និងទំនួលខុសត្រូវរួមក្នុង IQA។

### ៣. ការគាំទ្រពីថ្នាក់ដឹកនាំកំពូលរបស់គ្រឹះស្ថាន

សកលវិទ្យាល័យបានរៀបចំគោលការណ៍ និងដំណើរការយន្តការសម្រេចចិត្តទាក់ទងនឹងការវាយតម្លៃ និងធានាគុណភាពផ្ទៃក្នុង ដោយបានដឹកនាំ និងគាំទ្រយ៉ាងពេញទំហឹងដោយសាកលវិទ្យាធិការ និងថ្នាក់ដឹកនាំកំពូល ជាពិសេសសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ណែនាំដំណើរការធានាគុណភាពអប់រំផ្ទៃក្នុងដោយអនុលោមតាមស្តង់ដារជាតិ បន្សុីនិងបញ្ជ្រាបស្តង់ដារតំបន់ ក៏ដូចជាគោលការណ៍ណែនាំសំខាន់ៗកម្រិតអន្តរជាតិពាក់ព័ន្ធការធានាគុណភាព និងភាពត្រឹមត្រូវនៃប្រព័ន្ធធានាគុណភាពនៅសាកលវិទ្យាល័យ។ តាមរយៈការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់ថ្នាក់ដឹកនាំកំពូលនេះហើយ បានធ្វើឱ្យសាកលវិទ្យាល័យទទួលបានឆ្លងកាត់ការពិនិត្យ និងវាយតម្លៃពីផ្នែកធានាគុណភាពអប់រំពីខាងក្រៅតាមរយៈគម្រោងសហគមន៍

អឺរ៉ុប ជួយលើកកម្ពស់ឧត្តមសិក្សានៅអាស៊ាន (EU-SHARE Institutional Assessment) ក្នុងឆ្នាំ២០១៨ និង គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) នៅឆ្នាំ២០១៩។ ភាពសកម្មនៃថ្នាក់ដឹកនាំកំពូល ជាប៉ារ៉ាម៉ែត្រសំខាន់បំផុតនៃភាពជោគជ័យក្នុង IQA។ ទោះជាយ៉ាងណា ការចូលរួមសកម្មត្រូវបានពង្រីកទៅកាន់ថ្នាក់ដឹកនាំកម្រិតមធ្យម និងកម្រិតមូលដ្ឋាន ដើម្បីធានាថាបេសកកម្ម IQA ត្រូវបានបន្តដោយភាពស្មើគ្នា។

**៤. ធនធានគ្រប់គ្រាន់សម្រាប់បង្កើត និងគាំទ្រប្រព័ន្ធធានាគុណភាពអប់រំ**

ផ្នែកធានាគុណភាពរបស់សាកលវិទ្យាល័យ មានការិយាល័យដាច់ដោយឡែកដែលមានទំហំធំទូលាយ និងមានសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់ដំណើរការប្រព័ន្ធធានាគុណភាពអប់រំ។ ផ្នែកធានាគុណភាពអប់រំផ្ទៃក្នុងបានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការថវិកា (ប្រហែល៣០០០ ទៅ ៥០០០ដុល្លារ សហរដ្ឋអាមេរិក) និងទទួលបានការយល់ព្រមពីគណៈគ្រប់គ្រងជាន់ខ្ពស់រៀងរាល់ឆ្នាំ។ ជាមួយគ្នាផងដែរ ផ្នែកធានាគុណភាពអប់រំ ទទួលបានថវិកានៅក្នុងគម្រោង HEIP (២០២១-២០២៤) សម្រាប់ការអនុវត្តការងារ ការបណ្តុះបណ្តាល រៀបចំនិងចងក្រងសៀវភៅមគ្គុទ្ទេសន៍ធានាគុណភាពអប់រំផ្ទៃក្នុងឆ្នាំ២០២១។

**៥. លទ្ធផលស្វ័យវាយតម្លៃ ត្រូវយកទៅប្រើប្រាស់**

តាមរយៈលទ្ធផលស្វ័យវាយតម្លៃ សាកលវិទ្យាល័យបានបញ្ចូលចំណុច និងសកម្មភាពមួយចំនួនក្នុងផែនការសកម្មភាពដើម្បីកែលម្អលើចំណុចខ្វះខាតដែលបានរកឃើញ។ ជាក់ស្តែងបន្ទាប់ពីបានរៀបចំរបាយការណ៍ស្វ័យវាយតម្លៃរួច ក្រុមការងារទទួលបន្ទុកការងារធានាគុណភាពផ្ទៃក្នុងបានធ្វើការប្រជុំ ត្រួតពិនិត្យ និងផ្សព្វផ្សាយពីលទ្ធផលនៃរបាយការណ៍ស្វ័យវាយតម្លៃ ដោយបានបង្ហាញពីចំណុចខ្លាំង និងបានកែលម្អចំណុចខ្វះខាតភាគច្រើន។ ការយកលទ្ធផលស្វ័យវាយតម្លៃទៅប្រើប្រាស់ បង្ហាញពីភាពចាប់អារម្មណ៍ពីការលើកកម្ពស់គុណភាពអប់រំជាបន្ត។ ទោះយ៉ាងណា ប្រព័ន្ធតាមដានលទ្ធផល (follow-up monitoring mechanism) តម្រូវឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវាស់វែងសូចនាករ ដើម្បីកែលម្អ និងធ្វើឱ្យប្រសើរឡើងពី១ឆ្នាំទៅ១ឆ្នាំ។

**៦. ការវាយតម្លៃគុណផលការងារអ្នកទទួលបន្ទុក**

ផ្នែកធានាគុណភាពផ្ទៃក្នុងបានរៀបចំឧបករណ៍ស្ទង់មតិតែមួយវិធីសាស្រ្តប៉ុណ្ណោះ ជាមួយគណៈគ្រប់គ្រង និងគ្រូបង្រៀន ហើយបានធ្វើការវាយតម្លៃគុណផលតែទៅប្រធានទទួលបន្ទុក IQA តាមរយៈ Survey Google Form ប៉ុន្តែនៅមិនទាន់បានធ្វើការវាយតម្លៃគុណផលអនុគណៈកម្មការ១២រូបទទួលបន្ទុកស្តង់ដានីមួយៗ។ ប្រព័ន្ធវាយតម្លៃគុណផល (performance appraisal system) ត្រូវការបង្កើតសំណុំសូចនាករជាក់លាក់សម្រាប់អនុគណៈកម្មការ និងបុគ្គលិក IQA ទាំងអស់ ដើម្បីធានាថាការវាយតម្លៃមានភាពស្មើគ្នា និងអាចវាស់វែងបាន។

**ចំណុចខ្លាំង**

- មានគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ដែលមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំ១៥រូបរបស់សាកលវិទ្យាល័យ ហើយបានបណ្តុះបណ្តាលស្តីពីសិក្ខាសាលាស្តីពីស្តង់ដា និងសៀវភៅការទទួលស្គាល់គុណភាពអប់រំ

- មានប្រព័ន្ធ និងយន្តការវាយតម្លៃគុណភាព ហើយបានប្រកាសឱ្យអនុវត្តដោយមានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមប្រឹក្សាភិបាល ហើយបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីលើកកម្ពស់គុណភាពអប់រំជានិរន្តរ៍
- ផ្នែកធានាគុណភាពមានការិយាល័យដាច់ដោយឡែក និង បានអនុវត្តតាមផែនការថវិកាសម្រាប់គាំទ្រប្រព័ន្ធធានាគុណភាពប្រចាំឆ្នាំ។

**ចំណុចអនុវត្តបានល្អ**

- ថ្នាក់ដឹកនាំកំពូល និងគណៈគ្រប់គ្រងបានយកចិត្តទុកដាក់ និងចូលរួមលើកិច្ចការផ្នែកធានាគុណភាពផ្ទៃក្នុង ប៉ុន្តែការចូលរួមពីបុគ្គលិកអប់រំ និងនិស្សិតនៅមានកម្រិត
- បានកែលម្អចំណុចខ្វះខាតភាគច្រើន។

**ចំណុចកែលម្អ**

- បានធ្វើការវាយតម្លៃគុណផលប្រធានទទួលបន្ទុក IQA ប៉ុន្តែនៅមិនទាន់បានធ្វើការវាយតម្លៃគុណផលអនុគណៈកម្មការ១២រូបទទួលបន្ទុកស្តង់ដានីមួយៗ។

**សេចក្តីសន្និដ្ឋាន**

ជារួម សាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមសូចនាករតម្រូវនៃស្តង់ដា៩។ សាកលវិទ្យាល័យមានគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ដែលទទួលបានបណ្តុះបណ្តាលស្តីពីស្តង់ដា និងសៀវភៅណែនាំនៃការទទួលស្គាល់គុណភាពអប់រំ ព្រមទាំងមានប្រព័ន្ធ និងយន្តការវាយតម្លៃគុណភាព ហើយបានប្រកាសឱ្យអនុវត្តដោយមានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមប្រឹក្សាភិបាល និង បានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីលើកកម្ពស់គុណភាពអប់រំជានិរន្តរ៍។ ផ្នែកធានាគុណភាពមានការិយាល័យដាច់ដោយឡែក និង បានអនុវត្តតាមផែនការថវិកាសម្រាប់គាំទ្រប្រព័ន្ធធានាគុណភាពប្រចាំឆ្នាំ។ ថ្នាក់ដឹកនាំកំពូល និងគណៈគ្រប់គ្រងបានយកចិត្តទុកដាក់ និងចូលរួមលើកិច្ចការផ្នែកធានាគុណភាពផ្ទៃក្នុង ប៉ុន្តែការចូលរួមពីបុគ្គលិកអប់រំ និងនិស្សិតនៅមានកម្រិត។ សាកលវិទ្យាល័យបានកែលម្អចំណុចខ្វះខាតភាគច្រើន និង បានធ្វើការវាយតម្លៃគុណផលប្រធានទទួលបន្ទុក IQA ប៉ុន្តែនៅមិនទាន់បានធ្វើការវាយតម្លៃគុណផលអនុគណៈកម្មការ១២រូបទទួលបន្ទុកស្តង់ដានីមួយៗ។

**អនុសាសន៍**

ដើម្បីអនុវត្តស្តង់ដា៩ឱ្យកាន់តែប្រសើរ សាកលវិទ្យាល័យត្រូវ៖

- ពង្រឹងប្រព័ន្ធវាយតម្លៃគុណផលអ្នកទទួលបន្ទុក IQA ទាំងអស់តាមរយៈការកំណត់សូចនាករវាស់វែងលទ្ធផលសមស្រប និងអនុវត្តការវាយតម្លៃប្រចាំឆ្នាំ។

**សំណូមពរ**

ដើម្បីអនុវត្តស្តង់ដា៩ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត សាកលវិទ្យាល័យគប្បីគួរ៖

- បង្កើតប្រព័ន្ធតាមដានលទ្ធផល ដើម្បីវាស់វែងផលប៉ះពាល់នៃសកម្មភាពកែលម្អ និងផ្តល់ទិន្នន័យសម្រាប់ការសម្រេចចិត្ត
- បញ្ជ្រាបការយល់ដឹងដល់គ្រូបង្រៀននិងនិស្សិត អំពីការធានាគុណភាពអប់រំផ្ទៃក្នុង និង ជំរុញឱ្យមានការចូលរួម។

## តារាងសង្ខេបលទ្ធផលនៃការវាយតម្លៃ

| ស្តង់ដា | ពិន្ទុ | ចំណុចខ្លាំង | ចំណុចអនុវត្តបានល្អ | ចំណុចកែលម្អ |
|---|---|---|---|---|
| ១. ចក្ខុវិស័យ បេសកកម្ម និង គោលបំណង | | - បុគ្គលិកនិងគ្រូបង្រៀនបានចូលរួមសកម្មភាពសង្គមនិងសេវាសហគមន៍។ | - និស្សិតភាគច្រើនបញ្ចប់ការសិក្សាមានការងារធ្វើនិង មានការងារធ្វើស្របនឹងជំនាញភាគច្រើន<br>- បានបោះពុម្ពអត្ថបទស្រាវជ្រាវ និង សៀវភៅស្រាវជ្រាវច្រើនកម្រិតគ្រឹះស្ថាន និងជាតិ និងកម្រិតអន្តរជាតិមួយចំនួន | |
| ២. អភិបាលកិច្ច និង ការគ្រប់គ្រង | | - ក្រុមប្រឹក្សាភិបាលបានអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងារស្របតាមលក្ខខន្តិកៈ ហើយគណៈគ្រប់គ្រងនិងក្រុមប្រឹក្សាអប់រំបានប្រជុំពិភាក្សាគ្នារៀងរាល់ត្រីមាសដើម្បីពិនិត្យមើល និង កែលម្អកម្មវិធីសិក្សា<br>- ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និង ក្រុមប្រឹក្សាអប់រំមានគុណវុឌ្ឍិ និង បទពិសោធន៍ស្របតាមតួនាទីនិងភារកិច្ច និងលក្ខខន្តិកៈ ហើយបានអនុវត្តស្របតាមគោលការណ៍ | - បានតែងតាំងមុខតំណែងភាគច្រើននៃរចនាសម្ព័ន្ធគ្រប់គ្រង និងអនុវត្តស្របតាមអនុក្រឹត្យនៃការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ<br>- បានអនុវត្តភាគច្រើននៃផែនការយុទ្ធសាស្ត្រ ហើយបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស និងឆ្នាំ។ | |

| | | | | |
|---|---|---|---|---|
| | | - ក្រុមប្រឹក្សាភិបាលបានធ្វើស្វ័យវាយតម្លៃការងាររបស់ខ្លួនជាប្រចាំរៀងរាល់ឆ្នាំតាមរយៈការកំណត់ពេលវេលាប្រជុំច្បាស់លាស់ និងបានប្រៀបធៀបសមិទ្ធផលការងារក្នុងរយៈពេលប្រាំឆ្នាំ។ | | |
| ៣. បុគ្គលិកអប់រំ | | - គុណវឌ្ឍិ បទពិសោធន៍ និងជំនាញរបស់គ្រូបង្រៀនស្របតាមកម្រិតបណ្ឌុះបណ្ដាល និងមុខវិជ្ជាបង្រៀន<br>- ការបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗមិនលើស២៤ម៉ោងក្នុងមួយសប្ដាហ៍ និង ៣ មុខវិជ្ជាក្នុងមួយឆមាស<br>- បានវាយតម្លៃគ្រូបង្រៀនរៀងរាល់ឆមាស ដោយប្រើវិធីសាស្ត្រវាយតម្លៃច្រើនយ៉ាង<br>- គ្រូបង្រៀនម្នាក់ៗបានទទួលលទ្ធផលវាយតម្លៃ នៅរៀងរាល់ចុងឆមាសនីមួយៗ។ | - ចំនួនគ្រូបង្រៀនពេញម៉ោងពុំទាន់ស្របតាមគោលការណ៍របស់ គ.ទ.ក<br>- បានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកភាគច្រើនធៀបនឹងផែនការ និងកញ្ចប់ថវិកាដែលបានកំណត់<br>- បានរៀបចំគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន។ | - សំណុំឯកសាររបស់គ្រូបង្រៀនពុំទាន់បានរក្សាទុកស្របតាមការណែនាំរបស់ គ.ទ.ក និងពុំទាន់រៀបចំជាប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀន<br>- គ្រូបង្រៀនភាគច្រើនពុំទាន់ពេញចិត្តប្រាក់បៀវត្សនិងផលប្រយោជន៍នានា<br>- មានកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន ប៉ុន្តែពុំទាន់បានចំណាយលើសកម្មភាពស្រាវជ្រាវ |

| | | | | |
|---|---|---|---|---|
| ៤. កម្មវិធីអប់រំ | | - កម្មវិធីអប់រំស្ទើរតែទាំងអស់ មានលទ្ធផលសិក្សារំពឹងទុកស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ<br>- គ្រឹះស្ថានបានកំណត់ចំនួនក្រេឌីតសិក្សាបានត្រឹមត្រូវ និងអនុវត្តស្របតាមប្រព័ន្ធក្រេឌីត<br>- បានពិនិត្យនិងកែលម្អកម្មវិធីអប់រំស្របតាមយន្តការដែលបានកំណត់ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ | - ភាគច្រើននៃមុខវិជ្ជាទាំងអស់ មានប្លង់មុខវិជ្ជាលម្អិត<br>- ភាគច្រើននៃមុខវិជ្ជាទាំងអស់ មានលទ្ធផលសិក្សារំពឹងទុក<br>- បានប្រើវិធីសាស្ត្រច្រើនយ៉ាងក្នុងការវាយតម្លៃនិស្សិត ហើយបានផ្ទូរផ្ទងរវាងលទ្ធផលសិក្សារំពឹងទុក វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ។ | |
| ៥. សេវានិស្សិត | | - អនុវត្តការជ្រើសរើសនិស្សិតស្របតាមគោលការណ៍ដែលបានកំណត់<br>- បានផ្តល់អាហារូបករណ៍អនុលោមគោលការណ៍ដែលបានកំណត់<br>- បានធ្វើការស្រាវជ្រាវលើជំនាន់និស្សិតដែលបានបញ្ចប់ការសិក្សាប្រចាំឆ្នាំ<br>- បានដោះស្រាយការតវ៉ារបស់និស្សិត។ | - បុគ្គលិកគ្រប់គ្រងនិងបុគ្គលិកប្រតិបត្តិភាគច្រើនមានគុណវុឌ្ឍិស្របតាមតួនាទីភារកិច្ច<br>- និស្សិតភាគច្រើនពេញចិត្តលើសេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និងកម្មវិធីអប់រំសុខភាព<br>- និស្សិតចូលរៀនថ្មីភាគច្រើនទទួលបានការណែនាំតម្រង់ទិស<br>- និស្សិតមានឱកាសនិងបានចូលរួមហ្វឹកហាត់ការងារបន្ថែមលើការសិក្សា | - បានប្រឹក្សាយោបល់លើការសិក្សារបស់និស្សិត ប៉ុន្តែពុំទាន់បានវាយតម្លៃនិងប្រៀបធៀបលទ្ធផលវាយតម្លៃដើម្បីកែលម្អ។ |

| | | | | |
|---|---|---|---|---|
| | | | - បានផ្សព្វផ្សាយនិងជួយរកការងារឱ្យនិស្សិត<br>- និស្សិតបានចូលរួមសកម្មភាពសង្គម និងសេវាសហគមន៍<br>- និស្សិតភាគច្រើនបញ្ចប់ការសិក្សាធៀបទៅនឹងចំនួននិស្សិតតាមជំនាន់នីមួយៗ។ | |
| ៦. ធនធានសិក្សា | | - បណ្ណាល័យមានទំហំសមស្របតាមចំនួននិស្សិតតាមវេនសិក្សា និងមានបរិយាកាសអំណោយផលដល់ការសិក្សា និងស្រាវជ្រាវ<br>- ម៉ោងបើកបណ្ណាល័យឆ្លើយតបនឹងតម្រូវការនិស្សិត និងគ្រូបង្រៀន<br>- បន្ទប់ពិសោធន៍ទូទៅ និងឯកទេសឆ្លើយតបនឹងតម្រូវការនៃកម្មវិធី<br>- បានអនុវត្តតាមផែនការអភិវឌ្ឍន៍បន្ទប់អនុវត្ត។ | - បុគ្គលិកបណ្ណាល័យភាគច្រើនបានទទួលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបណ្ណាល័យពីបណ្ណារក្ស<br>- និស្សិតស្ទើរតែទាំងអស់ និងគ្រូបង្រៀនភាគច្រើនទទួលបានការណែនាំតម្រង់ទិសពីការប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ<br>- បណ្ណាល័យមានថវិកាមួយចំនួនសម្រាប់គាំទ្រសេវាបណ្ណាល័យ<br>- សៀវភៅសិក្សាឯកសារយោង និងទស្សនាវដ្ដីវិទ្យាសាស្ត្រឆ្លើយតបទៅនឹងកម្មវិធីអប់រំ | - ពុំទាន់មានបណ្ណាល័យអេឡិចត្រូនិក។ |

| | | | | |
|---|---|---|---|---|
| | | | - បុគ្គលិកនៃបន្ទប់អនុវត្តន៍បានឆ្លងកាត់ការបណ្តុះបណ្តាល<br>- បានអនុវត្តគោលការណ៍សុវត្ថិភាពរបស់សាកលវិទ្យាល័យភាគច្រើន<br>- បានផ្តល់ធនធានបច្ចេកវិទ្យានិងអ៊ីនធឺណិតបម្រើការបង្រៀននិងសិក្សាបានភាគច្រើន<br>- និស្សិតនិងគ្រូបង្រៀនភាគច្រើនទទួលបានការបណ្តុះបណ្តាលពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា<br>- បុគ្គលិកគាំទ្របច្ចេកវិទ្យាជួយសម្រួលបច្ចេកទេសតាមតម្រូវការភាគច្រើន។ | |
| ៧. ធនធានរូបវន្ត | | - មានធនធានរូបវន្តសម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ និងសកម្មភាពផ្សេងៗ រួមទាំងសកម្មភាពសិក្សានិងសកម្មភាពបន្ថែមដែលកំពុងសិក្សានិងអនាគតបានគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការ | | |

| | | | | |
|---|---|---|---|---|
| | | - មានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាពរួមទាំងសុវត្ថិភាពចំណតនិងសណ្តាប់ធ្នាប់ល្អប្រសើរ<br>- បានធ្វើការណែនាំនិងផ្សព្វផ្សាយពីការអនុវត្ត សុខភាព សុវត្ថិភាព សន្តិសុខ និងបានធ្វើការវាយតម្លៃជាប្រចាំ ព្រមទាំងបានធ្វើការកែលម្អរឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញ។<br>- មានគោលនយោបាយស្តីពីការគ្រប់គ្រងថែរក្សាប្រព័ន្ធអេឡិចត្រូនិក ការពារអគ្គីភ័យ ការថតចំលង ព្រមទាំងបានអនុវត្តតាមគោលការណ៍កំណត់បានយ៉ាងល្អប្រសើរ<br>- មានផែនការអភិវឌ្ឍន៍ធនធានរូបវន្តច្បាស់លាស់ ព្រមទាំងបានអនុវត្តសម្រេចតាមផែនការដែលបានកំណត់ ១០០%។ | | |
| ៨. ធនធានហិរញ្ញវត្ថុ | | - បានបើកប្រាក់បៀវត្សនិងប្រាក់ឈ្នួលរបស់គ្រូ | - បានអនុវត្តថវិកាប្រចាំឆ្នាំបានភាគច្រើន។ | - ពុំទាន់បានធ្វើសវនកម្ម។ |

| | | | | |
|---|---|---|---|---|
| | | បង្រៀន និងបុគ្គលិកគ្រប់ចំនួននិងទាន់ពេលកំណត់<br>- បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំជូនថ្នាក់ដឹកនាំតាមពេលកំណត់<br>- មានតំណាងគ្រប់ភាគីពាក់ព័ន្ធបានចូលរួមក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ<br>- បានបញ្ជូនរបាយការណ៍ចំណូល-ចំណាយ តារាងតុល្យការ របាយការណ៍លំហូរសាច់ប្រាក់ របាយការណ៍វិភាគហិរញ្ញវត្ថុ ទៅក្រុមប្រឹក្សាភិបាលទាន់ពេលវេលាដែលបានកំណត់។ | | |
| ៩. ការធានាគុណភាពអប់រំផ្ទៃក្នុង | | - មានគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ហើយបានបណ្តុះបណ្តាល ស្តីពីស្តង់ដា និងសៀវភៅការទទួលស្គាល់គុណភាពអប់រំ<br>- មានប្រព័ន្ធ និងយន្តការវាយតម្លៃគុណភាព ហើយបានប្រកាសឱ្យអនុវត្តដោយមានការ | - ថ្នាក់ដឹកនាំកំពូល និងគណៈគ្រប់គ្រងបានយកចិត្តទុកដាក់ និងចូលរួមលើកិច្ចការផ្នែកធានាគុណភាពផ្ទៃក្នុង<br>- បានកែលម្អចំណុចខ្វះខាតភាគច្រើន។ | - បានធ្វើការវាយតម្លៃគុណផលប្រធានទទួលបន្ទុក IQA ប៉ុន្តែនៅមិនទាន់បានធ្វើការវាយតម្លៃគុណផលអនុគណៈកម្មការ១២រូបទទួលបន្ទុកស្តង់ដានីមួយៗ។ |

| | | | | |
|---|---|---|---|---|
| | | គាំទ្រយ៉ាងពេញទំហឹងពីក្រុមប្រឹក្សាភិបាល ហើយបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីលើកកម្ពស់គុណភាពអប់រំជានិរន្តរ៍<br>- ផ្នែកធានាគុណភាពមានការិយាល័យដាច់ដោយឡែក និងបានអនុវត្តតាមផែនការថវិកាសម្រាប់គាំទ្រប្រព័ន្ធធានាគុណភាពប្រចាំឆ្នាំ។ | | |
| **ពិន្ទុមធ្យមភាគ** | | | | |

## ៤. សេចក្តីសន្និដ្ឋានរួម

ជារួមសាកលវិទ្យាល័យអនុវត្តបានភាគច្រើនស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដាទាំង៩។ សាកលវិទ្យាល័យបានអនុវត្តសកម្មភាពសង្គមនិងសេវាសហគមន៍ ព្រមទាំងមានការចូលរួមបុគ្គលិកនិងគ្រូបង្រៀន។ និស្សិតភាគច្រើនបញ្ចប់ការសិក្សាមានការងារធ្វើ និង មានការងារធ្វើស្របនឹងជំនាញ ៥៤%។ សាកលវិទ្យាល័យបានបោះពុម្ពអត្ថបទស្រាវជ្រាវ និងសៀវភៅស្រាវជ្រាវច្រើនកម្រិតគ្រឹះស្ថាន និងជាតិ និងកម្រិតអន្តរជាតិមួយចំនួន ប៉ុន្តែពុំទាន់រៀបចំទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រជាទម្រង់ទន់ និង ទម្រង់រឹង។

ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាអប់រំមានគុណវុឌ្ឍិ និងបទពិសោធន៍ស្របតាមតួនាទី និងភារកិច្ច ហើយគណៈគ្រប់គ្រងនិងក្រុមប្រឹក្សាអប់រំបានប្រជុំពិភាក្សាគ្នារៀងរាល់ត្រីមាសដើម្បីពិនិត្យមើល និងកែលម្អកម្មវិធីសិក្សា។ ក្រុមប្រឹក្សាភិបាលបានធ្វើស្វ័យវាយតម្លៃការងាររបស់ខ្លួនជាប្រចាំរៀងរាល់ឆ្នាំ និង បានប្រៀបធៀបសមិទ្ធផលការងារ។ សាកលវិទ្យាល័យបានតែងតាំងមុខតំណែងភាគច្រើននៃរចនាសម្ព័ន្ធគ្រប់គ្រង និង បានអនុវត្តភាគច្រើននៃផែនការយុទ្ធសាស្ត្រ ហើយបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស និងឆ្នាំ ប៉ុន្តែពុំមានរបាយការណ៍ពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ដែលបង្ហាញពីចំនួនកម្មវិធី ចង្កោមសកម្មភាព និង សូចនាករ ដែលបានអនុវត្តនិងសម្រេចបាន។

គុណវឌ្ឍិ បទពិសោធន៍ និង ជំនាញរបស់គ្រូបង្រៀនស្របតាមកម្រិតបណ្តុះបណ្តាល និង មុខវិជ្ជាបង្រៀន។ ការបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗមិនលើស២៤ម៉ោងក្នុងមួយសប្តាហ៍ និង ៣មុខវិជ្ជាក្នុងមួយឆមាស។ សាកលវិទ្យាល័យបានវាយតម្លៃគ្រូបង្រៀនរៀងរាល់ឆមាស ដោយប្រើវិធីសាស្ត្រវាយតម្លៃច្រើនយ៉ាង និង គ្រូបង្រៀនទទួលលទ្ធផលវាយតម្លៃនៅរៀងរាល់ចុងឆមាសនីមួយៗ។ ចំនួនគ្រូបង្រៀនពេញម៉ោងពុំទាន់ឆ្លើយតបពេញលេញតាមគោលការណ៍របស់ គ.ទ.ក។ សាកលវិទ្យាល័យបានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាព

គ្រូបង្រៀននិងបុគ្គលិកភាគច្រើនធៀបនឹងផែនការនិងកញ្ចប់ថវិកាដែលបានកំណត់ ព្រមទាំងបានរៀបចំគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន។ សំណុំឯកសាររបស់គ្រូបង្រៀនពុំទាន់បានរក្សាទុកស្របតាមការណែនាំរបស់ គ.ទ.ក និងពុំទាន់រៀបចំជាប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀន។ គ្រូបង្រៀនភាគច្រើនពុំទាន់ពេញចិត្តប្រាក់បៀវត្សនិងផលប្រយោជន៍នានា។ សាកលវិទ្យាល័យមានកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន ប៉ុន្តែពុំទាន់បានចំណាយលើសកម្មភាពស្រាវជ្រាវ។

កម្មវិធីអប់រំស្ទើរតែទាំងអស់ មានលទ្ធផលសិក្សារំពឹងទុកស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ។ ភាគច្រើននៃមុខវិជ្ជាទាំងអស់ មានប្លង់មុខវិជ្ជាលម្អិត និងលទ្ធផលសិក្សារំពឹងទុក។ គ្រឹះស្ថានបានកំណត់ចំនួនក្រេឌីតសរុបបានត្រឹមត្រូវ និងអនុវត្តស្របតាមប្រព័ន្ធក្រេឌីត។ គ្រូបង្រៀនបានប្រើវិធីសាស្ត្រច្រើនយ៉ាងក្នុងការវាយតម្លៃនិស្សិត ហើយបានផ្ទៀងផ្ទាត់រវាងលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជា និង វិធីសាស្ត្រវាយតម្លៃ។ មិនតែប៉ុណ្ណោះ សាកលវិទ្យាល័យបានពិនិត្យនិងកែលម្អកម្មវិធីអប់រំស្របតាមយន្តការដែលបានកំណត់ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

សាកលវិទ្យាល័យបានអនុវត្តការជ្រើសរើសនិស្សិត និងការផ្តល់អាហារូបករណ៍ ស្របតាមគោលការណ៍ដែលបានកំណត់ ព្រមទាំងបានធ្វើការស្រាវជ្រាវលើជំនាន់និស្សិតដែលបានបញ្ចប់ការសិក្សាប្រចាំឆ្នាំ និង បានដោះស្រាយរាល់ការតវ៉ារបស់និស្សិត។ បុគ្គលិកគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិភាគច្រើនមានគុណវុឌ្ឍិស្របតាមតួនាទីភារកិច្ច។ និស្សិតភាគច្រើនពេញចិត្តលើសេវាប្រឹក្សាសុខភាពផ្លូវចិត្ត សេវាសុខភាព និងកម្មវិធីអប់រំសុខភាព។ និស្សិតចូលរៀនថ្មីភាគច្រើនទទួលបានការណែនាំតម្រង់ទិស។ និស្សិតមានឱកាស និងបានចូលរួមហ្វឹកហាត់ការងារបន្ថែមលើការសិក្សា ប៉ុន្តែពុំទាន់បានរៀបចំគោលការណ៍ហ្វឹកហាត់ការងារ។ សាកលវិទ្យាល័យបានផ្សព្វផ្សាយនិងជួយរកការងារឱ្យនិស្សិត ប៉ុន្តែពុំទាន់បានតាមដានអំពីលទ្ធផលការងាររបស់និស្សិត។ និស្សិតបានចូលរួមសកម្មភាពសង្គម និងសេវាសហគមន៍ ប៉ុន្តែពុំទាន់បានរៀបចំឱ្យមានផែនការច្បាស់លាស់។ អត្រានិស្សិតភាគច្រើនបានបញ្ចប់ការសិក្សាតាមជំនាន់នីមួយៗ។

បណ្ណាល័យមានទំហំសមស្របតាមចំនួននិស្សិតតាមវេនសិក្សា និងមានបរិយាកាសអំណោយផល ហើយម៉ោងបើកបម្រើសេវាបណ្ណាល័យឆ្លើយតបនឹងតម្រូវការនិស្សិតនិងគ្រូបង្រៀន។ បុគ្គលិកបណ្ណាល័យភាគច្រើនបានទទួលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបណ្ណាល័យពីបណ្ណារក្ស។ និស្សិតស្ទើរតែទាំងអស់ និងគ្រូបង្រៀនភាគច្រើនទទួលបានការណែនាំតម្រង់ទិសពីការប្រើប្រាស់បណ្ណាល័យ និងធនធានសិក្សាផ្សេងៗ។ សៀវភៅសិក្សា ឯកសារយោង និងទស្សនាវដ្តីវិទ្យាសាស្ត្រឆ្លើយតបទៅនឹងកម្មវិធីអប់រំ ប៉ុន្តែភាគច្រើនឯកសារយោងនិងទស្សនាវដ្តីវិទ្យាសាស្ត្រមានអាយុកាលលើសពី១០ឆ្នាំ។ បណ្ណាល័យមានថវិកាមួយចំនួនសម្រាប់គាំទ្រសេវាបណ្ណាល័យ។ សាកលវិទ្យាល័យពុំទាន់មានបណ្ណាល័យអេឡិចត្រូនិក។

សាកលវិទ្យាល័យបានអនុវត្តតាមផែនការអភិវឌ្ឍន៍បន្ទប់អនុវត្ត ហើយបន្ទប់ពិសោធន៍ទូទៅ និងឯកទេសឆ្លើយតបនឹងតម្រូវការនៃកម្មវិធី។ បុគ្គលិកនៃបន្ទប់អនុវត្តន៍បានឆ្លងកាត់ការបណ្តុះបណ្តាល ប៉ុន្តែបុគ្គលិកមួយចំនួនពុំទាន់ឆ្លើយតបទៅនឹងតម្រូវការនិស្សិត។ សាកលវិទ្យាល័យ បានអនុវត្តគោលការណ៍សុវត្ថិភាពរបស់សាកលវិទ្យាល័យភាគច្រើន។

សាកលវិទ្យាល័យបានផ្តល់ធនធានបច្ចេកវិទ្យា និងអ៊ីនធឺណិតបម្រើការបង្រៀននិងសិក្សាបានភាគច្រើន ហើយបុគ្គលិកគាំទ្របច្ចេកវិទ្យាជួយសម្រួលបច្ចេកទេសតាមតម្រូវការបានភាគច្រើនផងដែរ។ និស្សិត និង គ្រូបង្រៀនភាគច្រើន ទទួលបានការបណ្តុះបណ្តាលពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា។

សាកលវិទ្យាល័យមានធនធានរូបវន្តសម្រាប់បំពេញបេសកកម្ម កម្មវិធីអប់រំ និងសកម្មភាពផ្សេងៗ ព្រមទាំងមានបរិស្ថានប្រកបដោយផាសុកភាពនិងសុវត្ថិភាព រួមទាំងសុវត្ថិភាពចំណត និងសណ្តាប់ធ្នាប់ល្អប្រសើរ។ សាកលវិទ្យាល័យបានធ្វើការណែនាំនិងផ្សព្វផ្សាយពីការអនុវត្តសុខភាព សុវត្ថិភាព សន្តិសុខ និងបានធ្វើការវាយតម្លៃជាប្រចាំ ព្រមទាំងបានធ្វើការកែលម្អឆ្លើយតបទៅនឹងលទ្ធផលដែលបានរកឃើញ។ សាកលវិទ្យាល័យបានអនុវត្តតាមគោលការណ៍ ស្តីពីការគ្រប់គ្រង ថែរក្សាប្រព័ន្ធអេឡិចត្រូនិក ការការពារអគ្គីភ័យ និងការថតចំលង ព្រមទាំងអនុវត្តសម្រេចបាន១០០%តាមផែនការអភិវឌ្ឍធនធានរូបវន្តដែលបានកំណត់។

សាកលវិទ្យាល័យបានរៀបចំផែនការថវិកាប្រចាំឆ្នាំ ដោយមានការចូលរួមពីតំណាងគ្រប់ភាគីពាក់ព័ន្ធ និងបានអនុវត្តថវិកាប្រចាំឆ្នាំបានភាគច្រើន ព្រមទាំងបានរៀបចំរបាយការណ៍ចំណូល-ចំណាយ តារាងតុល្យការ របាយការណ៍លំហូរសាច់ប្រាក់ និង របាយការណ៍ទ្រព្យម្ចាស់ និងបានបញ្ជូនទៅក្រុមប្រឹក្សាភិបាលទាន់ពេលវេលាដែលបានកំណត់។ សាកលវិទ្យាល័យបានបើកប្រាក់បៀវត្សនិងប្រាក់ឈ្នួលរបស់គ្រូបង្រៀន និងបុគ្គលិកគ្រប់ចំនួននិងទាន់ពេលកំណត់។ ប៉ុន្តែសាកលវិទ្យាល័យពុំទាន់បានធ្វើសវនកម្ម។

សាកលវិទ្យាល័យមានគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ដែលទទួលបានបណ្តុះបណ្តាលស្តីពីស្តង់ដា និងសៀវភៅណែនាំនៃការទទួលស្គាល់គុណភាពអប់រំ ព្រមទាំងមានប្រព័ន្ធ និងយន្តការវាយតម្លៃគុណភាព ហើយបានប្រកាសឱ្យអនុវត្តដោយមានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមប្រឹក្សាភិបាល និង បានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីលើកកម្ពស់គុណភាពអប់រំជានិរន្តរ៍។ ផ្នែកធានាគុណភាពមានការិយាល័យដាច់ដោយឡែក និង បានអនុវត្តតាមផែនការថវិកាសម្រាប់គាំទ្រប្រព័ន្ធធានាគុណភាពប្រចាំឆ្នាំ។ ថ្នាក់ដឹកនាំកំពូល និងគណៈគ្រប់គ្រងបានយកចិត្តទុកដាក់ និងចូលរួមលើកិច្ចការផ្នែកធានាគុណភាពផ្ទៃក្នុង ប៉ុន្តែការចូលរួមពីបុគ្គលិកអប់រំ និងនិស្សិតនៅមានកម្រិត។ សាកលវិទ្យាល័យបានកែលម្អចំណុចខ្វះខាតភាគច្រើន និង បានធ្វើការវាយតម្លៃគុណផលប្រធានទទួលបន្ទុក IQA ប៉ុន្តែនៅមិនទាន់បានធ្វើការវាយតម្លៃគុណផលអនុគណៈកម្មការ១២រូបទទួលបន្ទុកស្តង់ដានីមួយៗ។

## ៥. អនុសាសន៍

ដើម្បីអនុវត្តស្តង់ដាជាតិទាំង៩ឱ្យកាន់តែប្រសើរឡើង សាកលវិទ្យាល័យត្រូវ៖

- សិក្សាស្រាវជ្រាវពីតម្រូវការគ្រូបង្រៀន និងកែសម្រួលអត្រាប្រាក់ម៉ោងបង្រៀននិងផលប្រយោជន៍នានាសម្រាប់រក្សាគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ទាំងគ្រូបង្រៀនពេញម៉ោង និងវេលាការ
- រក្សាទុកសំណុំឯកសាររបស់គ្រូបង្រៀនឱ្យស្របតាមការណែនាំរបស់ គ.ទ.ក និង រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់គ្រូបង្រៀន
- អនុវត្តកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដល់ការស្រាវជ្រាវរបស់គ្រូបង្រៀន ឱ្យស្របតាមផែនការដែលបានកំណត់
- វាយតម្លៃប្រព័ន្ធប្រឹក្សាយោបល់លើការសិក្សាជារៀងរាល់ឆ្នាំ និងប្រើប្រាស់លទ្ធផលវាយតម្លៃដើម្បីប្រៀបធៀបនិងកែលម្អ
- ធ្វើទំនើបកម្មបណ្ណាល័យអេឡិចត្រូនិក ឱ្យបានពេញលេញដើម្បីឱ្យនិស្សិត និងគ្រូបង្រៀនអាចទាញយកឯកសារផ្សេងៗពីចម្ងាយសម្រាប់សិក្សាស្រាវជ្រាវ
- រៀបចំគោលការណ៍ ស្តីពីការធ្វើសវនកម្មផ្ទៃក្នុង និងអនុវត្តតាមគោលការណ៍ដែលបានកំណត់ និង/ឬធ្វើសវនកម្មពីខាងក្រៅ

- ពង្រឹងប្រព័ន្ធវាយតម្លៃគុណផលអ្នកទទួលបន្ទុក IQA ទាំងអស់តាមរយៈការកំណត់សូចនាករវាស់វែងលទ្ធផលសមស្រប និងអនុវត្តការវាយតម្លៃប្រចាំឆ្នាំ។

## ៦. សំណូមពរ

ដើម្បីអនុវត្តស្តង់ដាជាតិទាំង៩ឱ្យកាន់តែប្រសើរឡើងថែមទៀត សាកលវិទ្យាល័យគប្បីគួរៈ

- សិក្សាស្រាវជ្រាវបន្ថែមអំពីតម្រូវការភាគីពាក់ព័ន្ធ ដោយដេប៉ាតឺម៉ង់ជំនាញនីមួយៗ ដើម្បីកែលម្អកម្មវិធីអប់រំឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ
- រៀបចំទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រជាទម្រង់ទន់ និងទម្រង់រឹង ដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវរបស់សាកលវិទ្យាល័យ
- តែងតាំងមុខតំណែងព្រឹទ្ធបុរសមហាវិទ្យាល័យពាណិជ្ជសាស្ត្រនិងទេសចរណ៍ មហាវិទ្យាល័យនីតិសាស្ត្រនិងសេដ្ឋកិច្ច សាលាក្រោយបរិញ្ញាបត្រ និង ប្រធានការិយាល័យហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ និងរបាយការណ៍បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រដែលបង្ហាញពីចំនួនកម្មវិធី ចង្កោមសកម្មភាព និង សូចនាករ ដែលបានអនុវត្ត និងសម្រេចបាន
- ជ្រើសរើសគ្រូបង្រៀនពេញម៉ោងបន្ថែមទៀត
- អនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងបុគ្គលិកឱ្យស្របតាមផែនការ និងកញ្ចប់ថវិកាដែលបានកំណត់
- អនុវត្តគោលការណ៍ដំឡើងឋានៈគ្រូបង្រៀន
- សរសេរនិងធ្វើបច្ចុប្បន្នកម្ម ប្លង់មុខវិជ្ជាលម្អិត រួមទាំងលទ្ធផលសិក្សារំពឹងទុក ឱ្យបានគ្រប់កម្មវិធីអប់រំ
- ផ្ទៀងផ្ទាត់វិធីសាស្ត្រវាយតម្លៃនៃមុខវិជ្ជា ទៅនឹងលទ្ធផលសិក្សារំពឹងទុក ឱ្យបានគ្រប់មុខវិជ្ជាទាំងអស់ ក៏ដូចជាផ្ទៀងផ្ទាត់វិធីសាស្ត្រវាយតម្លៃបញ្ចប់ការសិក្សា ទៅនឹងលទ្ធផលសិក្សារំពឹងទុកនៃគ្រប់កម្មវិធីអប់រំ
- បង្កើនបុគ្គលិកសេវានិស្សិតពេញម៉ោងបន្ថែមទៀត ដែលមានកម្រិតគុណវុឌ្ឍិនិងបទពិសោធន៍ខ្ពស់ ដើម្បីធានាស្ថិរភាពនៃការងារ និងការឆ្លើយតបទៅនឹងតម្រូវការនិស្សិត
- វាយតម្លៃពីប្រសិទ្ធភាពលើការផ្តល់សេវាសុខភាពផ្លូវចិត្ត សេវាសុខភាព និង កម្មវិធីអប់រំសុខភាព ដើម្បីកែលម្អគុណភាពនៃសេវាកម្ម
- ណែនាំតម្រង់ទិសនិស្សិតថ្មីឱ្យបានទូលំទូលាយ
- រៀបចំគោលការណ៍ ស្តីពីការហ្វឹកហាត់ការងារឱ្យបានច្បាស់លាស់ឆ្លើយតបទៅនឹងតម្រូវការនៃកម្មវិធីអប់រំ
- តាមដានអំពីលទ្ធផលការងាររបស់និស្សិត ដើម្បីបន្តកែលម្អវិធានការផ្សេងៗ និងការរៀបចំផែនការអភិវឌ្ឍអាជីពនិស្សិតឱ្យបានច្បាស់លាស់
- រៀបចំផែនការក្នុងការផ្តល់សេវាសហគមន៍ និងសកម្មភាពជួយសង្គមប្រចាំឆ្នាំឱ្យបានច្បាស់លាស់
- សិក្សាអំពីមូលហេតុនៃការបោះបង់ចោលការសិក្សា ផ្ទេរចូល និងផ្ទេរចេញ ដើម្បីរៀបចំកែលម្អគោលការណ៍ ស្តីពីភាពជោគជ័យក្នុងការសិក្សា ការថែរក្សានិស្សិត និង អត្រាបញ្ចប់ការសិក្សា

- ធ្វើបច្ចុប្បន្នកម្ម និងបន្ថែមសៀវភៅសិក្សា ឯកសាយោង ជាពិសេសទស្សនាវដ្ដីវិទ្យាសាស្ត្រថ្មីៗទាំងឯកសាររឹង និងទន់ (Hard and Soft Copy)
- បំប៉នសមត្ថភាពបុគ្គលិកក្នុងការគ្រប់គ្រងបណ្ណាល័យ និង ណែនាំតម្រង់ទិសគ្រូបង្រៀនអំពីការប្រើប្រាស់បណ្ណាល័យ និងធនធានធានសិក្សាផ្សេងៗ
- បំប៉នសមត្ថភាពបុគ្គលិកទទួលបន្ទុកបន្ទប់អនុវត្តន៍ឱ្យឆ្លើយតបទៅនឹងតម្រូវការនិស្សិត និងការអនុវត្តគោលការណ៍សុវត្ថិភាពនៃបន្ទប់អនុវត្តន៍នីមួយៗ
- បង្កើនការគាំទ្រធនធានបច្ចេកវិទ្យានិងអ៊ីនធឺណិតឱ្យឆ្លើយតបទៅនឹងតម្រូវការបង្រៀននិងរៀន
- បំប៉នសមត្ថភាពនិស្សិតនិងគ្រូបង្រៀនអំពីការប្រើប្រាស់ធនធានបច្ចេកវិទ្យា និងជំរុញបុគ្គលិកគាំទ្របច្ចេកទេសជួយសម្រួលបច្ចេកទេសឱ្យឆ្លើយតបតាមតម្រូវការ
- ពិនិត្យនិងកែលម្អគម្រោងថវិកាប្រចាំឆ្នាំដែលអាចអនុវត្តបាន
- បង្កើតប្រព័ន្ធតាមដានលទ្ធផល ដើម្បីវាស់វែងផលប៉ះពាល់នៃសកម្មភាពកែលម្អ និងផ្តល់ទិន្នន័យសម្រាប់ការសម្រេចចិត្ត
- បញ្ជ្រាបការយល់ដឹងដល់គ្រូបង្រៀននិងនិស្សិត អំពីការធានាគុណភាពអប់រំផ្ទៃក្នុង និង ជំរុញឱ្យមានការចូលរួម។

## ៧. ឧបសម្ព័ន្ធ

- របាយការណ៍ស្វ័យវាយតម្លៃរបស់សាកលវិទ្យាល័យ និង ឯកសារឧបសម្ព័ន្ធ
- របាយការណ៍វាយតម្លៃរបស់អនុក្រុមទី១ អនុក្រុមទី២ និងអនុក្រុមទី៣
- បញ្ជីសម្រង់វត្តមានភាគីពាក់ព័ន្ធ ក្នុងដំណើរការវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្ដមសិក្សា
- តារាងពិន្ទុទៅតាមស្តង់ដានីមួយៗ។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**អ្នករៀបចំរបាយការណ៍**

បានឃើញ និងឯកភាព

**ប្រធានក្រុមមន្ត្រីវាយតម្លៃ**

**និន្ន សុភា**

**បណ្ឌិត រ័ត្ន ឆាច**